ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# ផែនការយុទ្ធសាស្ត្រ

# ស្តីពី

# ការកសាងនិងអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## (ដំណាក់កាលទី ៣)

រៀបចំដោយ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ)

ខែ ធ្នូ ឆ្នាំ ២០១៧

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ផែនការយុទ្ធសាស្ត្រ**

**ស្ដីពី**

# ការកសាងនិងអភិវឌ្ឍសមត្ថភាព
# ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់
# ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## (ដំណាក់កាលទី ៣)

រៀបចំដោយ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥០៥...... សហវ.ប្រក

# ប្រកាស

## ស្តីពីការដាក់ឱ្យអនុវត្ត

## ផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាព

## ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ដំណាក់កាលទី ៣)

## របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៥ ស្តីពីការដំឡើងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រកាសលេខ ១០៥៨ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃនាយកដ្ឋាន និង អង្គភាពក្រោមឱវាទរបស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# សម្រេច

**ប្រការ ១._**

ដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាព ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ដំណាក់កាលទី ៣) នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដូចមានខ្លឹមសារភ្ជាប់មកជាមួយប្រកាសនេះ ។

**ប្រការ ២._**

អគ្គលេខាធិការដ្ឋាន ខុទ្ទកាល័យ អគ្គនាយកដ្ឋាន នាយកដ្ឋាន មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត និង គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ថ្ងៃ ចន្ទ ៧កើត ខែជេស្ឋ ឆ្នាំ ច សំរឹទ្ធស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៨

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច, ឯកឧត្តម, លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការ
- អគ្គលេខាធិការដ្ឋាន, អគ្គនាយកដ្ឋាន, អគ្គាធិការដ្ឋាន និង វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០៧៥.....សហវ.......

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៥ ស្តីពីការដំឡើងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រកាសលេខ ១០៥៨ សហវ.ប្រក ចុះថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃនាយកដ្ឋាន និង អង្គភាពក្រោមឱវាទរបស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការងារកសាង និង អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ លើជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

# សម្រេច

**ប្រការ ១.-**

បង្កើតក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានសមាសភាព ដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តម **មាស សុខសេនសាន** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន កសហវ | អនុប្រធាន |
| ៣. ឯកឧត្តម **អិន អេម** | នាយកវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. លោក **យ៉េត វីណែល** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ៥. លោក **ញឹម ខេមរា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ៦. លោក **កែន សម្បត្តិ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៧. លោក **ប៊ុន បុណ្ណារិទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ៨. លោក **ឌី សុវណ្ណា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក |
| ៩. លោក **សេង ស្រេង** | អគ្គនាយករងនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ១០. លោក **ខៀវ សំអាន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១១. លោក **សួន វិចិត្រ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ១២. លោក **ជូ វណ្ណៈ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | សមាជិក |
| ១៣. លោក **ចន ណារិទ្ធិ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១៤. លោក **យូ ធី** | នាយករងនៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៥. លោក **ហ៊ីវ បញ្ញាវុឌ្ឍ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ | សមាជិក |
| ១៦. លោក **ថុន វុឌ្ឍី** | ប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និង សិក្សាស្រាវជ្រាវបណ្តឹង នៃអគ្គាធិការដ្ឋាន | សមាជិក |
| ១៧. លោក **ហ៊ី គុណាវុឌ្ឍន៍** | ប្រធាននាយកដ្ឋានកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល | សមាជិក |
| ១៨. លោក **គាត ហេង** | អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់មូលដ្ឋាននៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ១៩. លោក **អៀង សុភ័ក្ត្រ** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការនៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | លេខាធិការ |

**ប្រការ ២.-**

ក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានតួនាទី និង ភារកិច្ចដូចខាងក្រោម÷

- ដឹកនាំ និងណែនាំតម្រង់ទិសជាយុទ្ធសាស្ត្រក្នុងការអនុវត្ត និង វាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការកសាង និង អភិវឌ្ឍសមត្ថភាព ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធានា និងគាំទ្រឱ្យការបណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាពលើជំនាញគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំ និងអនុវត្តមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ
- ដឹកនាំ និងណែនាំតម្រង់ទិសក្នុងការវាយតម្លៃតម្រូវការ និង ប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងវិក្រឹតការ
- ដឹកនាំ និងណែនាំតម្រង់ទិសការធ្វើបច្ចុប្បន្នកម្មឯកសារផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាព ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ នាពេលខាងមុខ
- បំពេញភារកិច្ចដទៃទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ ៣.-**

ក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មាននាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ នៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន ។

ក្នុងនាមជាសេនាធិការនៃក្រុមការងារកសាងសមត្ថភាព លេខាធិការដ្ឋានមានតួនាទី និង ភារកិច្ចដូចខាងក្រោម÷

- សិក្សាស្រាវជ្រាវ និង រៀបចំសេចក្តីព្រាងផែនការសកម្មភាពប្រចាំឆ្នាំ ដើម្បីដាក់ជូនក្រុមការងារពិនិត្យសម្រេច
- តាមដាន និង រាយការណ៍អំពីវឌ្ឍនភាព និង បញ្ហាប្រឈមនៃការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការកសាង និង អភិវឌ្ឍសមត្ថភាព ដើម្បីដាក់ជូនក្រុមការងារពិនិត្យសម្រេច
- គ្រប់គ្រង តាមដាន និង វាយតម្លៃសកម្មភាពការងារទីប្រឹក្សា និង ជំនាញការជាតិ និង អន្តរជាតិ របស់ក្រុមការងារ
- សម្របសម្រួលរៀបចំកិច្ចប្រជុំរបស់ក្រុមការងារ និង ធ្វើរបាយការណ៍ ឬ កំណត់ហេតុស្តីពីលទ្ធផលនៃកិច្ចប្រជុំនោះ
- គ្រប់គ្រង ចាត់ចែង និង រាយការណ៍អំពីស្ថានភាពធនធានរបស់ក្រុមការងារ
- បំពេញភារកិច្ចដទៃទៀត តាមការណែនាំរបស់ប្រធានក្រុមការងារ ។

**ប្រការ ៤.-**

ដើម្បីធានាគុណភាព ភាពគ្រប់ជ្រុងជ្រោយ និង ប្រសិទ្ធភាពនៃការដឹកនាំអនុវត្តការងារកសាង និង អភិវឌ្ឍសមត្ថភាព ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រុមការងារអាច÷

- រៀបចំកម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី និង ទស្សនៈកិច្ចសិក្សានៅក្នុងស្រុក និង បរទេស ដើម្បីពង្រីកចំណេះដឹង និង ពង្រឹង ចំណេះធ្វើចាំបាច់នានាសម្រាប់គាំទ្រការងារដឹកនាំការងារកសាងសមត្ថភាព
- ជ្រើសរើសទីប្រឹក្សា និង ជំនាញការជាតិ និង អន្តរជាតិ ដើម្បីផ្ទេរចំណេះដឹង, ចែករំលែកបទពិសោធន៍, ប្រឹក្សាយោបល់, សិក្សាស្រាវជ្រាវ និង គាំទ្រការងារវាយតម្លៃគុណភាព ប្រសិទ្ធភាព និង តម្រូវការនៃការបណ្តុះបណ្តាល
- ពិភាក្សា និង ប្រឹក្សាយោបល់ជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានបណ្តុះបណ្តាល និង ស្ថាប័នខួរក្បាលនានា
- ប្រើប្រាស់ជំនួយបច្ចេកទេស និងជំនួយហិរញ្ញវត្ថុរបស់ដៃគូអភិវឌ្ឍន៍ ដើម្បីលើកកម្ពស់ការងារកសាង និងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- សហការជាមួយដៃគូអភិវឌ្ឍន៍ ឬគ្រឹះស្ថានបណ្តុះបណ្តាល រៀបចំកម្មវិធីកសាងសមត្ថភាពរយៈពេលមធ្យម និងរយៈពេលវែងសម្រាប់មន្ត្រីរាជការលើជំនាញពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

**ប្រការ ៥.-**

អនុប្រធាន និង សមាជិកក្រុមការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងករណីប្រធានអវត្តមាន ឬ មានភារកិច្ចផ្សេង អនុប្រធានមួយរូបត្រូវដឹកនាំប្រជុំជំនួស តាមការប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធាន ។ ប្រធានក្រុមការងារអាចអញ្ជើញតំណាងអង្គភាព ក្រសួងស្ថាប័នផ្សេងទៀតចូលរួមប្រជុំ តាមការចាំបាច់ ។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថាន និង ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង សាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យជោគជ័យ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/

*ថ្ងៃ ចន្ទ ៧កើត ខែ[illegible] ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ ២០១៨*

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

***កន្លែងទទួល:***

- *ឯកឧត្តម លោកជំទាវរដ្ឋលេខាធិការ កសហវ*
- *ឯកឧត្តម លោកជំទាវអនុរដ្ឋលេខាធិការ កសហវ*

  *"ដើម្បីជូនជ្រាប"*
- *អគ្គលេខាធិការដ្ឋាន*
- *គ្រប់អគ្គនាយកដ្ឋាន*
- *អគ្គាធិការដ្ឋាន*
- *វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

  *"ដើម្បីអនុវត្ត និង សហការអនុវត្ត"*
- *ដូចប្រការ ៧*
- *ឯកសារ-កាលប្បវត្តិ*

# មាតិកា


មាតិកា ............................................................ i

តារាងពាក្យកាត់ ............................................................ ii

១. សេចក្តីផ្តើម ............................................................ ១

១.១. សាវតារ ............................................................ ១

១.២. វង្វាយតម្លៃការបណ្តុះបណ្តាលនិងវិក្រឹតការ និង សមិទ្ធផលកន្លងមក ............................................................ ៤

១.៣. បញ្ហាប្រឈមនៃការបណ្តុះបណ្តាលនិងវិក្រឹតការ និង វិធានការដោះស្រាយ ............................................................ ៦

២. ចក្ខុវិស័យ និង បេសកកម្ម ............................................................ ៧

២.១. ចក្ខុវិស័យ ............................................................ ៧

២.២. បេសកកម្ម ............................................................ ៧

៣. គោលបំណង គោលដៅ និង លទ្ធផលរំពឹងទុក ............................................................ ៨

៣.១. គោលបំណង ............................................................ ៨

៣.២. គោលដៅ ............................................................ ៨

៣.៣. លទ្ធផលរំពឹងទុក ............................................................ ៩

៤. ក្របខណ្ឌយុទ្ធសាស្ត្រនៃការបណ្តុះបណ្តាលនិងអភិវឌ្ឍសមត្ថភាព ............................................................ ១០

៤.១. ការវិភាគតម្រូវការបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាព ............................................................ ១១

៤.២. កត្តាកំណត់ជោគជ័យ ............................................................ ១៤

៤.៣. ទិសដៅជាយុទ្ធសាស្ត្រ និង យុទ្ធសាស្ត្រ ............................................................ ១៥

៤.៣.១. យុទ្ធសាស្ត្រទី ១: ការអភិវឌ្ឍសមត្ថភាពស្ថាប័ន ............................................................ ១៥

៤.៣.២. យុទ្ធសាស្ត្រទី ២: ការពង្រឹងពង្រីកការស្រាវជ្រាវនិងអភិវឌ្ឍ ............................................................ ១៦

៤.៣.៣. យុទ្ធសាស្ត្រទី ៣: ការបណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាព ............................................................ ១៦

៥. ផែនការសកម្មភាព ............................................................ ១៦

៦. តួអង្គនិងយន្តការអនុវត្តន៍ និង ប្រភពធនធានហិរញ្ញវត្ថុ ............................................................ ១៩

៦.១. តួអង្គអនុវត្តន៍ ............................................................ ១៩

៦.២. យន្តការអនុវត្តន៍ ............................................................ ២៣

៦.៣. ប្រភពធនធានហិរញ្ញវត្ថុ ............................................................ ២៤

៧. ការត្រួតពិនិត្យ និង វាយតម្លៃ ............................................................ ២៤

៨. សេចក្តីសន្និដ្ឋាន ............................................................ ២៧

*ឧបសម្ព័ន្ធ ១: តារាងផែនការសកម្មភាពស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាព*

*ឧបសម្ព័ន្ធ ២: តារាងគោលដៅនិងតម្រូវការជំនាញសម្រាប់កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

*ឧបសម្ព័ន្ធ ៣: គំនូសបំព្រួញចលនការនៃប្រព័ន្ធតួអង្គ និង យន្តការអនុវត្តន៍ការកសាងនិងអភិវឌ្ឍសមត្ថភាព*

*ឧបសម្ព័ន្ធ ៤: តារាងសមិទ្ធផលសំខាន់ៗនៃកម្មវិធីបណ្តុះបណ្តាល ១៩៩៨-២០១៦*

*ឧបសម្ព័ន្ធ ៥: តារាងគ្រឹះស្ថានសាធារណៈរដ្ឋបាល នៅព្រះរាជាណាចក្រកម្ពុជា*

*ឧបសម្ព័ន្ធ ៦: តារាងសង្ខេបចំនួនអង្គភាពថវិកាសរុបនៅព្រះរាជាណាចក្រកម្ពុជា*

# តារាងពាក្យកាត់

| ល.រ | ពាក្យកាត់ | ពាក្យពេញ | ពន្យល់ |
|---|---|---|---|
| ១. | កសហវ | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | |
| ២. | វសហ | វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | |
| ៣. | អគហ | អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | |
| ៤. | D&D | Decentralization and Deconcentration | វិមជ្ឈការ និងវិសហមជ្ឈការ |
| ៥. | FMIS | Financial Management Information System | ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ៦. | GDAP | General Department Action Plan | ផែនការសកម្មភាពរួម |
| ៧. | MBPI | Merit Based Pay Initiative | ប្រព័ន្ធលាភការ |
| ៨. | MTEF | Medium-Term Expenditure Framework | ក្របខណ្ឌចំណាយរយៈពេលមធ្យម |
| ៩. | PAR | Public Administrative Reform | កំណែទម្រង់រដ្ឋបាលសាធារណៈ |
| ១០. | PFM | Public Financial Management | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ១១. | POC | Priority Operating Costs | កញ្ចប់លើកទឹកចិត្ត |
| ១២. | TOT | Training of Trainers | ការបណ្តុះបណ្តាលគ្រូបង្គោល |

# ផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣

## ១.សេចក្តីផ្តើម

ការកសាងនិងអភិវឌ្ឍសមត្ថភាពគឺជាឧបករណ៍ស្នូល និងគន្លឹះ សម្រាប់ទ្រទ្រង់ដល់ការអភិវឌ្ឍប្រកបដោយចីរភាព និងជំរុញផលិតភាព ទាំងនៅក្នុងវិស័យសាធារណៈ និង វិស័យឯកជន ។ ការកសាងនិងអភិវឌ្ឍសមត្ថភាព គ្របដណ្តប់លើការកសាងក្របខណ្ឌការងារ ការកែប្រែវប្បធម៌ធ្វើការងារ គោលនយោបាយ ប្រព័ន្ធនិងនីតិវិធីនៅក្នុងអង្គភាព សមត្ថភាព ជំនាញ និងការលើកទឹកចិត្ត ដើម្បីឈានទៅសម្រេចបានលទ្ធផលចុងក្រោយរបស់អង្គភាពការងារ ។

ក្នុងក្របខណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់នេះដំបូងនៅឆ្នាំ ២០០៤ ជាមួយនឹងឆន្ទៈនយោបាយមុតស្រួច និង ឥតរាថយ ក្នុងគោលដៅច្បាស់លាស់គឺការផ្លាស់ប្តូរប្រព័ន្ធថវិកាពីថវិកាផ្អែកលើធាតុចូលនិងមជ្ឈការ ឆ្ពោះទៅថវិកាផ្អែកលើសមិទ្ធកម្មនិងវិមជ្ឈការ។ កម្មវិធីកែទម្រង់នេះ មានបួនដំណាក់កាល និងឈានឡើងជាជំហានៗ ជាមួយគោលបំណងជាក់លាក់សម្រាប់ដំណាក់កាលនីមួយៗ ពោលគឺៈ ដំណាក់កាលទី១.ភាពជឿទុកចិត្តនៃថវិកា, ដំណាក់កាលទី២.គណនេយ្យភាពហិរញ្ញវត្ថុ, ដំណាក់កាលទី៣.ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងដំណាក់កាលទី៤.គណនេយ្យភាពចំពោះសមិទ្ធកម្ម ឬ លទ្ធផល ។

កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាផ្នែកមួយនៃកម្មវិធីកែទម្រង់សំខាន់ៗ របស់រាជរដ្ឋាភិបាល សំដៅចូលរួមចំណែកសម្រេចគោលដៅនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ជាពិសេសការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាសមាសធាតុដ៏សំខាន់មួយ សម្រាប់ធានាភាពរឹងមាំនៃអភិបាលកិច្ចល្អ ដែលជាស្នូលនៃ **យុទ្ធសាស្ត្រចតុកោណ** ដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាល នៅក្នុងនីតិកាលទី ៥ នៃរដ្ឋសភា ដើម្បីកំណើនការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា ។

### ១.១. សាវតារ

ក្នុងបរិការណ៍ នៃសមាហរណកម្មសេដ្ឋកិច្ចតំបន់និងពិភពលោក និងក្រោមឥទ្ធិពលនៃនិន្នាការវិវឌ្ឍន៍ដ៏ឆាប់រហ័សខាងបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ ការកសាងនិងអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ប្រកបដោយគុណភាពទាំងចំនួន និង ជំនាញឱ្យបានគ្រប់គ្រាន់ និងសមស្រប គឺជាកត្តាចាំបាច់និងមិនអាចខ្វះបាន សម្រាប់ធានាជោគជ័យប្រកដោយចីរភាព និងប្រសិទ្ធភាព នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានចាត់ទុកថា ការពង្រឹងសមត្ថភាពធនធានមនុស្ស និងស្ថាប័ន មានសារៈសំខាន់ជាសារវន្ត សម្រាប់ធានាចីរភាព និងប្រសិទ្ធភាព ក្នុងការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកែទម្រង់សំខាន់ៗ ដទៃទៀតរបស់រាជរដ្ឋាភិបាល ។

ក្នុងស្មារតីនេះ ផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ លើមុខជំនាញចាំបាច់សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំ និង អនុម័តដាក់ឱ្យអនុវត្តជាផ្លូវការដំបូង នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៧ ដោយគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់តម្រង់ទិសការរៀបចំ និងអនុវត្តកម្មវិធីស្រាវជ្រាវ បណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាពមន្ត្រីរាជការ ឆ្លើយតបទៅនឹងតម្រូវការ សម្រាប់ការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលនៅដំណាក់កាលទី១ ដល់ ដំណាក់កាលទី ៤ ។ ***ផែនការយុទ្ធសាស្ត្រនោះ គឺជាឯកសាររស់ ដែលអាចត្រូវបានកែសម្រួល និងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់ ទៅតាមសេចក្តីត្រូវការនៃការកសាងនិងអភិវឌ្ឍសមត្ថភាព និង ស្របតាមបរិការណ៍គ្របដណ្តប់ នៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងដំណាក់កាលនីមួយៗ***។

ផ្អែកតាមបទពិសោធន៍ ការកសាងនិងអភិវឌ្ឍសមត្ថភាព សម្តែងឡើងតាមរយៈ **ការអភិវឌ្ឍជំនាញ** និង **ការពង្រីកវិសាលភាពនៃវិធីសាស្ត្រអភិវឌ្ឍសមត្ថភាព** ដែលគ្រប់អង្គភាព/ក្រសួងស្ថាប័ន ចាំបាច់ត្រូវចូលរួមប្រតិបត្តិ និង ត្រៀមលក្ខណៈសម្បត្តិឱ្យបានល្អជានិច្ច ។ ក្នុងទិដ្ឋភាពនេះ ការអភិវឌ្ឍជំនាញមានពីរកម្រិតគឺ **ជំនាញឯកទេសមូលដ្ឋាន (Foundation Skills)** និង **ជំនាញឯកទេសជាក់លាក់ (Professional Skills)** ដែលត្រូវផ្សារភ្ជាប់ទៅនឹងតម្រូវការរបស់អង្គភាព/ក្រសួងស្ថាប័ន ។ ចំណែកការពង្រីកវិសាលភាពនៃវិធីសាស្ត្រអភិវឌ្ឍសមត្ថភាព គឺសំដៅមធ្យោបាយ ដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការរបស់អង្គភាព/ក្រសួងស្ថាប័ននីមួយៗ ដែលអាចរួមមាន **ការអភិវឌ្ឍគោលនយោបាយធនធានមនុស្ស, ការប្រើប្រាស់អ្នកជំនាញពីខាងក្រៅ, ការអភិវឌ្ឍស្ថាប័ន, ការអភិវឌ្ឍកិច្ចសហប្រតិបត្តិការ និង ការអភិវឌ្ឍការលើកទឹកចិត្ត** ជាដើម ។

ជាក់ស្តែង នៅក្នុងដំណាក់កាលទី១ នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍជំនាញ គឺបានផ្តោតជាសំខាន់ទៅលើមុខជំនាញឯកទេសមូលដ្ឋាន (Foundation Skills) និង មុខជំនាញឯកទេសជាក់លាក់ (Professional Skills) មួយចំនួន សម្រាប់បញ្ជ្រាបចំណេះដឹង និង ការយល់ដឹងជាមូលដ្ឋានជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អំពីខ្លឹមសារនិងសារសំខាន់ នៃកម្មវិធីកែទម្រង់នេះ ដើម្បីជំរុញការគាំទ្រ និង លើកកម្ពស់ការចូលរួមរបស់គាត់ក្នុងការអនុវត្ត សំដៅឈានទៅសម្រេចគោលបំណងជាបឋមគឺ ***"ការកសាងភាពទុកចិត្តបាននៃថវិកា (Credible Budget)"*** ។ ទន្ទឹមនេះ យើងបានប្រើប្រាស់ប្រព័ន្ធលើកទឹកចិត្តដែលហៅថា **ប្រព័ន្ធលាភការ (MBPI)**[1] អនុវត្តចំពោះក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមនឹងប្រព័ន្ធបៀវត្សរ៍ផ្លូវការដែលមានស្រាប់ ព្រមទាំងប្រើប្រាស់អ្នកជំនាញការអន្តរជាតិ សម្រាប់ជាមធ្យោបាយក្នុងការពង្រីកវិសាលភាពនៃវិធីសាស្ត្រអភិវឌ្ឍសមត្ថភាព ។

នៅដំណាក់កាលទី២ ជាមួយនឹងការបន្តផ្តោតលើជំនាញមូលដ្ឋានគ្រឹះ កម្មវិធីបណ្តុះបណ្តាលជាក់ស្តែងត្រូវបានបន្ថែមមុខជំនាញជាក់លាក់ (Professional Skills) ជាច្រើនទៀត ដែលជាសេចក្តីត្រូវការចាំបាច់សម្រាប់ការអនុវត្ត*"ថវិកាកម្មវិធី និងអង្គភាពថវិកា"* និង ការដាក់ឱ្យអនុវត្ត*"ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)"* ជំហានទី១ ព្រមទាំងត្រូវបានពង្រីកវិសាលភាពការបណ្តុះបណ្តាលជូនមន្ត្រីរាជការ នៃក្រសួងស្ថាប័នចំនួន ៩ ថែមទៀត[2] រួមនឹងមន្ទីរអង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទ ក្នុងគោលដៅបន្តរក្សា ***"ភាពជឿទុកចិត្តនៃថវិកា"*** ដែលសម្រេចបានជាសារវន្តនៅក្នុងដំណាក់កាលទី១ ផង និងសម្រេចបាន ***"គណនេយ្យភាពហិរញ្ញវត្ថុ (Financial Accountability)"*** ដែលជាគោលបំណងនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅដំណាក់កាលទី២ ផង ។ ជាមួយនេះ សម្រាប់មធ្យោបាយពង្រីកវិសាលភាពនៃវិធីសាស្ត្រអភិវឌ្ឍ សមត្ថភាព យើងបានប្តូរការលើកទឹកចិត្តពី MBPI ទៅជា POC ដែលហៅថា កញ្ចប់លើកទឹកចិត្ត (Priority Operating Costs) និងអនុវត្តចំពោះក្រុមការងារកែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នមួយចំនួន រួមនឹងប្រព័ន្ធបៀវត្សរ៍មូលដ្ឋានមានស្រាប់ដែលត្រូវបានបង្កើនជាបណ្តើរៗ ព្រមទាំងបន្តជំរុញនូវការចែករំលែកចំណេះដឹង និងបទពិសោធន៍ពីអ្នកជំនាញការអន្តរជាតិ តាមរយៈសិក្ខាសាលា និង វគ្គសិក្សាខ្លីៗនៅនឹងកន្លែងក្នុងប្រទេស រួមនឹងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នបណ្តុះបណ្តាលក្រៅប្រទេស សម្រាប់ការងារកសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ។

---

[1] *MBPI: stand for Merit Based Pay Initiative*

[2] *ក្រសួងអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បង ក្នុងឆ្នាំ ២០១៥ មានចំនួន ១០ ក្នុងនោះមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នផ្សេងទៀតចំនួន ៩ ដែលរួមមានៈ (១). ក្រសួងអប់រំ យុវជន និងកីឡា, (២).ក្រសួងសុខាភិបាល, (៣).ក្រសួងកិច្ចការនារី, (៤).ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, (៥).ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ, (៦).ក្រសួងអភិវឌ្ឍជនបទ, (៧).ក្រសួងសាធារណៈការនិងដឹកជញ្ជូន, (៨).ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និង (៩).ក្រសួងយុត្តិធម៌ ។*

បច្ចុប្បន្ន ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានមកដល់ដំណាក់កាលទី៣ ក្នុងគោលបំណងបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាល ហើយភាពជាម្ចាស់ និងការទទួលខុសត្រូវភាគច្រើនត្រូវបានផ្ទេរទៅកាន់ក្រសួងស្ថាប័ន ដែលនេះគឺជាចំណុចរបត់ដ៏សំខាន់មួយ ក្នុងកាលៈទេសៈដែលសមត្ថភាពធនធានមនុស្សនៅមានកម្រិត ។ លើសពីនេះ គិតត្រឹមឆ្នាំ ២០១៧ មានក្រសួងស្ថាប័នសរុបចំនួន ៣៦ ហើយ ដែលត្រូវអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បង និងអង្គភាពថវិកា ហើយដល់ឆ្នាំ២០១៨ គ្រប់ក្រសួងស្ថាប័ន រួមនឹងមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ នឹងត្រូវចូលរួមអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បងនេះ ។ ប្រការនេះ ធ្វើឱ្យការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានវិសាលភាពកាន់តែធំទូលាយនិងស្មុគស្មាញ ដែលតម្រូវឱ្យគ្រប់ក្រសួង ស្ថាប័ន ត្រូវបង្កើនឆន្ទៈចូលរួមអនុវត្តឱ្យកាន់តែសកម្មខ្លាំងក្លាថែមទៀត ។ ក្នុងន័យនេះ គ្រប់ក្រសួងស្ថាប័ន មានភាពចាំបាច់ក្នុងការពង្រឹងសមត្ថភាពជំនាញវិជ្ជាជីវៈដល់មន្ត្រីរាជការរបស់ខ្លួនជាពិសេស ***ក្រុមមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ដែលជា ក្រុមលទ្ធកម្ម, ក្រុមការងារថវិកា, រដ្ឋទេយ្យករបុរេប្រទាន, រដ្ឋទេយ្យករបុរេប្រទានរង, ភ្នាក់ងារបើកផ្តល់ និង ភ្នាក់ងារបើកផ្តល់ជំនួស ជាដើម*** ដើម្បីធានាបាននូវប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាពស្របតាមគោលការណ៍ណែនាំ និង នីតិវិធី ក្នុងការរៀបចំ និង អនុវត្តថវិកាកម្មវិធី និង អង្គភាពថវិកា ។

ដើម្បីឱ្យការកសាងនិងអភិវឌ្ឍសមត្ថភាព ត្រូវបានរៀបចំនិងអនុវត្ត មានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ គ្រប់ជ្រុងជ្រោយនិងប្រកបដោយគុណភាព វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានដំឡើងឋានៈស្មើអគ្គនាយកដ្ឋាន[3] និង បំពេញមុខងារជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារស្រាវជ្រាវ បណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាព ដោយសហការជិតស្និទ្ធជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងស្ថាប័ន និងដៃគូជាតិ-អន្តរជាតិ ។ ការកសាងនិងអភិវឌ្ឍសមត្ថភាពលើជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ត្រូវបន្តផ្តោតអាទិភាពលើ **ការអភិវឌ្ឍជំនាញ** តាមរយៈកម្មវិធីបណ្តុះបណ្តាល ដែលមានលក្ខណៈជាអាជីព ស្របតាមតម្រូវការ និង **ការពង្រីកវិសាលភាពនៃវិធីសាស្ត្រអភិវឌ្ឍសមត្ថភាព** ដែលត្រូវគ្របដណ្តប់គ្រប់ក្រសួងស្ថាប័ន និងផ្អែកតាមផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ។ ក្នុងន័យនេះ មុខជំនាញ និងប្រធានបទពាក់ព័ន្ធនៃកម្មវិធីបណ្តុះបណ្តាល ចាំបាច់ត្រូវបន្តជំរុញការស្រាវជ្រាវនិងអភិវឌ្ឍថែមទៀត រួមជាមួយនឹងការអនុវត្តនូវការវាយតម្លៃលទ្ធផលជាទៀងទាត់ ដើម្បីធានាការផ្សារភ្ជាប់នូវប្រសិទ្ធភាពនិងគុណភាព នៃការបណ្តុះបណ្តាលទៅនឹងការអនុវត្តតួនាទីភារកិច្ច ប្រកបដោយមនសិការ និងការទទួលខុសត្រូវរបស់សិក្ខាកាម សំដៅរួមចំណែកសម្រេចគោលដៅនៃការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងដំណាក់កាលទី ៣ នេះ ។

ក្នុងស្មារតីនេះ ផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ ចាំបាច់ត្រូវធ្វើបច្ចុប្បន្នកម្មឡើងវិញ ដើម្បីឱ្យសមស្របទៅនឹងបរិបទ និងសេចក្តីត្រូវការនៅក្នុងដំណាក់កាលថ្មីនេះ ដោយត្រូវបញ្ចូលនូវមុខជំនាញ ប្រធានបទនិងវិធីសាស្ត្រថ្មីៗថែមទៀត អនុលោមតាមគោលការណ៍ណែនាំ បទប្បញ្ញត្តិ និងលក្ខណៈបច្ចេកទេស សម្រាប់ការអនុវត្តថវិកាកម្មវិធីពេញលេញ និងតម្រូវការនៃការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជំហានទី២ រួមនឹងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងការកែទម្រង់ពីរទៀតគឺ ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ សម្រាប់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

***រួមសេចក្តីមក ផែនការយុទ្ធសាស្ត្រនេះ គឺជាត្រីវិស័យសម្រាប់ចង្អុលទិសជាយុទ្ធសាស្ត្ររយៈពេលមធ្យម ក្នុងការរៀបចំនិងអនុវត្តផែនការ កម្មវិធី និងសកម្មភាពប្រចាំឆ្នាំ លើការកសាងនិងអភិវឌ្ឍសមត្ថភាព លើជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ច***

[3] *អនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០១៥ ។*

*និងហិរញ្ញវត្ថុសាធារណៈ ផ្ដល់ផលសិក្ខាកាមគោលដៅដែលត្រូវចូលរួមពាក់ព័ន្ធនៅក្នុងដំណើរការនៃ “ការរៀបចំថវិកា ការអនុម័តថវិកា ការអនុវត្តថវិកា ការតាមដានត្រួតពិនិត្យការអនុវត្តថវិកា និងការធ្វើសវនកម្មនិងអធិការកិច្ចហិរញ្ញវត្ថុ លើកិច្ចដំណើរការ និងលទ្ធផល ឬសមិទ្ធកម្ម នៃការអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា”[4] ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងដំណាក់កាលទី៣ ក្នុងគោលដៅបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និង ដើម្បីប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធ ក្នុងការវិភាជ និង ការប្រើប្រាស់ធនធានហិរញ្ញវត្ថុសាធារណៈ ប្រកបដោយតម្លាភាព គណនេយ្យភាព និង មានប្រតិភូល្យការគ្រប់ជ្រុងជ្រោយ សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ឆ្លើយតបទៅនឹងតម្រូវការ និង បំណងរបស់ប្រជាជន ។*

## ១.២. វាយតម្លៃការបណ្តុះបណ្តាលនិងវិក្រឹតការ និង សមិទ្ធផលកន្លងមក

ក្នុងក្របខណ្ឌស្ថាប័ន កន្លងមក ការបណ្តុះបណ្តាលនិងវិក្រឹតការ លើមុខជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំនិងអនុវត្តដោយតួអង្គផ្សេងៗគ្នាជាច្រើន ទៅតាមលទ្ធភាព និង ការចាំបាច់ ។ ក្នុងនោះ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៧ តាមគំនិតផ្តួចផ្តើមរបស់កិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ កាលនោះជាអគ្គលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ដឹកនាំសម្របសម្រួលផ្ទាល់ដោយឯកឧត្តមបណ្ឌិត **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អតីតនាយកវិទ្យាស្ថាន ក្រោមជំនួយបច្ចេកទេសរបស់ធនាគារពិភពលោក គឺជាតួអង្គសំខាន់មួយដែលបានដើរតួនាទីយ៉ាងសកម្មលើការងារនេះ ។

វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសហការជាមួយដៃគូ ជាអង្គការនិងស្ថាប័នបណ្តុះបណ្តាលនានា ដូចជា វិទ្យាស្ថានធនាគារពិភពលោក (WBI), វិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី (ADBI), មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF), កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP), សាកលវិទ្យាល័យហ្វីលីពីន (UP) និង វិទ្យាស្ថានអាស៊ីសម្រាប់ការគ្រប់គ្រង (AIM) ប្រទេសហ្វីលីពីន, សាលារដ្ឋបាលសាធារណៈប្រទេសសឹង្ហបុរី (CSC), វិទ្យាស្ថានបណ្តុះបណ្តាលក្នុងតំបន់នៃមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំនៅប្រទេសសឹង្ហបុរី (STI), សាកលវិទ្យាល័យម៉ាឡាយ៉ាប្រទេសម៉ាឡេស៊ី (MU), សាកលវិទ្យាល័យណាហ្គោយ៉ាប្រទេសជប៉ុន, អង្គការចៃការជប៉ុន (JICA), មជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិនៃក្រសួងហិរញ្ញវត្ថុប្រទេសជប៉ុន (JCIF), វិទ្យាស្ថានអភិវឌ្ឍន៍កូរ៉េ (KDI), សាកលវិទ្យាល័យឆាលស្ទឺតប្រទេសអូស្ត្រាលី (CSU) ។

ចាប់ពីឆ្នាំ ២០១១ មក វិទ្យាស្ថានបានពង្រីកកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នបណ្តុះបណ្តាលនិងស្រាវជ្រាវមួយចំនួនទៀត ដូចជា វិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃអង្គការសហប្រជាជាតិ (UNITAR), វិទ្យាស្ថានអភិវឌ្ឍន៍ហិរញ្ញវត្ថុអាស៊ី-ប៉ាស៊ីភិច ទីក្រុងសៀងហៃ ប្រទេសចិន (AFDI), សាកលវិទ្យាល័យបច្ចេកវិទ្យាណាន់យ៉ាង (NTU) និង មូលនិធិតេម៉ាសេកអន្តរជាតិ (TFI) ប្រទេសសឹង្ហបុរី និង មជ្ឈមណ្ឌលតំបន់អាស៊ី-ប៉ាស៊ីភិច នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ប្រចាំទីក្រុងបាងកកជាដើម ។ ក្រៅពីនេះនៅមានតួអង្គដទៃទៀត ដែលជាអគ្គលេខាធិការដ្ឋាន/អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ

---

[4] *សិក្ខាកាមគោលដៅចែកចេញជា៤ ប្រភេទគឺ (១). ក្រុមមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុនៃអង្គភាពថវិកា ដែលរួមមាន: ក្រុមការងារថវិកា ក្រុមលទ្ធកម្ម, មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ, រដ្ឋទេយ្យករបុរេប្រទាន, រដ្ឋទេយ្យករបុរេប្រទានរង, ភ្នាក់ងារបើកផ្តល់, ភ្នាក់ងារបើកផ្តល់ជំនួស, (២). ក្រុមមន្ត្រីអនុវត្តផែនការសកម្មភាពនៃអង្គភាពថវិកា, (៣). មន្ត្រីជំនាញ និង សមាជិកសមាជិកានៃអង្គនីតិបញ្ញត្តិ និង (៤). មន្ត្រីជំនាញ និង ថ្នាក់ដឹកនាំនៃអាជ្ញាធរសវនកម្មជាតិ រួមនឹងបុគ្គលិកជំនាញ និងថ្នាក់ដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ។*

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងស្ថាប័ន ក៏បានចូលរួមផ្ដល់នូវការបណ្ដុះបណ្ដាលផងដែរ ពិសេស ក្រោយពេលដែលជំនួយបច្ចេកទេសរបស់ធនាគារពិភពលោកសម្រាប់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានបញ្ចប់ ។

ក្នុងក្របខណ្ឌអនុវត្ត កម្មវិធីបណ្ដុះបណ្ដាលរបស់វិទ្យាស្ថាន កន្លងមក ចែកជាបីប្រភេទគឺៈ *(១).កម្មវិធីបណ្ដុះបណ្ដាលរយៈពេលវែង (៦ ខែ ដល់ ២ ឆ្នាំ)* ជាវគ្គសិក្សាកម្រិតសញ្ញាបត្រ (បរិញ្ញាបត្រជាន់ខ្ពស់ ឬ សញ្ញាបត្រជាន់ខ្ពស់) សម្រាប់ពង្រឹងពង្រីកសមត្ថភាពជូនថ្នាក់ដឹកនាំកម្រិតជំនាញ និង មន្ត្រីជំនាញ ដែលទើបទទួលបានការតែងតាំងប្រគល់ភារកិច្ច ឬត្រៀមទទួលការតែងតាំងប្រគល់ភារកិច្ចពាក់ព័ន្ធការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ, *(២).កម្មវិធីបណ្ដុះបណ្ដាលរយៈពេលមធ្យម (១ ខែ ដល់ ៦ ខែ)* ជាវគ្គសិក្សាកម្រិតវិញ្ញាបនបត្រ សំដៅតម្រង់ទិសនិងហ្វឹកហាត់ជំនាញ ពាក់ព័ន្ធការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ពិសេសសម្រាប់មន្ត្រីជ្រើសរើសថ្មី និង *(៣).កម្មវិធីបណ្ដុះបណ្ដាលរយៈពេលខ្លី (ក្រោម ១ ខែ)* ជាវគ្គសិក្សាកម្រិតវិក្រឹតការនិងសុក្រឹតការចំណេះដឹង និងព័ត៌មាន ពាក់ព័ន្ធនឹងបទប្បញ្ញត្តិ លិខិតបទដ្ឋាន និង គោលការណ៍ណែនាំផ្សេងៗ សម្រាប់អនុវត្តការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ដែលប្រព្រឹត្តទៅក្នុងទម្រង់ជាកម្មសិក្ខាសាលា, សិក្ខាសាលាផ្សព្វផ្សាយ រួមនឹងទស្សនកិច្ចសិក្សាសំខាន់ៗ ។

ចំពោះមុខសញ្ញានៃការបណ្ដុះបណ្ដាល ក្នុងដំណាក់កាលឆ្នាំ ១៩៩៨-២០០៣ កម្មវិធីបណ្ដុះបណ្ដាលបានផ្ដោតលើមុខវិជ្ជាជំនាញដូចជាៈ ***ការគ្រប់គ្រងសេដ្ឋកិច្ច, ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, គណនេយ្យ, ច្បាប់, កុំព្យូទ័រ, ភាសាអង់គ្លេស*** សម្រាប់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និង កម្មវិធីសិក្សា វគ្គពិសេសស្ដីពី ***"ជំនាញដឹកនាំ និង គ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ"*** សម្រាប់កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ជូនថ្នាក់ដឹកនាំអង្គភាព, វគ្គពិសេសស្ដីពី ***"ជំនាញការងារគយអាស៊ាន"*** សម្រាប់មន្ត្រីរាជការជំនាញគយនិងរដ្ឋាករ និង វគ្គពិសេសស្ដីពី ***"ជំនាញការងារពន្ធដារ"*** សម្រាប់មន្ត្រីជំនាញពន្ធដារ ។ ទន្ទឹមនោះ ចំពោះកម្មវិធីសិក្សាក្នុងទម្រង់ជាសិក្ខាសាលា ទស្សនកិច្ចសិក្សា និងវគ្គសិក្សាខ្លីៗ គឺបានផ្ដោតលើប្រធានបទពាក់ព័ន្ធនឹងការផ្សព្វផ្សាយនូវវិធានការកំណែទម្រង់ និងច្បាប់សម្រាប់អនុវត្តក្នុងការគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានបទស្ដីពីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាក់ទិនទៅនឹងការវិវត្តថ្មីៗនៅក្នុងប្រទេស ក្នុងតំបន់ និងក្នុងពិភពលោក ។ ក្នុងដំណាក់កាល ចាប់ពីឆ្នាំ ២០០៤ កម្មវិធីបណ្ដុះបណ្ដាលបានផ្ដោតជាសំខាន់ទៅលើមុខជំនាញ ដូចជាៈ ***សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ថវិកា, គណនេយ្យ, គ្រប់គ្រង, ច្បាប់គយ, អធិការកិច្ចហិរញ្ញវត្ថុ, ពន្ធដារ, សវនកម្ម, ភាសាអង់គ្លេសសម្រាប់ហិរញ្ញវត្ថុ, និងកុំព្យូទ័រ*** ជាដើម ដែលជាមូលដ្ឋានគ្រឹះចាំបាច់សម្រាប់ចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល នៅគ្រប់ដំណាក់កាល ។

ជាលទ្ធផល ក្នុងរយៈពេល ២០ ឆ្នាំកន្លងមកនេះ ការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការលើជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ សម្រេចបាននូវសមិទ្ធផលគួរឱ្យកត់សម្គាល់ជាច្រើន ដែលបានរួមចំណែកធ្វើឱ្យធនធានមនុស្សនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជា រាជរដ្ឋាភិបាល អាចគ្រប់គ្រងបានដោយគត់មត់នូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការគ្រប់គ្រងបំណុលសាធារណៈ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ និង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលធ្វើឱ្យកម្ពុជាចាកផុតពីបំណុលសាច់ប្រាក់រ៉ាំរ៉ៃ និងឈានមកមានអតិរេកសាច់ប្រាក់ សម្រាប់បង្កើនថវិកាលើការវិនិយោគសាធារណៈក្នុងវិស័យសំខាន់ៗ ដូចជាអប់រំ និងសុខាភិបាល និងការបង្កើនប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និវត្តជន និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដោយបើកផ្ដល់ជូនបានទាន់ពេលវេលារៀងរាល់ខែទៀតផង ។

ក្នុងនោះ នៅក្នុងអំឡុងពេលពីឆ្នាំ ១៩៩៨-២០០៣ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអនុវត្តសកម្មភាពនៃការងារបណ្ដុះបណ្ដាល ហ្វឹកហ្វឺននិងវិក្រឹតការ ជូនមន្ត្រីរាជការដែលជា ***មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ, ថ្នាក់ដឹកនាំអង្គភាព, មន្ត្រីជំនាញគយនិងរដ្ឋាករ និង គយអាស៊ាន, មន្ត្រីជំនាញពន្ធដារ និង មន្ត្រីជំនាញពាក់ព័ន្ធដទៃទៀត*** របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័ន បានសរុបចំនួន ១៤,៨១៣ នាក់ *(ឧបសម្ព័ន្ធ៤: ផ្នែកទី១)* ។ នៅក្នុងអំឡុងពេលពីឆ្នាំ ២០០៤-២០១៦ ក្រសួង

សម្រេចការបណ្តុះបណ្តាល ហ្វឹកហ្វឺននិងវិក្រឹតការជូនមន្ត្រីរាជការជំនាញ ថ្នាក់ដឹកនាំជំនាញ និងថ្នាក់ដឹកនាំជាន់ខ្ពស់ បានសរុបចំនួន ១៧,៣១៧ នាក់ *(ឧបសម្ព័ន្ធ៤: ផ្នែកទី២)* ដោយផ្តោតលើមុខជំនាញ មូលដ្ឋានគ្រឹះនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការរៀបចំនិងអនុវត្តផែនការសកម្មភាព នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការរៀបចំនិងអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកា, ការរៀបចំនិងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ, ការរៀបចំកិច្ចបញ្ជិកាគណនេយ្យហិរញ្ញវត្ថុ, ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ, ការកត់ត្រានិងតាមដានចលនាឥណទាននៃការអនុវត្តថវិកាកម្មវិធី និង មុខជំនាញពាក់ព័ន្ធការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមុខជំនាញទាំងនេះ គឺជាតម្រូវការចាំបាច់សម្រាប់រួមចំណែកអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ជារួម ការបណ្តុះបណ្តាល ហ្វឹកហ្វឺន និង វិក្រឹតការ រួមនឹងកិច្ចខិតខំប្រឹងប្រែងទាំងអស់ពាក់ព័ន្ធការកសាងនិងអភិវឌ្ឍសមត្ថភាព នាពេលកន្លងមក បានរួមចំណែកផ្តល់ចំណេះដឹង ជំនាញ និងគុណវុឌ្ឍិចាំបាច់ ជូនដល់មន្ត្រីរាជការ និងថ្នាក់ដឹកនាំសម្រាប់ឆ្លើយតបនឹងតម្រូវការ ក្នុងការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាឧបករណ៍គោលនយោបាយដ៏មានសារៈសំខាន់ សម្រាប់ការគ្រប់គ្រងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច, ការកែលម្អប្រព័ន្ធគ្រប់គ្រងថវិកា, ការធ្វើទំនើបកម្មប្រព័ន្ធប្រមូលចំណូលសាធារណៈ, ការកែលម្អប្រព័ន្ធគណនេយ្យសាធារណៈ, ការកសាងប្រព័ន្ធសវនកម្ម និង អធិការកិច្ចហិរញ្ញវត្ថុ, ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ និង ការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដែលជាបច្ច័យគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ។

## ១.៣. បញ្ហាប្រឈមនៃការបណ្តុះបណ្តាលនិងវិក្រឹតការ និង វិធានការដោះស្រាយ

ទោះបីជាការអនុវត្តសកម្មភាពបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាព កន្លងមក បានទទួលជោគជ័យគួរឱ្យកត់សម្គាល់ដូចខាងលើក៏ដោយ ក៏ប៉ុន្តែសម្រាប់រយៈពេលចុងក្រោយនេះ ពិសេស ក្រោយពេលជំនួយបច្ចេកទេសសម្រាប់ការងារបណ្តុះបណ្តាលត្រូវបានបញ្ចប់ ដំណើរការការងារនេះ បានជួបបញ្ហាប្រឈមជាបន្តបន្ទាប់លើផ្នែកថវិកា និង ធនធានសម្រាប់គាំទ្រសកម្មភាពអនុវត្តន៍ ដែលធ្វើឱ្យយើងមិនអាចឆ្លើយតបបានគ្រប់គ្រាន់ និង ទាន់ពេលវេលាទៅនឹងតម្រូវការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ។ ប្រការនេះ ធ្វើឱ្យមានកម្មវិធីបណ្តុះបណ្តាលភាគច្រើន ត្រូវបានធ្វើឡើងក្នុងទម្រង់ជាសិក្ខាសាលា និងវគ្គសិក្សាខ្លីៗ ចាប់ពីឆ្នាំ ២០០៤ និងជាបន្តបន្ទាប់មក និងត្រូវបានអនុវត្តដោយតួអង្គផ្សេងៗគ្នា ដែលមិនមែនជាស្ថាប័នទទួលបន្ទុកការងារបណ្តុះបណ្តាលនិងកសាងសមត្ថភាព ពិសេស គឺចាប់ពីដំណាក់កាលទី ២ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ការណ៍នេះធ្វើឱ្យការបណ្តុះបណ្តាលនិងកសាងសមត្ថភាពមន្ត្រីរាជការ រប៉ាត់រប៉ាយ លែងមានលក្ខណៈប្រមូលផ្តុំជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ ដែលធ្វើឱ្យមានសម្ពាធដល់ការគ្រប់គ្រងសម្របសម្រួល ការចំណាយថវិកា និងចោទជាមន្ទិលចំពោះគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល ។

ទន្ទឹមនេះ ក្នុងក្របខណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ គិតត្រឹមឆ្នាំ ២០១៨ ការអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បងនឹងត្រូវគ្របដណ្តប់ដល់គ្រប់ក្រសួងស្ថាប័ន រួមនឹងមន្ទីរ អង្គភាពជំនាញក្រោមឱវាទ ដែលធ្វើឱ្យមានអង្គភាពថវិកាកើនឡើងរហូតដល់ **៨៨៤** អង្គភាព[5] ។ ក្នុងនោះ អង្គភាពថវិកាដែលត្រូវបង្កើតថ្មីរបស់ក្រសួងស្ថាប័ន

[5] *ចំនួនអង្គភាពថវិកាសរុប ៨៨៤ នៅត្រឹមឆ្នាំ២០១៨ នេះ គឺផ្អែកតាមទិន្នន័យផ្លូវការរបស់អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ប៉ុន្តែតួលេខជាក់ស្តែងអាចនឹងលើសពីនេះ ពិសេស ព្រោះមានក្រសួងស្ថាប័នមួយចំនួន ដែលបានចូលរួមអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បងនៅឆ្នាំ ២០១៥, ២០១៦ និងឆ្នាំ២០១៧ អាចនឹងបង្កើតអង្គភាពថវិការបស់ខ្លួនថែមទៀត ។ ហេតុនេះ យើងចាំបាច់ត្រូវមានការពិនិត្យវាយតម្លៃតម្រូវការបណ្តុះបណ្តាលជារៀងរាល់ឆ្នាំ ទើបអាចធានាភាពប្រាកដប្រជាបាន ។*

**១១** ដែលទើបចូលរួមអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បងនៅឆ្នាំ ២០១៧ និង ក្រសួង ស្ថាប័នធំៗ៣ ដែលនឹងត្រូវចូលរួមនៅឆ្នាំ ២០១៨ មានតម្រូវការអាទិភាព ក្នុងការបណ្តុះបណ្តាលនិងវិក្រឹតការ ដែលធ្វើឱ្យតម្រូវការបណ្តុះបណ្តាលនិងកសាងសមត្ថភាពមានការកើនឡើងខ្លាំង ។ លើសពីនេះ ផ្អែកតាមបទពិសោធន៍ នៃការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅឆ្នាំ ២០១៥ និង ២០១៦ បង្ហាញច្បាស់ថា មានអង្គភាពថវិកាមួយចំនួនអនុវត្តបានល្អ ទាំងប្រសិទ្ធភាព តម្លាភាព សង្គតិភាព និងភាពទាន់ពេលវេលា ក្នុងខណៈដែលមានអង្គភាពថវិកាខ្លះទៀត នៅជួបបញ្ហាប្រឈមដោយអន្លើ ។ បញ្ហាប្រឈមទាំងនោះ គឺពាក់ព័ន្ធទៅនឹងចំណេះដឹង និងសមត្ថភាពរបស់មន្ត្រីរាជការនៃអង្គភាពថវិកានីមួយៗ នោះ ។

ហេតុផលទាំងអស់នេះ បញ្ជាក់ថា សម្រាប់ជាវិធានការដោះស្រាយនៅពេលខាងមុខ យើងចាំបាច់ត្រូវកសាងប្រព័ន្ធបណ្តុះបណ្តាល និងវិក្រឹតការ ដែលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយឡើងវិញ ដើម្បីឱ្យការបណ្តុះបណ្តាលនិងអភិវឌ្ឍសមត្ថភាព ទទួលបានជោគជ័យ ប្រកបដោយប្រសិទ្ធភាព និង គុណភាព ពោលគឺធ្វើឱ្យមន្ត្រីរាជការគោលដៅមានចំណេះដឹង ជំនាញវិជ្ជាជីវៈ និង គុណវុឌ្ឍិគ្រប់គ្រាន់ សម្រាប់ចូលរួមអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចបានជោគជ័យដោយប្រសិទ្ធភាពនិងចីរភាព ។ កិច្ចការនេះ ត្រូវបានចង្អុលបង្ហាញនិងណែនាំដោយផ្ទាល់ពីឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងកិច្ចប្រជុំត្រួតពិនិត្យការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំឆ្នាំ ២០១៦ ព្រមទាំងទទួលនូវការគាំទ្រពីបណ្តាដៃគូអភិវឌ្ឍន៍ និងក្រសួងស្ថាប័នពាក់ព័ន្ធថែមទៀត ។

ក្នុងស្មារតីនេះ ផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ នេះ មានតួនាទីជាស្នូលដ៏សំខាន់ សម្រាប់កសាងប្រព័ន្ធបណ្តុះបណ្តាលនិងវិក្រឹតការលើជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ នៅកម្ពុជា ឱ្យមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ ដើម្បីធានាគុណភាព និងប្រសិទ្ធភាព នៃការបណ្តុះបណ្តាលនិងវិក្រឹតការ សំដៅលើកកម្ពស់សមត្ថភាព និងការយល់ដឹងជូនសិក្ខាកាមគោលដៅ សម្រាប់ចូលរួមចំណែកអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសការអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បង និង ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ឱ្យសម្រេចបានជោគជ័យប្រកបដោយប្រសិទ្ធភាព និង ចីរភាព ។

## ២. ចក្ខុវិស័យ និង បេសកកម្ម

### ២.១. ចក្ខុវិស័យ

ផែនការយុទ្ធសាស្ត្រនេះ មានចក្ខុវិស័យដើម្បីបង្កើតប្រព័ន្ធបណ្តុះបណ្តាលដែលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ សំដៅធ្វើឱ្យសិក្ខាកាមគោលដៅមានចំណេះដឹង ជំនាញវិជ្ជាជីវៈ និងសមត្ថភាពគ្រប់គ្រាន់ សម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ។

### ២.២. បេសកកម្ម

ដើម្បីសម្រេចចក្ខុវិស័យខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការលើការងារកសាងសមត្ថភាព មានបេសកកម្មអនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការជាប្រចាំលើជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនសិក្ខាកាមគោលដៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយត្រូវផ្តោតលើសកម្មភាពសំខាន់ៗ ដូចតទៅ:

- អនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាព ប្រកបដោយគុណភាព លើមុខជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- សិក្សាស្រាវជ្រាវ និង ប្រមូលធាតុចូលស្តីពីការអនុវត្តគោលនយោបាយ និង កម្មវិធីពាក់ព័ន្ធការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ សម្រាប់ពង្រឹង និងកែលម្អកម្មវិធី និងការអនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាព
- គ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធទិន្នន័យបច្ចេកវិទ្យាព័ត៌មាន សម្រាប់គាំទ្រការបណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាពប្រកបដោយគុណភាព
- កំណត់តម្រូវការ និង វាយតម្លៃគុណភាព និងប្រសិទ្ធភាព នៃការបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាពមន្ត្រីរាជការ
- វាយតម្លៃកម្រិតចំណេះដឹងមូលដ្ឋាន និង សមត្ថភាពជំនាញពាក់ព័ន្ធរបស់សិក្ខាកាម និង កំណត់វិធីសាស្ត្រនិងបច្ចេកទេសសមស្រប មុននឹងអនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការ
- ផ្តួចផ្តើម សម្របសម្រួល និងជំរុញកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នស្រាវជ្រាវ និងគ្រឹះស្ថានបណ្តុះបណ្តាលជាតិនិងអន្តរជាតិ ដើម្បីធ្វើទំនើបកម្មកម្មវិធីស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាព
- បោះពុម្ព និង ផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវ និង ឯកសារសិក្សាសំខាន់ៗ ពាក់ព័ន្ធនឹងបញ្ហាសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគាំទ្រការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាពមន្ត្រីរាជការ និង សាធារណជន
- រៀបចំ និងសម្របសម្រួលការផ្ទេរនិងចែករំលែកចំណេះដឹង ជំនាញ និងឧត្តមានុវត្តន៍ពីទីប្រឹក្សា និងអ្នកជំនាញការទាំងក្នុងស្រុក និងអន្តរជាតិ ជូនដល់មន្ត្រីរាជការ គ្រូបង្គោល គ្រូឧទ្ទេស និងសាស្ត្រាចារ្យ
- ជ្រើសរើស និងរៀបចំគ្រូបង្គោល ឬគ្រូឧទ្ទេស សម្រាប់អនុវត្តការងារស្រាវជ្រាវ បណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាពមន្ត្រីរាជការ និងវាយតម្លៃសមិទ្ធផល និងស្នាដៃដែលសម្រេចបាន សម្រាប់ផ្តល់ការលើកទឹកចិត្ត ។

## ៣. គោលបំណង គោលដៅ និង លទ្ធផលរំពឹងទុក

### ៣.១. គោលបំណង

ផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាពនេះ មានគោលបំណងដើម្បីតម្រង់ទិសការរៀបចំផែនការនិងកម្មវិធីលម្អិតសម្រាប់អនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការ ដែលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ ប្រកបដោយគុណភាព ប្រសិទ្ធភាព និង មានលក្ខណៈវិជ្ជាជីវៈស៊ីជម្រៅ ឆ្លើយតបទៅនឹងតម្រូវការនៃការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ ប្រកបដោយប្រសិទ្ធភាព និង ចីរភាព ។

### ៣.២. គោលដៅ

ផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាពនេះ មានគោលដៅតម្រង់ទិសការអនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការ ដែលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ ដើម្បីធានាគុណភាព ប្រសិទ្ធភាព និងមានលក្ខណៈវិជ្ជាជីវៈស៊ីជម្រៅ សម្រាប់អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងដំណាក់កាលទី ៣ ដោយមានកិច្ចសហការជិតស្និទ្ធ រវាងស្ថាប័នទទួលបន្ទុកបណ្តុះបណ្តាល ជាមួយនឹងគ្រប់អគ្គលេខាធិការដ្ឋាន/អគ្គនាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់ក្រសួង ស្ថាប័ន និង គ្រប់ដៃគូពាក់ព័ន្ធជាតិ និង អន្តរជាតិ ។

### ៣.៣. លទ្ធផលរំពឹងទុក

ផ្អែកតាមចក្ខុវិស័យ បេសកកម្ម គោលបំណង និង គោលដៅខាងលើ ផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាពនេះ នឹងធ្វើឱ្យយើងសម្រេចបាននូវលទ្ធផលរំពឹងទុកសំខាន់ៗដូចខាងក្រោមៈ

- ប្រព័ន្ធបណ្តុះបណ្តាលនិងវិក្រឹតការ ដែលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ ត្រូវបានរៀបចំ និងអនុវត្ត សំដៅកសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការលើជំនាញ សម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ការអនុវត្តប្រព័ន្ធបច្ចេកវិជ្ជាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- មន្ត្រីរាជការគោលដៅ នឹងទទួលបានការបណ្តុះបណ្តាលនិងវិក្រឹតការ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងមានលក្ខណៈវិជ្ជាជីវៈស៊ីជម្រៅ លើមុខជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្លើយតបទៅនឹងតម្រូវការនៃការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និងចីរភាព
- សមត្ថភាព និង ចំនួនគ្រូបង្គោល គ្រូឧទ្ទេស មន្ត្រីបច្ចេកទេស និង មន្ត្រីសម្របសម្រួល ត្រូវបានពង្រឹង និង ពង្រីកបានគ្រប់គ្រាន់ សម្រាប់អនុវត្តការងារស្រាវជ្រាវ បណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាពមន្ត្រីរាជការ និងសម្រាប់ការវាយតម្លៃតម្រូវការ ប្រសិទ្ធភាព សមិទ្ធកម្ម និង ស្នាដៃសម្រេចបាន
- ហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈបរិក្ខារ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យបច្ចេកវិទ្យាព័ត៌មានរបស់ស្ថាប័នទទួលបន្ទុកការបណ្តុះបណ្តាលនិងវិក្រឹតការ ត្រូវបានធ្វើទំនើបកម្ម ស្របតាមសេចក្តីត្រូវការ និងបទដ្ឋានអន្តរជាតិ
- តម្រូវការនៃការស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការ ត្រូវបានសិក្សាវាយតម្លៃ និងកំណត់ច្បាស់លាស់ សម្រាប់ការរៀបចំផែនការ និងកម្មវិធីលម្អិតដើម្បីអនុវត្តឱ្យបានទាន់ពេលវេលា និង មានប្រសិទ្ធភាព
- កម្រិតចំណេះដឹងមូលដ្ឋាន និងសមត្ថភាពជំនាញពាក់ព័ន្ធរបស់សិក្ខាកាម និង វិធីសាស្ត្រនិងបច្ចេកទេសបណ្តុះបណ្តាល ត្រូវបានវាយតម្លៃ និងកំណត់ច្បាស់លាស់ មុននឹងអនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការ
- កម្មវិធីស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការ, មុខជំនាញ, ប្រធានបទ និងឯកសារសម្រាប់ការបណ្តុះបណ្តាលនិងវិក្រឹតការ ត្រូវបានកែលម្អនិងធ្វើទំនើបកម្ម ឆ្លើយតបទៅនឹងតម្រូវការនៃការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ប្រកបដោយប្រសិទ្ធភាព និង ចីរភាព
- លទ្ធផលនៃការបណ្តុះបណ្តាលនិងវិក្រឹតការ ត្រូវបានពិនិត្យនិងវាយតម្លៃ ដើម្បីធានាអំពីគុណភាព ប្រសិទ្ធភាព និងឆ្លើយតបទៅនឹងតម្រូវការនៃការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- កិច្ចសហការ និងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន និង ដៃគូពាក់ព័ន្ធជាតិ និងអន្តរជាតិ ក្នុងការអនុវត្តកម្មវិធីស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការ និងការចែករំលែកព័ត៌មាន ចំណេះដឹង បទពិសោធន៍ និងឧត្តមានុវត្តន៍ ត្រូវបានពង្រឹងនិងពង្រីក
- លទ្ធផលនៃការស្រាវជ្រាវ និងឯកសារសិក្សាសំខាន់ៗ ពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដើម្បីគាំទ្រការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាពមន្ត្រីរាជការ ត្រូវបានចងក្រង បោះពុម្ព និងផ្សព្វផ្សាយ ។

## ៤. ក្របខណ្ឌយុទ្ធសាស្ត្រនៃការបណ្តុះបណ្តាលនិងអភិវឌ្ឍសមត្ថភាព

ផ្អែកតាមឧត្តមានុវត្តន៍អន្តរជាតិ ការបណ្តុះបណ្តាលនិងអភិវឌ្ឍសមត្ថភាពត្រូវការនូវការគាំទ្រ ការចូលរួម និង កិច្ចសហការពីតួអង្គស្ថាប័នពាក់ព័ន្ធសំខាន់ៗរួមមាន ***ស្ថាប័នផ្តល់សេវាបណ្តុះបណ្តាល, ស្ថាប័នទទួលសេវាបណ្តុះបណ្តាល និងស្ថាប័នគាំទ្រការបណ្តុះបណ្តាល*** ។ តួអង្គផ្តល់សេវាបណ្តុះបណ្តាល ត្រូវមានការទទួលស្គាល់ មានជំនាញឯកទេស មានបទពិសោធន៍ និងគុណវុឌ្ឍិត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ដែលរួមមាន សាស្ត្រាចារ្យ គ្រូបង្គោល គ្រូឧទ្ទេស កម្មវិធីសិក្សាវិធីសាស្ត្រ សម្ភារឧបទេស សម្ភារបរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រនិងទ្រទ្រង់រឹងមាំ និងមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ។

តួអង្គទទួលសេវាបណ្តុះបណ្តាល ត្រូវសហការក្នុងការផ្តល់ព័ត៌មាន ទិន្នន័យពាក់ព័ន្ធ សម្រាប់វាយតម្លៃដើម្បីកំណត់តម្រូវការបណ្តុះបណ្តាល ប្រធានបទ មុខវិជ្ជា សិក្ខាកាមគោលដៅ និង កំណត់វិធីសាស្ត្រនៃការបណ្តុះបណ្តាល និង ត្រូវចាត់បញ្ជូនមន្ត្រីចូលរួមជាសិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាល ឱ្យត្រូវតាមលក្ខខណ្ឌ និង សំណូមពរនៃវគ្គសិក្សា ហើយផ្តល់ឱកាសឱ្យសិក្ខាកាមបានប្រើប្រាស់ចំណេះដឹងនិងជំនាញ សម្រាប់អនុវត្តមុខងារ ភារកិច្ច នៅក្នុងអង្គភាពការងារជាក់ស្តែង ក្រោយពីបញ្ចប់វគ្គសិក្សា ព្រមទាំងសហការផ្តល់ព័ត៌មានត្រឡប់ទៅសាលា ឬ ស្ថាប័នផ្តល់សេវាបណ្តុះបណ្តាលវិញ អំពីប្រសិទ្ធភាព និងលទ្ធផលនៃការអនុវត្តការងាររបស់មន្ត្រីជាសិក្ខាកាមទាំងនោះ ។

តួអង្គដែលជាស្ថាប័នគាំទ្រ សំដៅស្ថាប័នដែលមិនផ្តល់ឬទទួលសេវាបណ្តុះបណ្តាល ប៉ុន្តែអាចមានអត្ថប្រយោជន៍ឬបេសកកម្មពាក់ព័ន្ធ ដែលនៅពេលនេះ គឺសំដៅដៃគូអភិវឌ្ឍន៍ ។ តួអង្គនេះ ត្រូវផ្តល់កិច្ចសហការគាំទ្រទាំងស្មារតី បច្ចេកទេស ហិរញ្ញវត្ថុ និងការប្រឹក្សាយោបល់ ព្រោះថា អន្តរកម្មនៃការចាប់យកចំណេះដឹង ត្រូវផ្សារភ្ជាប់នូវទស្សនាទានជាមួយនឹងការអនុវត្តទាំងនៅក្នុងថ្នាក់រៀន ថ្នាលពិសោធន៍ និងនៅក្នុងការដ្ឋានការងារ ។ លើសពីនោះ តួអង្គគាំទ្រអាចចូលរួមផ្តល់យោបល់លើកម្មវិធីវិធីសាស្ត្រ និងចែករំលែកបទពិសោធន៍ ដោយផ្ទាល់ឬប្រយោលដល់តួអង្គផ្តល់សេវាបណ្តុះបណ្តាល និង សិក្ខាកាម ដើម្បីឱ្យដំណើរការបណ្តុះបណ្តាលនិងអភិវឌ្ឍសមត្ថភាពអាចប្រព្រឹត្តទៅបានដោយរលូន និង មានប្រសិទ្ធភាព ។

ក្នុងទិដ្ឋភាពបច្ចេកទេស ការរៀបចំកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ អនុលោមតាមស្មារតីនៃផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ នេះ នឹងត្រូវចែកចេញជាបីប្រភេទ ដូចខាងក្រោម:

**(១).កម្មវិធីបណ្តុះបណ្តាលរយៈពេលវែង:** ជាកម្មវិធីសិក្សាកម្រិតសញ្ញាបត្រ ដែលអាចមានរយៈពេលពី ៦ ខែដល់ ២ ឆ្នាំ (បរិញ្ញាបត្រជាន់ខ្ពស់ ឬ សញ្ញាបត្រជាន់ខ្ពស់) សម្រាប់ពង្រឹងពង្រីកសមត្ថភាពជូនថ្នាក់ដឹកនាំកម្រិតជំនាញ និង មន្ត្រីជំនាញ ដែលមានសក្តានុពលល្អលាស់ សម្រាប់ទ្រទ្រង់ការងារកែទម្រង់ និង ទើបទទួលបានការតែងតាំង ប្រគល់ភារកិច្ច ឬត្រៀមទទួលការតែងតាំងប្រគល់ភារកិច្ចពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ។ កម្មវិធីសិក្សានេះនឹងប្រព្រឹត្តទៅក្នុងទម្រង់ជាវគ្គសិក្សាជាស៊េរីពេញម៉ោង ឬក្រៅម៉ោងចាប់បង្ខំ (Intensive Courses) និង វគ្គអាហារូបករណ៍ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមួយនឹងដៃគូសហប្រតិបត្តិការជាតិ-អន្តរជាតិ ។

**(២).កម្មវិធីបណ្តុះបណ្តាលរយៈពេលមធ្យម:** ជាកម្មវិធីសិក្សាកម្រិតវិញ្ញាបនបត្រ ដែលមានរយៈពេលពី ១ ខែដល់ ៦ ខែ សម្រាប់តម្រង់ទិស និង ហ្វឹកហាត់ជំនាញពាក់ព័ន្ធការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ជូនដល់មន្ត្រីជំនាញពិសេស សម្រាប់មន្ត្រីវ័យក្មេងដែលទើបជ្រើសរើសថ្មី និង មន្ត្រីដែលទទួលការផ្លាស់ប្តូរភារកិច្ចថ្មី ដោយសារស្ថានភាពចាំបាច់នៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ កម្មវិធីសិក្សានេះ នឹងប្រព្រឹត្តទៅក្នុងទម្រង់ជាវគ្គសិក្សាបច្ចេកទេសពេញម៉ោង ឬក្រៅម៉ោងចាប់បង្ខំ (Intensive Courses) នៅក្នុងស្រុក និងក្រៅប្រទេស ។

**(៣). កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី:** ជាកម្មវិធីសិក្សាកម្រិតវិក្រឹតការនិងសុក្រឹតការចំណេះដឹង និង ព័ត៌មានពាក់ព័ន្ធនឹងបទប្បញ្ញត្តិ លិខិតបទដ្ឋាន និង គោលការណ៍ណែនាំផ្សេងៗ សម្រាប់អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ កម្មវិធីសិក្សានេះ មានរយៈពេលក្រោម ១ ខែ និង ប្រព្រឹត្តទៅក្នុងទម្រង់ជាកម្មសិក្ខាសាលា, សិក្ខាសាលាផ្សព្វផ្សាយ រួមនឹងទស្សនកិច្ចសិក្សាសំខាន់ៗ នៅក្នុងស្រុក និងក្រៅប្រទេស ។

កម្មវិធីសិក្សាទាំង ៣ ប្រភេទខាងលើ នឹងត្រូវរៀបចំឡើងដោយផ្អែកលើការសិក្សា វិភាគ និងវាយតម្លៃតម្រូវការជាក់ស្តែងរបស់អង្គភាពថវិកា ដើម្បីធានាគុណភាព ប្រសិទ្ធភាព និង មានវិជ្ជាជីវៈច្បាស់លាស់ ព្រមទាំងមានការផ្តល់សញ្ញាបត្រ ឬ ផ្តល់វិញ្ញាបនបត្របញ្ជាក់សមត្ថភាពនៃការសិក្សាជូនសិក្ខាកាម ដែលត្រូវបានវាយតម្លៃថាទទួលជោគជ័យក្នុងការសិក្សា ។

***ហេតុនេះ ក្របខណ្ឌយុទ្ធសាស្ត្រនៃការបណ្តុះបណ្តាលនិងអភិវឌ្ឍសមត្ថភាព សម្រាប់ដំណាក់កាលទី៣ នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ <u>គឺត្រូវបន្តជំរុញការអភិវឌ្ឍជំនាញ និង ការពង្រីកវិសាលភាពនៃវិធីសាស្ត្រអភិវឌ្ឍសមត្ថភាពតាមអភិក្រមជាយុទ្ធសាស្ត្រៈ (១). ការអភិវឌ្ឍសមត្ថភាពស្ថាប័ន, (២). ការស្រាវជ្រាវ អភិវឌ្ឍ និងពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការ និង (៣). ការអនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការ ដែលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ រួមនឹងការវាយតម្លៃប្រសិទ្ធភាពនិងគុណភាព ផ្សារភ្ជាប់ទៅនឹងតម្រូវការអនុវត្តមុខងារ ភារកិច្ចរបស់សិក្ខាកាមគោលដៅរបស់អង្គភាពថវិកា</u> ។***

## ៤.១. ការវិភាគតម្រូវការបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាព

ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុដំណាក់កាលទី ១ និង ទី ២ ត្រូវបានបញ្ចប់ដោយជោគជ័យ ពោលគឺសម្រេចបាននូវគោលដៅ ***"កសាងបានភាពជឿទុកចិត្តនៃថវិកា និង គណនេយ្យភាពហិរញ្ញវត្ថុ"*** ។ ទន្ទឹមនេះ ការកសាងនិងអភិវឌ្ឍសមត្ថភាព ត្រូវបានវាយតម្លៃថា បានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការគាំទ្រការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចបានជោគជ័យខាងលើនេះ ។ ទោះបីជាយ៉ាងណា ការអនុវត្តសកម្មភាពពាក់ព័ន្ធការកសាងនិងអភិវឌ្ឍសមត្ថភាពនេះ ត្រូវបានទទួលស្គាល់ថា នៅមិនទាន់ពេញលេញ ។

ការបណ្តុះបណ្តាលនិងវិក្រឹតការដ៏ត្រឹមត្រូវលើជំនាញមូលដ្ឋាន និង ជំនាញបច្ចេកទេសជាក់លាក់មួយចំនួនត្រូវបានអនុវត្តជូនមន្ត្រីរាជការគោលដៅ ប៉ុន្តែប្រធានបទលើវិស័យជាក់លាក់មួយចំនួនដែលបានគ្រោងនៅក្នុងផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនោះ ត្រូវទាមទារឱ្យមានការសម្រួចបន្ថែមទៀត ។ ទន្ទឹមនោះ ការពង្រីកវិសាលភាពអភិវឌ្ឍសមត្ថភាពក៏ត្រូវបានអនុវត្តត្រឹមតែការផ្តល់នូវការលើកទឹកចិត្តតាមប្រព័ន្ធលើកទឹកចិត្ត (MBPI) និង កញ្ចប់លើកទឹកចិត្ត (POC) ឯកិច្ចការដទៃទៀត ដូចជាការអភិវឌ្ឍសមត្ថភាពស្ថាប័ន និង ការអភិវឌ្ឍតាមរយៈការប្រើប្រាស់អ្នកជំនាញការបច្ចេកទេសជាដើម នៅមិនទាន់មានសកម្មភាពដែលគួរឱ្យកត់សម្គាល់នៅឡើយ ។ ដូច្នេះយើងចាំបាច់ត្រូវពិនិត្យអំពីតម្រូវការបណ្តុះបណ្តាលសម្រាប់ដំណាក់កាលទី៣ នេះ ឡើងវិញ ដើម្បីដាក់ចេញនូវយុទ្ធសាស្ត្រ និង ផែនការសកម្មភាពឆ្លើយតបឱ្យបានសមស្រប ។

ក្នុងការសិក្សាវិភាគ និងវាយតម្លៃតម្រូវការ គឺយើងផ្តោតទៅលើតម្រូវការតាមទិន្នន័យជាក់ស្តែងនៃអង្គភាពថវិកា ដែលមានតម្រូវការការបណ្តុះបណ្តាលជូនមន្ត្រីជំនាញរបស់ខ្លួនទៅលើមុខជំនាញជាក់លាក់ និង មុខជំនាញមូលដ្ឋាន ដែលផ្សារភ្ជាប់ទៅគោលដៅនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅដំណាក់កាលទី៣ ដើម្បីកំណត់ឱ្យឃើញនូវគម្លាតសម្រាប់ការបណ្តុះបណ្តាល និងកសាងសមត្ថភាពជូនមន្ត្រីគោលដៅ នៃអង្គភាពថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងស្ថាប័នពាក់ព័ន្ធ ។ ដើម្បីកំណត់ឱ្យបានត្រឹមត្រូវ និងជាក់លាក់អំពីតម្រូវការនៃការបណ្តុះបណ្តាល យើងបានអភិវឌ្ឍកម្រងសំណួរ ដែលផ្តោតទៅលើគោលការណ៍នៃតម្រូវការអភិវឌ្ឍជំនាញ និង ការពង្រីកវិសាលភាពអភិវឌ្ឍសមត្ថភាព ដែលទទួលបានតាមរយៈការចូលរួមវគ្គបណ្តុះបណ្តាល និងធ្វើការជ្រើសរើសនូវជំនាញអាទិភាព សម្រាប់ធ្វើការពង្រីក ឬអភិវឌ្ឍជំនាញ

បច្ចេកទេសជាក់លាក់បន្ថែមទៀត ។ ទន្ទឹមនេះ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយនឹងគ្រប់អគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា ដើម្បីប្រមូលធាតុចូលអំពីតម្រូវការបណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាពជាក់ស្តែងតាមសាមីអង្គភាព រួមជាមួយនឹងការប្រើប្រាស់បណ្តាញទំនាក់ទំនងតេឡេក្រាមក្នុងប្រមូល និងផ្ទៀងផ្ទាត់ព័ត៌មានអំពីតម្រូវការបណ្តុះបណ្តាល ជាមួយជនបង្គោលរបស់ក្រសួងស្ថាប័ន ។ តាមរយៈនេះ យើងអាចប្រមូលបាននូវធាតុចូលគ្រប់ជ្រុងជ្រោយបន្ថែមពីគ្រប់ស្ថាប័ន អង្គភាពពាក់ព័ន្ធអំពីតម្រូវការបណ្តុះបណ្តាលជាក់ស្តែងទាំងជំនាញអាទិភាព និងបរិមាណ ។

ផ្អែកតាមលទ្ធផលនៃការវិភាគ និង វាយតម្លៃរបស់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អំពីតម្រូវការក្នុងការកសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័ន លើមុខជំនាញពាក់ព័ន្ធសម្រាប់អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ ឆ្នាំ (២០១៧-២០២០)[6] បញ្ជាក់ថាកម្ពុជាមានសេចក្តីត្រូវការខ្ពស់ក្នុងការបណ្តុះបណ្តាលនិងវិក្រឹតការចំណេះដឹង និង សមត្ថភាពទេពកោសល្យជូនមន្ត្រីរាជការ ។ ជាក់ស្តែងគិតត្រឹមឆ្នាំ២០១៧ មានក្រសួងស្ថាប័នចំនួន **៣៦** រួមនឹងមន្ទីរ អង្គភាពជំនាញក្រោមឱវាទ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បង ។ ហើយនៅឆ្នាំ២០១៨ មានក្រសួង ស្ថាប័នធំៗ ៣ ទៀតគឺក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងទីស្តីការគណៈរដ្ឋមន្ត្រី រួមនឹងមន្ទីរ អង្គភាពជំនាញក្រោមឱវាទពាក់ព័ន្ធនឹងត្រូវចូលរួមអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បងថែមទៀត ដែលធ្វើឱ្យអង្គភាពថវិកាសរុបទូទាំងប្រទេសមានចំនួន **៨៨៤** *(ឧបសម្ព័ន្ធ ៦)* ។ ក្នុងនោះ ***មន្ត្រីគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុ ដែលជា ក្រុមការងារថវិកា, ក្រុមលទ្ធកម្ម, មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ, រដ្ឋទេយ្យករបុរេប្រទាន, រដ្ឋទេយ្យករបុរេប្រទានរង, ភ្នាក់ងារបើកផ្តល់ និង ភ្នាក់ងារបើកផ្តល់ជំនួស*** នៃអង្គភាពថវិកាចំនួន **២២១** ដែលទើបបង្កើតថ្មីរបស់ក្រសួងស្ថាប័នទើបចូលរួមអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បងនៅឆ្នាំ ២០១៧ និង **៤៧** អង្គភាពថវិការបស់ក្រសួងធំៗទាំង ៣ គឺមានតម្រូវការអាទិភាពបន្ទាន់ ក្នុងការបណ្តុះបណ្តាលនិងកសាងសមត្ថភាព ។

លើសពីនេះ មន្ត្រីទទួលកិច្ចការហិរញ្ញវត្ថុ របស់គ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ៣០ អង្គភាពទៀត *(ឧបសម្ព័ន្ធ ៥)* ក៏មានតម្រូវការក្នុងការបណ្តុះបណ្តាលលើមុខជំនាញសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែរ ព្រោះអង្គភាពទាំងនោះក៏ត្រូវអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកា ក្នុងក្របខណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផងដែរ ។ ជាមួយនោះ មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គភាពថវិកា និងថ្នាក់ដឹកនាំកម្រិតជំនាញ នៃក្រសួង ស្ថាប័ន អនុវត្តថវិកាកម្មវិធីពេញលេញសាកល្បងនៅឆ្នាំ ២០១៥ និង ឆ្នាំ ២០១៦ ដែលទទួលបានការបណ្តុះបណ្តាលរួចហើយនៅពេលកន្លងមក ក៏នៅមានតម្រូវការក្នុងការធ្វើសុក្រឹតការចំណេះដឹង និងជំនាញថែមទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងការវិវឌ្ឍឈានឡើងនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅដំណាក់កាលទី៣ ជាពិសេស ការដាក់ចេញនូវបទប្បញ្ញត្តិ និងការណែនាំថ្មីៗ ដូចជាគោលការណ៍ណែនាំស្តីពីការរៀបចំ និង អនុវត្តថវិកាកម្មវិធីសម្រាប់រដ្ឋបាលហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ និងការដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជំហានទី២ ជាដើម ដែលត្រូវចាប់ផ្តើមក្នុងឆ្នាំ ២០១៧ ជាមួយក្រសួង ស្ថាប័នចំនួន ១០ ដោយចាប់ផ្តើមម្តង ៥ ក្រសួង ហើយនឹងត្រូវបន្តពង្រីកទៅដល់ក្រសួងស្ថាប័នទាំងអស់ផ្សេងទៀតជាបន្តបន្ទាប់ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ នៅពេលខាងមុខ ។

---

[6] *តាមពិតដំណាក់កាលទី៣ នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានរយៈពេល ៥ ឆ្នាំ (២០១៦-២០២០) ប៉ុន្តែ ដោយសារការពន្យារពេលទទួលការអនុម័ត ធ្វើឱ្យក្របខណ្ឌពេលវេលាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រនេះ ត្រូវប្តូរមកជា ២០១៧-២០២០ វិញ ។ ទោះជាយ៉ាងណាលទ្ធផលនៃការវាយតម្លៃជារួមនៅចុងឆ្នាំ ២០១៥ និង ការវាយតម្លៃការបណ្តុះបណ្តាលតាមវគ្គនីមួយៗ គឺជាមូលដ្ឋាន នៃការកំណត់តម្រូវការបណ្តុះបណ្តាលនេះ។*

ទឡ្ហីករណ៍ទាំងអស់ខាងលើ ឆ្លុះឱ្យឃើញនូវតម្រូវការដ៏ធំធេងចំពោះការបណ្តុះបណ្តាល និងកសាងសមត្ថភាព ពិសេស ក្រុមមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ដែលជាមន្ត្រីរាជការគោលដៅ នៃអង្គភាពថវិកា ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ សម្រាប់ចូលរួមអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងដំណាក់កាលទី ៣ ។ ក្នុងនោះ ការបណ្តុះបណ្តាលនិងវិក្រឹតការត្រូវផ្តោតទៅលើមុខជំនាញ ដូចជា ***ការប្រើប្រាស់កុំព្យូទ័រ, គណនេយ្យ, គណនេយ្យតាមកុំព្យូទ័រ, ថវិកា, លទ្ធកម្ម, ហិរញ្ញកិច្ច, សវនកម្មនិងអធិការកិច្ច, ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងការផ្លាស់ប្តូរ, ការវិភាគនិងគ្រប់គ្រងបំណុលសាធារណៈ, ការវិភាគនិងព្យាករណ៍សេដ្ឋកិច្ច, ការវិភាគនិងគ្រប់គ្រងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ, ការវិភាគនិងវាយតម្លៃគម្រោងវិនិយោគ ក្នុងភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន, ការវិភាគ វាយតម្លៃ បែងចែក ត្រួតពិនិត្យ និងតាមដានហានិភ័យពាក់ព័ន្ធនៃគម្រោងវិនិយោគតាមយន្តការនៃភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន*** ជាដើម ដែលចាំបាច់សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមនឹងមុខជំនាញពាក់ព័ន្ធផ្សេងៗទៀត ដែលជាសេចក្តីត្រូវការបន្ទាន់និងចំពោះមុខ សម្រាប់ក្រសួងស្ថាប័ន ក្នុងការងារអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បង និង អង្គភាពថវិកា ។

ទន្ទឹមនេះ ផ្អែកតាមលទ្ធផលនៃការវាយតម្លៃតម្រូវការបណ្តុះបណ្តាលបញ្ជាក់ថា ដើម្បីលើកកម្ពស់ការអភិវឌ្ឍជំនាញបច្ចេកទេសជូនមន្ត្រីរាជការគោលដៅ កម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាព នៅដំណាក់កាលទី៣ ត្រូវបន្តផ្តោតអាទិភាពទៅលើៈ ***មុខជំនាញឯកទេសមូលដ្ឋាន (Foundation Skills)*** និង ***មុខជំនាញឯកទេសជាក់លាក់ (Professional Skills)*** ។ ក្នុងនោះ មុខជំនាញឯកទេសមូលដ្ឋាន (Foundation Skills) គឺសម្រាប់បញ្ជ្រាបចំណេះដឹង និងពង្រីកការយល់ដឹងជាមូលដ្ឋានជូនថ្នាក់ដឹកនាំ និង មន្ត្រីជំនាញ អំពីខ្លឹមសារនិងសារសំខាន់ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេសអំពីការអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកា ដើម្បីជំរុញការគាំទ្រនិងលើកកម្ពស់ការចូលរួមអនុវត្ត ។ មុខជំនាញសំខាន់ៗទាំងនោះរួមមាន ***"ទស្សនាទាននៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក្របខណ្ឌនៃការត្រួតពិនិត្យចំណាយរយៈពេលមធ្យម (MTEF), ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច, ការវិនិយោគសាធារណៈ, ការគ្រប់គ្រងបំណុលសាធារណៈ, ទស្សនាទាននៃថវិកាកម្មវិធីនិងអង្គភាពថវិកា, ការវិភាគនិងព្យាករណ៍សេដ្ឋកិច្ច, ការវិភាគនិងគ្រប់គ្រងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ, ការវិភាគនិងវាយតម្លៃគម្រោងវិនិយោគ ក្នុងភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន និង ភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងការផ្លាស់ប្តូរ, ..."*** ជាដើម ។

ចំណែកមុខជំនាញឯកទេសជាក់លាក់ (Professional Skills) គឺជាមុខជំនាញឯកទេស ដែលចាំបាច់សម្រាប់អនុវត្តតួនាទី ភារកិច្ចស្នូលរបស់អង្គភាព ឬក្រសួង ស្ថាប័ន។ មុខជំនាញអាទិភាពរួមមាន ***"នីតិវិធីរៀបចំ និងអនុវត្តថវិកាកម្មវិធី, នីតិវិធីនិងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ; ការកត់ត្រាបញ្ជិកាគណនេយ្យសាធារណៈ; ការរៀបចំផែនការនិងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ; ការរៀបចំតារាងរដ្ឋទេយ្យបុរេប្រទាន, ការរៀបចំកិច្ចការនិយ័តកម្មថវិកា, ការរៀបចំតាមដាន និង ត្រួតពិនិត្យរបាយការណ៍ចលនាឥណទាន, ការរៀបចំ កត់ត្រា និងតាមដានកិច្ចបញ្ជិកាគណនេយ្យហិរញ្ញវត្ថុ, ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសាធារណៈ; ការគ្រប់គ្រងសន្និធិ និងទ្រព្យសម្បត្តិរដ្ឋ និងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ"*** ជាដើម ។ មុខជំនាញទាំងអស់នោះ គឺជាអាទិភាពចាំបាច់សម្រាប់រៀបចំជាកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការជូនមន្ត្រីរាជការគោលដៅ *ដែលជាក្រុមមន្ត្រីគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុ ដូចជា ក្រុមលទ្ធកម្ម, ក្រុមការងារថវិកា, រដ្ឋទេយ្យករបុរេប្រទាន, រដ្ឋទេយ្យករបុរេប្រទានរង, ភ្នាក់ងារបើកផ្តល់ និង ភ្នាក់ងារបើកផ្តល់ជំនួស* ស្របតាមតម្រូវការ សម្រាប់អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅដំណាក់កាលទី ៣ ។

**តារាងឧបសម្ព័ន្ធទី ២** នៃផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាពនេះ នឹងបង្ហាញពីមុខវិជ្ជាសរុបដែលជាសេចក្តីត្រូវការរបស់ក្រសួងស្ថាប័ន និង អង្គភាពពាក់ព័ន្ធ សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំកម្មវិធីលម្អិត នៃផែនការបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាពប្រចាំឆ្នាំ ជូនមន្ត្រីរាជការគោលដៅ ដើម្បីរួមចំណែកអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅដំណាក់កាលទី ៣ ឱ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ។ លើសពីនោះ ផ្អែកតាមបទពិសោធន៍ ក្នុងការអនុវត្តក្នុងពីរ

ដំណាក់កាលកន្លងមកបញ្ជាក់ថា យើងមានតម្រូវការចាំបាច់ក្នុងការអនុវត្តនូវការសិក្សាវិភាគ និងវាយតម្លៃតម្រូវការ បណ្តុះបណ្តាលជារៀងរាល់ឆ្នាំ ជាបន្តបន្ទាប់ថែមទៀត សម្រាប់រៀបចំផែនការលម្អិតនៃកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការប្រចាំឆ្នាំ និងធ្វើបច្ចុប្បន្នកម្មឯកសារ និង វិធីសាស្រ្តបណ្តុះបណ្តាលឱ្យបានសមស្របទៅតាមតម្រូវការ រចនាសម្ព័ន្ធអង្គភាព ស្ថានភាពមន្ត្រីរាជការគោលដៅ និង បរិបទការងារ ដែលអាចមានការប្រែប្រួលជាយថាហេតុនៅក្នុងបណ្តាឆ្នាំនីមួយៗ ។

ម្យ៉ាងវិញទៀត ក្នុងទិដ្ឋភាពអនុវត្ត ការអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បង និង ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាការងារថ្មី មាននីតិវិធីច្រើន និងស្ថិតក្នុងដំណាក់កាលរៀបចំផង រៀនសូត្រផង និងអនុវត្តផង ហេតុដូច្នេះ ធ្វើឱ្យតម្រូវការបណ្តុះបណ្តាលនិងអភិវឌ្ឍសមត្ថភាពនេះ មានទំហំធំធេងដែលត្រូវមានការយកចិត្តទុកដាក់ ការគាំទ្រ និងកិច្ចសហការពីគ្រប់តួអង្គភាពពាក់ព័ន្ធ ។ កង្វះថវិកានិងធនធានគាំទ្រ, ប្រព័ន្ធលើកទឹកចិត្តមិនទាន់គ្របដណ្តប់បានដល់គ្រប់ ក្រសួងស្ថាប័ន និង មន្ត្រីមួយចំនួនដែលទទួលបានការបណ្តុះបណ្តាលហើយ មិនបានយកចំណេះដឹងទៅប្រើប្រាស់ ធ្វើឱ្យការបណ្តុះបណ្តាលនិងវិក្រឹតការមួយចំនួនកន្លងមក មិនទាន់អាចប្រព្រឹត្តទៅបានតាមគម្រោង និង តាមលក្ខណៈបច្ចេកទេស ហើយកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ ភាគច្រើនត្រូវធ្វើឡើងក្នុងទម្រង់ជាសិក្ខាសាលា និង វគ្គសិក្សាខ្លីៗ ដែលមានសិក្ខាកាមចូលរួមក្នុងចំនួនច្រើន និង ត្រូវបានអនុវត្តដោយតួអង្គផ្សេងៗគ្នា ដែលខ្លះមិនមែនជាស្ថាប័នទទួលបន្ទុកការងារបណ្តុះបណ្តាលនិងកសាងសមត្ថភាព ។ ស្ថានភាពទាំងអស់នេះ ធ្វើឱ្យការអនុវត្តកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការកន្លងមក ពិសេស ចាប់ពីឆ្នាំ ២០០៨-២០០៩ មក រប៉ាត់រប៉ាយ លែងមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ ដែលធ្វើឱ្យមានសម្ពាធដល់ការគ្រប់គ្រងសម្របសម្រួល ការចំណាយថវិកា និងចោទឡើងជាមន្ទិលចំពោះគុណភាព និងប្រសិទ្ធភាព ។

*ហេតុផលទាំងអស់នេះ បញ្ជាក់ថា យើងចាំបាច់ត្រូវធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្រ្តកសាងនិងអភិវឌ្ឍសមត្ថភាព ដើម្បីធ្វើឱ្យប្រព័ន្ធបណ្តុះបណ្តាលនិងវិក្រឹតការ នៅពេលខាងមុខ មានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយឡើងវិញ ដែលនឹងធានាឱ្យការបណ្តុះបណ្តាលនិងអភិវឌ្ឍសមត្ថភាពទទួលបានជោគជ័យ ប្រកបដោយប្រសិទ្ធភាព និង គុណភាព សំដៅធ្វើឱ្យសិក្ខាកាមគោលដៅមានចំណេះដឹង ជំនាញវិជ្ជាជីវៈ និងគុណវុឌ្ឍិគ្រប់គ្រាន់ ឆ្លើយតបទៅនឹងតម្រូវការនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ក្នុងស្មារតីនេះ ផែនការយុទ្ធសាស្រ្តកសាងនិងអភិវឌ្ឍសមត្ថភាពនេះ មានតួនាទីជាស្នូលសម្រាប់តម្រង់ទិសជាយុទ្ធសាស្រ្តរយៈពេលមធ្យម (ឆ្នាំ២០១៧-២០២០) លើការរៀបចំ និង អនុវត្តផែនការនិងកម្មវិធីលម្អិត នៃការបណ្តុះបណ្តាលនិងវិក្រឹតការ ដោយផ្សារភ្ជាប់រវាងខ្សែសង្វាក់ មុខជំនាញ ប្រធានបទ ឯកសារ និង វិធីសាស្រ្តនៃការបណ្តុះបណ្តាលនិងវិក្រឹតការ ទៅនឹងតម្រូវការជាក់ស្តែងរបស់អង្គភាពថវិកា និងមុខងារភារកិច្ចរបស់មន្ត្រីរាជការ សំដៅធ្វើឱ្យសិក្ខាកាមគោលដៅមានចំណេះដឹង សមត្ថភាពវិជ្ជាជីវៈស៊ីជម្រៅ និង ទូលំទូលាយ សម្រាប់រួមចំណែកអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅដំណាក់កាលទី ៣ នេះឱ្យសម្រេចជោគជ័យប្រកបដោយប្រសិទ្ធភាព និងចីរភាព ។*

## ៤.២. កត្តាកំណត់ជោគជ័យ

កត្តាកំណត់ជោគជ័យក្នុងការអនុវត្តផែនការយុទ្ធសាស្រ្តស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការលើជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ រួមមានដូចខាងក្រោម:

(១). មានការយកចិត្តទុកដាក់ ការគាំទ្រនិងលើកទឹកចិត្តពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមរបៀបវារៈគោលនយោបាយជាអាទិភាព ដែលមានចែងនៅក្នុង **យុទ្ធសាស្រ្តចតុកោណ** ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ដើម្បីកំណើនការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា ។

(២). មានស្ថាប័នទទួលបន្ទុកច្បាស់លាស់ ជាសេនាធិការផ្ទាល់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារបណ្តុះបណ្តាលនិងវិក្រឹតការ ដែលមានរចនាសម្ព័ន្ធគ្រប់គ្រងនិងគុណវុឌ្ឍិរឹងមាំ, មានជំនាញពិតប្រាកដ និង មានបទពិសោធន៍គ្រប់គ្រាន់ ក្នុងការរៀបចំ និង អនុវត្តកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ ។

(៣). មានកិច្ចសហការជិតស្និទ្ធរវាងស្ថាប័នទទួលបន្ទុកការបណ្តុះបណ្តាលនិងវិក្រឹតការជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័ន និងមានទំនាក់ទំនងសហប្រតិបត្តិការទូលំទូលាយជាមួយស្ថាប័នដៃគូជាតិ-អន្តរជាតិ លើការងារស្រាវជ្រាវ បណ្តុះបណ្តាល និងវិក្រឹតការ ។

(៤). មានធនធានគ្រូបង្គោល និង គ្រូឧទ្ទេស ដែលមានចំណេះដឹង ជំនាញ បទពិសោធន៍ និង ឆន្ទៈក្នុងការងារស្រាវជ្រាវ បណ្តុះបណ្តាល និង ចែករំលែកចំណេះដឹង និងបទពិសោធន៍ជូនសិក្ខាកាម ។

(៥). មានប្រភពហិរញ្ញវត្ថុច្បាស់លាស់តាមរយៈ ថវិកាជាតិក្នុងក្របខណ្ឌថវិកាកម្មវិធី និងអង្គភាពថវិកា, ថវិកាគាំទ្រពីដៃគូអភិវឌ្ឍន៍ក្នុងក្របខណ្ឌកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ថវិកាដៃគូសហប្រតិបត្តិការជាតិ-អន្តរជាតិ ។

(៦). មានមន្ត្រីរាជការនិងបុគ្គលិក ដែលមានចំណេះដឹង ជំនាញ ទេពកោសល្យ បទពិសោធន៍ ឧបនិស្ស័យ និងឆន្ទៈមុតមាំលើការងារពាក់ព័ន្ធការកសាងនិងអភិវឌ្ឍសមត្ថភាព ។

## ៤.៣. ទិសដៅជាយុទ្ធសាស្ត្រ និង យុទ្ធសាស្ត្រ

ផ្អែកលើការវិភាគតម្រូវការបណ្តុះបណ្តាលនិងវិក្រឹតការ ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដាក់ចេញនូវទិសដៅជាយុទ្ធសាស្ត្រនៃការកសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការលើជំនាញ សម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ គឺសំដៅរៀបចំប្រព័ន្ធបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាព ដែលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ ដើម្បីលើកកម្ពស់សមត្ថភាព និងការយល់ដឹង ប្រកបដោយគុណភាព និង មានវិជ្ជាជីវៈស៊ីជម្រៅ ជូនដល់មន្ត្រីរាជការគោលដៅសម្រាប់រួមចំណែកអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេស ការអនុវត្តថវិកាកម្មវិធីពេញលេញ និង ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចបានជោគជ័យប្រកបដោយប្រសិទ្ធភាពនិងចីរភាព ។

ស្របតាមទិសដៅជាយុទ្ធសាស្ត្រខាងលើ ផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ ត្រូវឈរលើយុទ្ធសាស្ត្រសំខាន់ៗដែលរួមមានៈ ***ការអភិវឌ្ឍសមត្ថភាពស្ថាប័ន, ការពង្រឹងពង្រីកការស្រាវជ្រាវ និងអភិវឌ្ឍ តាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការ ដើម្បីធ្វើទំនើបកម្មកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ និង ការអនុវត្តកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការលើមុខជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*** ដែលខ្លឹមសារលម្អិតនៃយុទ្ធសាស្ត្រនីមួយៗ រួមមានដូចខាងក្រោមៈ

### ៤.៣.១.យុទ្ធសាស្ត្រទី ១: ការអភិវឌ្ឍសមត្ថភាពស្ថាប័ន

យុទ្ធសាស្ត្រទី១ គ្របដណ្តប់លើការអភិវឌ្ឍសមត្ថភាពស្ថាប័ន ដែលទទួលបន្ទុកការងារបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាពមន្ត្រីរាជការ ដោយផ្តោតទៅលើសកម្មភាពកសាងនិងអភិវឌ្ឍធនធានមនុស្ស ទាំងសមត្ថភាពនិងចំនួន និង ការធ្វើទំនើបកម្មនិងបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារបរិក្ខារ សម្រាប់គាំទ្រការស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការ ដើម្បីពង្រឹងពង្រីកសមត្ថភាពមន្ត្រីរាជការសម្រាប់គាំទ្រការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ យុទ្ធសាស្ត្រទី១ គឺផ្តោតលើសកម្មភាពជាយុទ្ធសាស្ត្រ និងចំណុចដៅសំខាន់ៗ ដូចខាងក្រោមៈ

១.១. ការពង្រឹងនិងបង្កើនធនធានមនុស្សសម្រាប់អនុវត្តការស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការ, និង

១.២. ការធ្វើទំនើបកម្ម និងបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារបរិក្ខារ សម្រាប់គាំទ្រការស្រាវជ្រាវបណ្តុះបណ្តាលនិងវិក្រឹតការ ដើម្បីពង្រឹងនិងពង្រីកសមត្ថភាពមន្ត្រីរាជការ ។

### ៤.៣.២. យុទ្ធសាស្ត្រទី ២: ការពង្រឹងពង្រីកការស្រាវជ្រាវនិងអភិវឌ្ឍ តាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការដើម្បីធ្វើទំនើបកម្មកម្មវិធីបណ្ដុះបណ្ដាលនិងវិក្រឹតការ ពាក់ព័ន្ធការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ

យុទ្ធសាស្ត្រទី២ គ្របដណ្ដប់លើការពង្រឹងពង្រីកការស្រាវជ្រាវ និងអភិវឌ្ឍ ដែលនឹងប្រព្រឹត្តទៅតាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការជាមួយអគ្គលេខាធិការដ្ឋាន/អគ្គនាយកដ្ឋាន ក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ ក្នុងគោលដៅដើម្បីវិភាគ វាយតម្លៃនិងកំណត់តម្រូវការនៃការបណ្ដុះបណ្ដាលនិងវិក្រឹតការ, ប្រមូលធាតុចូលសម្រាប់ការធ្វើទំនើបកម្មកម្មវិធី មុខជំនាញ ប្រធានបទ ឯកសារ និងវិធីសាស្ត្របណ្ដុះបណ្ដាលនិងវិក្រឹតការ សំដៅជំរុញនិងលើកកម្ពស់ការផ្តល់សេវាបណ្ដុះបណ្ដាលនិងវិក្រឹតការ ប្រកបដោយគុណភាព ប្រសិទ្ធភាព មានលក្ខណៈវិជ្ជាជីវៈ និងស៊ីជម្រៅ ឆ្លើយតបទៅនឹងតម្រូវការនៃការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព និងចីរភាព ។ យុទ្ធសាស្ត្រទី២ គឺផ្ដោតលើសកម្មភាពជាយុទ្ធសាស្ត្រ និងចំណុចដៅសំខាន់ៗ ដូចខាងក្រោម:

២.១. ការវាយតម្លៃតម្រូវការជាក់លាក់សម្រាប់ការស្រាវជ្រាវ បណ្ដុះបណ្ដាលនិងវិក្រឹតការសមត្ថភាពមន្ត្រីរាជការ

២.២. ការសិក្សាស្រាវជ្រាវនិងអភិវឌ្ឍកម្មវិធីមុខជំនាញ ប្រធានបទ ឯកសារ និងវិធីសាស្ត្របណ្ដុះបណ្ដាលនិងវិក្រឹតការ

២.៣. ការពង្រឹងនិងពង្រីកការស្រាវជ្រាវ បណ្ដុះបណ្ដាលនិងវិក្រឹតការ តាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការ ជាមួយស្ថាប័ន និង ដៃគូពាក់ព័ន្ធជាតិ-អន្តរជាតិ ។

### ៤.៣.៣. យុទ្ធសាស្ត្រទី ៣: ការបណ្ដុះបណ្ដាល និងវិក្រឹតការសមត្ថភាព

យុទ្ធសាស្ត្រទី៣ គ្របដណ្ដប់លើការវាយតម្លៃកម្រិតចំណេះដឹងមូលដ្ឋាន និងសមត្ថភាពជំនាញពាក់ព័ន្ធរបស់សិក្ខាកាម, ការកំណត់វិធីសាស្ត្រ និង បច្ចេកទេសក្នុងការបណ្ដុះបណ្ដាលនិងវិក្រឹតការ, ការអនុវត្តកម្មវិធី និងសកម្មភាពបណ្ដុះបណ្ដាលនិងវិក្រឹតការ ដែលមានលក្ខណៈប្រមូលផ្ដុំ ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ រួមនឹងការវាយតម្លៃគុណភាព ប្រសិទ្ធភាព នៃការបណ្ដុះបណ្ដាលនិងវិក្រឹតការ សំដៅធ្វើឱ្យសិក្ខាកាមគោលដៅមានចំណេះដឹង ជំនាញវិជ្ជាជីវៈ និងសមត្ថភាពទេពកោសល្យលើមុខជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីគាំទ្រនិងរួមចំណែកអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាពនិងចីរភាព ។ យុទ្ធសាស្ត្រទី៣ គឺផ្ដោតលើសកម្មភាពជាយុទ្ធសាស្ត្រនិងចំណុចដៅសំខាន់ៗដូចខាងក្រោម:

៣.១. ការវាយតម្លៃកម្រិតចំណេះដឹងមូលដ្ឋាន និងសមត្ថភាពជំនាញពាក់ព័ន្ធរបស់សិក្ខាកាម និងកំណត់វិធីសាស្ត្រនិងបច្ចេកទេសច្បាស់លាស់ មុននឹងអនុវត្តការបណ្ដុះបណ្ដាលនិងវិក្រឹតការ

៣.២. ការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលនិងវិក្រឹតការ ដែលមានលក្ខណៈប្រមូលផ្ដុំជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ

៣.៣. ការវាយតម្លៃគុណភាព ប្រសិទ្ធភាព និង សមិទ្ធកម្មនៃការបណ្ដុះបណ្ដាលនិងវិក្រឹតការ ។

## ៥. ផែនការសកម្មភាព

ដើម្បីឈានទៅអនុវត្តយុទ្ធសាស្ត្ររួមទាំង ៣ ខាងលើ នៃផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាពឱ្យសម្រេចបានជោគជ័យប្រកបដោយប្រសិទ្ធភាព ស្របតាមចំណុចដៅជាយុទ្ធសាស្ត្រនីមួយៗ និង ដើម្បីតម្រង់ទិសការអនុវត្តឱ្យប្រព្រឹត្តទៅបានដោយរលូន និង មានភាពប្រទាក់ក្រឡាបំពេញឱ្យគ្នាទៅវិញទៅមក ផែនការសកម្មភាពរួមមួយ នឹងត្រូវរៀបចំឡើងជាសង្ខេបទៅតាមយុទ្ធសាស្ត្រ និង ចំណុចដៅជាយុទ្ធសាស្ត្រនីមួយៗ ដូចខាងក្រោម:

**យុទ្ធសាស្ត្រទី ១: ការអភិវឌ្ឍសមត្ថភាពស្ថាប័ន**

***១.១. ការពង្រឹង និងបង្កើនធនធានមនុស្សសម្រាប់អនុវត្តការស្រាវជ្រាវ បណ្តុះបណ្តាល និងវិក្រឹតការ***

- ពង្រឹងនិងពង្រីកសមត្ថភាពមន្ត្រីបច្ចេកទេសនិងសម្របសម្រួល នៃស្ថាប័នទទួលបណ្តុះបណ្តាលនិងវិក្រឹតការ
- ជ្រើសរើស រៀបចំ ពង្រឹង និង ពង្រីកសមត្ថភាពគ្រូឧទ្ទេស គ្រូបង្គោល និងសាស្ត្រាចារ្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់អនុវត្តការងារស្រាវជ្រាវ បណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាពមន្ត្រីរាជការ
- រៀបចំ និងសម្របសម្រួលការផ្ទេរ និងចែករំលែកចំណេះដឹង ជំនាញ និងឧត្តមានុវត្តន៍ពីទីប្រឹក្សានិងអ្នកជំនាញការទាំងក្នុងស្រុក និងអន្តរជាតិ ជូនដល់មន្ត្រីរាជការ គ្រូបង្គោល គ្រូឧទ្ទេស និងសាស្ត្រាចារ្យ
- វាយតម្លៃសមិទ្ធផល និង ស្នាដៃដែលមន្ត្រីបច្ចេកទេសនិងសម្របសម្រួល គ្រូឧទ្ទេស គ្រូបង្គោល និងសាស្ត្រាចារ្យសម្រេចបានលើការងារស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការ សម្រាប់ផ្តល់ការលើកទឹកចិត្ត
- សិក្សាលទ្ធភាពដើម្បីបង្កើនការគាំទ្រថវិកាសម្រាប់អនុវត្តការស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការ ឆ្លើយតបទៅនឹងតម្រូវការនៃការកសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ។

***១.២. ការធ្វើទំនើបកម្ម និងបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសម្ភាររូបវ័ន្ត សម្រាប់គាំទ្រការស្រាវជ្រាវ បណ្តុះបណ្តាល និងវិក្រឹតការដើម្បីពង្រឹងនិងពង្រីកសមត្ថភាពមន្ត្រីរាជការ***

- រៀបចំ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងបំពាក់សម្ភាររូបវ័ន្តទំនើបចាំបាច់គ្រប់គ្រាន់ និងសមស្រប សម្រាប់គាំទ្រដំណើរការអនុវត្តកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ
- រៀបចំកែលម្អ គ្រប់គ្រង និង អភិវឌ្ឍប្រព័ន្ធទិន្នន័យ (Database) ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីស្រាវជ្រាវបណ្តុះបណ្តាលនិងវិក្រឹតការ
- រៀបចំ គ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងបណ្ណាល័យតាមបែបព័ត៌មានវិទ្យា
- រៀបចំ គ្រប់គ្រង និងអភិវឌ្ឍ គេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយតាមបណ្តាញសង្គម
- សិក្សាលទ្ធភាពដើម្បីធ្វើទំនើបកម្ម និងបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និង សម្ភាររូបវ័ន្តសម្រាប់គាំទ្រការស្រាវជ្រាវ ការបណ្តុះបណ្តាល និងវិក្រឹតការ ។

**យុទ្ធសាស្ត្រទី ២: ការពង្រឹងពង្រីកការស្រាវជ្រាវ និង អភិវឌ្ឍ តាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការ ដើម្បីធ្វើទំនើបកម្មកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ ពាក់ព័ន្ធការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ**

***២.១. ការវាយតម្លៃតម្រូវការជាក់លាក់សម្រាប់ការស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាពមន្ត្រីរាជការ***

- រៀបចំផែនការ ឧបករណ៍ និង កំណត់វិធីសាស្ត្រសម្រាប់ការវាយតម្លៃតម្រូវការ នៃការស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាព ដោយសហការជិតស្និទ្ធជាមួយគ្រប់តួអង្គពាក់ព័ន្ធ
- សម្របសម្រួល និង អនុវត្តផែនការវាយតម្លៃតម្រូវការនៃការស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាព
- ប្រមូលសរុប និងវិភាគព័ត៌មាន-ទិន្នន័យ សម្រាប់កំណត់និងវាយតម្លៃឱ្យបានច្បាស់លាស់អំពីតម្រូវការនៃការស្រាវជ្រាវបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាព ។

***២.២. ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍកម្មវិធី មុខជំនាញ ប្រធានបទ ឯកសារ និងវិធីសាស្ត្របណ្តុះបណ្តាលនិងវិក្រឹតការ***

- សិក្សា ស្រាវជ្រាវ និងប្រមូលធាតុចូលអំពីការអនុវត្តគោលនយោបាយ និងកម្មវិធីពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពីគ្រប់អគ្គលេខាធិការដ្ឋាន/អគ្គនាយកដ្ឋាន និងអង្គភាពនៃ កសហវ និងក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំ និងធ្វើទំនើបកម្មកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការ (ប្រធានបទ ឯកសារ វិធីសាស្ត្របណ្តុះបណ្តាល ...)
- ចងក្រង បោះពុម្ព និង ផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវ ។

***២.៣. ការពង្រឹង និងពង្រីកការស្រាវជ្រាវ ការបណ្តុះបណ្តាលនិងវិក្រឹតការ តាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការជាមួយស្ថាប័ននិងដៃគូពាក់ព័ន្ធជាតិ-អន្តរជាតិ***

- ពង្រឹង និងពង្រីកកិច្ចសហការជាមួយគ្រប់អគ្គលេខាធិការដ្ឋាន/អគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ នៃ កសហវ ក្រសួង ស្ថាប័ន និង ដៃគូពាក់ព័ន្ធក្នុងស្រុក
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយស្ថាប័ន និង ដៃគូពាក់ព័ន្ធអន្តរជាតិ ។

**យុទ្ធសាស្ត្រទី ៣: ការបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាព**

***៣.១. ការវាយតម្លៃកម្រិតចំណេះដឹងមូលដ្ឋាន និង សមត្ថភាពជំនាញពាក់ព័ន្ធរបស់សិក្ខាកាម និង កំណត់វិធីសាស្ត្រ និង បច្ចេកទេសច្បាស់លាស់ មុននឹងអនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការ***

- កំណត់ឱ្យបានជាក់លាក់អំពីកម្រិតចំណេះដឹងមូលដ្ឋាន និងសមត្ថភាពជំនាញពាក់ព័ន្ធរបស់សិក្ខាកាម
- កំណត់វិធីសាស្ត្រនិងបច្ចេកទេសសមស្រប សម្រាប់ការបណ្តុះបណ្តាលនិងវិក្រឹតការ
- សម្របសម្រួល និង បំពាក់បំប៉នអំពីវិធីសាស្ត្រនិងបច្ចេកទេស នៃការបណ្តុះបណ្តាលនិងវិក្រឹតការជូនដល់គ្រូបង្គោល គ្រូឧទ្ទេស និង ក្រុមសម្របសម្រួលវគ្គបណ្តុះបណ្តាល ។

***៣.២. ការអនុវត្តកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការដែលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ***

- រៀបចំ និង សម្របសម្រួលកម្មវិធី (មុខវិជ្ជា ប្រធានបទ) បណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាព ឆ្លើយតបទៅនឹងតម្រូវការរបស់ក្រសួង ស្ថាប័ន
- លើកកម្ពស់កិច្ចសហការជាមួយអគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) និងក្រសួងស្ថាប័នក្នុងការអនុវត្តផែនការ និង កម្មវិធីបណ្តុះបណ្តាល
- អនុវត្តដំណើរការបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាពជូនដល់មន្ត្រីរាជការនៃគ្រប់ក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល និង សហគ្រាសសាធារណៈរបស់រដ្ឋ
- រៀបចំនិងអនុវត្តកម្មវិធីបណ្តុះបណ្តាលជាស៊េរី កម្រិតវិញ្ញាបនបត្រសម្រាប់ក្រុមមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ឬ អ្នកដែលត្រូវតែងតាំង ប្រគល់ភារកិច្ចជាមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ នៃគ្រប់ក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈរបស់រដ្ឋ ។

***៣.៣. ការវាយតម្លៃគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មនៃការបណ្តុះបណ្តាល និង វិក្រឹតការ***

- រៀបចំយន្តការ ផែនការ ឧបករណ៍ និង កំណត់វិធីសាស្ត្រសម្រាប់ការវាយតម្លៃគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មនៃការបណ្តុះបណ្តាល និងវិក្រឹតការ
- សម្របសម្រួល និងអនុវត្តផែនការវាយតម្លៃគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មនៃការបណ្តុះបណ្តាល និងវិក្រឹតការ
- ប្រមូលសរុប និងវិភាគព័ត៌មាន-ទិន្នន័យ សម្រាប់កំណត់និងវាយតម្លៃឱ្យបានច្បាស់លាស់អំពីគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មនៃការបណ្តុះបណ្តាល និងវិក្រឹតការ ។

តារាងម៉ាទ្រីស នៃផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ រួមទាំងនឹងការកំណត់អំពីក្របខណ្ឌពេលវេលា និងស្ថាប័នអនុវត្ត គឺមាននៅក្នុង***តារាងឧបសម្ព័ន្ធ ១***ដែលមានភ្ជាប់ជាមួយ ។

## ៦. តួអង្គនិងយន្តការអនុវត្តន៍ និង ប្រភពធនធានហិរញ្ញវត្ថុ

ស្ថាប័នតួអង្គនិងយន្តការអនុវត្តន៍ ជាឧបករណ៍គន្លឹះសម្រាប់ជំរុញការចូលរួម និង ការសហការអនុវត្តផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ឱ្យសម្រេចជោគជ័យប្រកបដោយប្រសិទ្ធភាព ឆ្លើយតបទៅនឹងចក្ខុវិស័យ គោលបំណង និង គោលដៅដែលបានកំណត់ ។ ទន្ទឹមនេះ ការគាំទ្រផ្នែកស្មារតី ធនធានហិរញ្ញវត្ថុ និងបច្ចេកទេស គឺជាកម្លាំងចលករចាំបាច់ សម្រាប់ធានាចីរភាព និង ឆ្លើយតបទៅនឹងតម្រូវការ ក្នុងការកសាងសមត្ថភាពមន្ត្រីរាជការ ។ ក្នុងន័យនេះ ផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ នឹងត្រូវដឹកនាំអនុវត្តផ្ទាល់ដោយឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈឯកឧត្តមបណ្ឌិត **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការទទួលបន្ទុក របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការចូលរួមគាំទ្រ និងសហការអនុវត្តពីគ្រប់អង្គភាព ក្រសួងស្ថាប័ន និងតួអង្គពាក់ព័ន្ធ ។

### ៦.១. តួអង្គអនុវត្តន៍

ស្ថាប័នតួអង្គសំខាន់ៗដែលត្រូវចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ រួមមាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងស្ថាប័ន, ដៃគូអភិវឌ្ឍន៍ និងដៃគូសហប្រតិបត្តិការ ។ ក្នុងទិដ្ឋភាពបច្ចេកទេស ស្ថាប័នតួអង្គរួមមាន: ក្រុមការងារកសាងសមត្ថភាព, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, អគ្គលេខាធិការដ្ឋាន កសហវ/អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱ្យវាទ កសហវ, ស្ថាប័ននីតិបញ្ញត្តិ អាជ្ញាធរសវនកម្មជាតិ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ, ក្រសួងស្ថាប័ន និងមន្ទីរជំនាញ-អង្គភាពពាក់ព័ន្ធក្រោមឱវាទ, លេខាធិការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ និងលេខាធិការដ្ឋានកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ, ដៃគូរអភិវឌ្ឍន៍, ដៃគូរសហប្រតិបត្តិការ និងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហរញ្ញវត្ថុ ។ ស្ថាប័នតួអង្គទាំងនេះ ចែកចេញជា ៤ ប្រភេទគឺ ***តួអង្គដឹកនាំនិងណែនាំអនុវត្តផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាព, តួអង្គផ្តល់សេវាបណ្តុះបណ្តាលនិងវិក្រឹតការ, តួអង្គទទួលសេវាបណ្តុះបណ្តាលនិងវិក្រឹតការ និង តួអង្គគាំទ្រដំណើរការបណ្តុះបណ្តាលនិងវិក្រឹតការ*** ។ ប្រភេទស្ថាប័នតួអង្គនីមួយៗមានតួនាទី ភារកិច្ចរៀងៗខ្លួន ដែលបំពេញឱ្យគ្នា និងមានទំនាក់ទំនងគ្នាទៅវិញទៅមក ហើយមានខ្លឹមសារលម្អិតដូចខាងក្រោម:

#### ៦.១.១. ក្រុមការងារកសាងសមត្ថភាព

ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ **ក្រុមការងារកសាងសមត្ថភាព** មួយនឹងត្រូវបង្កើតឡើង និងត្រូវអនុវត្តភារកិច្ច ក្រោមការដឹកនាំ និងណែនាំកម្រិតនយោបាយរបស់ឯកឧត្តមបណ្ឌិត **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ **ក្រុមការងារកសាងសមត្ថភាព**នេះ ជាតួអង្គដឹកនាំ និង ណែនាំការអនុវត្តផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាព ពិសេស ការអនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការ ដែលមានតួនាទី និងភារកិច្ចដូចខាងក្រោម:

(១). ដឹកនាំ ណែនាំ និង តម្រង់ទិសជាយុទ្ធសាស្ត្រ ក្នុងការអនុវត្ត និង ការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ

(២). ធានា និងគាំទ្រឱ្យការបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាព លើជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំ និងអនុវត្តមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ

(៣). ដឹកនាំ និងណែនាំតម្រង់ទិស ក្នុងការវាយតម្លៃតម្រូវការ និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលនិងវិក្រឹតការ និង

(៤). ដឹកនាំ និងណែនាំទម្រង់ទិសការរៀបចំធ្វើបច្ចុប្បន្នកម្មឯកសារផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់ដំណាក់កាលទី៤ នៅពេលខាងមុខ ។

### ៦.១.២. អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ដើម្បីអនុវត្តផែនការយុទ្ធសាស្រ្តកសាងនិងអភិវឌ្ឍសមត្ថភាពនេះ អគហ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងបំពេញមុខងារជាតួអង្គគាំទ្រដំណើរការបណ្តុះបណ្តាលនិងវិក្រឹតការ ដែលមានតួនាទី និង ភារកិច្ចសំខាន់ៗដូចខាងក្រោម:

(១). សម្របសម្រួល និងគាំទ្រថវិកា សម្រាប់អនុវត្តកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាពជូនមន្ត្រីរាជការ

(២). សម្របសម្រួលការបញ្ជូនសំណើសុំអនុវត្តកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ និង សំណើពាក់ព័ន្ធការអនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការ ពីគ្រប់អគ្គលេខាធិការដ្ឋាន/អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងស្ថាប័ន ទៅកាន់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីសម្របសម្រួលនិងអនុវត្ត

(៣). សហការផ្តល់អ្នកជំនាញពី អគហ ដល់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើជាគ្រូឧទ្ទេស ឬ វាគ្មិន សម្រាប់អនុវត្តកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាព ពាក់ព័ន្ធការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

(៤). សម្របសម្រួល និងសហការជាមួយ លេខាធិការដ្ឋាន នៃការងារកែទម្រង់រដ្ឋបាលសាធារណៈ, ការងារកែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ និង វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការកំណត់នូវចំណុចប្រទាក់ក្រឡាគ្នា បំពេញឱ្យគ្នា និងត្រួតស៊ីគ្នាអំពីតម្រូវការបណ្តុះបណ្តាល នៃកម្មវិធីកែទម្រង់ទាំង ៣ (PFM, D&D and PAR) ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវា ចំគោលដៅ និងមានប្រសិទ្ធភាព និង

(៥). សម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីកៀរគរថវិកានិងអ្នកជំនាញឯកទេសកសាងសមត្ថភាព សម្រាប់សហការ និងគាំទ្រវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការអនុវត្តកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ ដែលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ ប្រកបដោយគុណភាព និងប្រសិទ្ធភាព ។

### ៦.១.៣. អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន មន្ទីរ និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ដើម្បីអនុវត្តផែនការយុទ្ធសាស្រ្តកសាងនិងអភិវឌ្ឍសមត្ថភាពនេះ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទកសហវ[7] នឹងបំពេញមុខងារជាតួអង្គទទួលសេវាបណ្តុះបណ្តាល ដែលមានតួនាទី ភារកិច្ចដូចខាងក្រោម:

(១). សហការជាមួយវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការអនុវត្តការវាយតម្លៃតម្រូវការសម្រាប់ការរៀបចំផែនការ និងកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ

(២). ចាត់បញ្ជូនមន្ត្រីគោលដៅតាមលក្ខខណ្ឌកំណត់ សម្រាប់ជាសិក្ខាកាមចូលរួមវគ្គបណ្តុះបណ្តាលនិងវិក្រឹត្យការ ក្នុងគោលបំណងដើម្បីពង្រឹងពង្រីកសមត្ថភាព និងអភិវឌ្ឍជំនាញឯកទេសជាក់លាក់តាមតម្រូវការរបស់អង្គភាព

(៣). ចាត់បញ្ជូនអ្នកជំនាញចូលរួមជាគ្រូបង្គោល គ្រូឧទ្ទេស ឬ វាគ្មិន សម្រាប់ការបណ្តុះបណ្តាលនិងវិក្រឹតការ ដែលរៀបចំនិងសម្របសម្រួលដោយវិទ្យាស្ថាន និងចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល (TOT) ដើម្បីបំប៉នសមត្ថភាពបន្ថែម

(៤). ចូលរួមសហការជាមួយវិទ្យាស្ថាន និង តួអង្គពាក់ព័ន្ធ ក្នុងការវាយតម្លៃគុណភាព, ប្រសិទ្ធភាព និងសមិទ្ធកម្មនៃការបណ្តុះបណ្តាលនិងវិក្រឹតការ ជាមូលដ្ឋានសម្រាប់កែលម្អការរៀបចំ និងអនុវត្តកម្មវិធីក្រោយៗទៀត និង

(៥). លើកសំណើតាមរយៈ អគហ និង/ ឬ វិទ្យាស្ថានដើម្បីរៀបចំ និងសម្របសម្រួលការបណ្តុះបណ្តាលនិងវិក្រឹតការ ឬទស្សនកិច្ចសិក្សាជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការរបស់ខ្លួន ។

---

[7] ***អង្គភាពក្រោមឱវាទ កសហវ*** *សំដៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃរាជធានី-ខេត្ត និងគ្រប់អង្គភាពនៅក្រោមការគ្រប់គ្រងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅដំណាក់កាលទី៣ ។*

### ៦.១.៤. ក្រសួង ស្ថាប័ន មន្ទីរជំនាញ-អង្គភាពក្រោមឱវាទ និង គ្រឹះស្ថានសាធារណៈរដ្ឋបាល

ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ ក្រសួងស្ថាប័ន មន្ទីរជំនាញ-អង្គភាពពាក់ព័ន្ធក្រោមឱវាទ[8] និងគ្រឹះស្ថានសាធារណៈរដ្ឋបាល នឹងបំពេញមុខងារជាតួអង្គទទួលសេវាបណ្តុះបណ្តាល ដែលមានតួនាទី ភារកិច្ចដូចខាងក្រោម:

(១). សហការផ្តល់ព័ត៌មាន និងទិន្នន័យដល់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់វិភាគនិងវាយតម្លៃអំពីតម្រូវការបណ្តុះបណ្តាលជាមូលដ្ឋានដើម្បីរៀបចំផែនការ និង កម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ

(២). ចាត់បញ្ជូនមន្ត្រីគោលដៅតាមលក្ខខណ្ឌកំណត់ សម្រាប់ជាសិក្ខាកាមចូលរួមវគ្គបណ្តុះបណ្តាលនិងវិក្រឹត្យការក្នុងគោលបំណងដើម្បីពង្រឹងពង្រីកសមត្ថភាព និង អភិវឌ្ឍជំនាញឯកទេសតាមតម្រូវការរបស់ខ្លួន

(៣). ចាត់បញ្ជូនអ្នកជំនាញចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល(TOT) ដែលរៀបចំ និងសម្របសម្រួលដោយវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការបណ្តុះបណ្តាលបន្តជូនមន្ត្រីរាជការរបស់ក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធ

(៤). ចូលរួមសហការជាមួយវិទ្យាស្ថាន និង តួអង្គពាក់ព័ន្ធ ក្នុងការវាយតម្លៃគុណភាព, ប្រសិទ្ធភាព និងសមិទ្ធកម្មនៃការបណ្តុះបណ្តាលនិងវិក្រឹតការ ជាមូលដ្ឋានសម្រាប់កែលម្អការរៀបចំ និង អនុវត្តកម្មវិធីក្រោយៗទៀត និង

(៥). លើកសំណើតាមរយៈ អគហ និង/ឬ វិទ្យាស្ថានដើម្បីរៀបចំនិងសម្របសម្រួលការបណ្តុះបណ្តាលនិងវិក្រឹតការ ឬទស្សនកិច្ចសិក្សាជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការរបស់ខ្លួន ។

### ៦.១.៥. ស្ថាប័ននីតិបញ្ញត្តិ អាជ្ញាធរសវនកម្មជាតិ និង អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ

ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ ស្ថាប័ននីតិបញ្ញត្តិ អាជ្ញាធរសវនកម្មជាតិ និង អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ នឹងចូលរួមបំពេញមុខងារជាតួអង្គទទួលសេវាបណ្តុះបណ្តាល ដែលមានតួនាទី ភារកិច្ចដូចខាងក្រោម:

(១). សហការផ្តល់ព័ត៌មាន និងទិន្នន័យដល់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់វិភាគនិងវាយតម្លៃអំពីតម្រូវការបណ្តុះបណ្តាលជាមូលដ្ឋានដើម្បីរៀបចំផែនការ និង កម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ

(២). ចាត់បញ្ជូនសិក្ខាកាមគោលដៅ ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលនិងវិក្រឹត្យការ ក្នុងគោលបំណងពង្រឹងពង្រីកសមត្ថភាព និង ការយល់ដឹងលើជំនាញឯកទេសពាក់ព័ន្ធការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ

(៣). ចាត់បញ្ជូនអ្នកជំនាញចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល(TOT) ដែលរៀបចំ និងសម្របសម្រួលដោយវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការបណ្តុះបណ្តាលបន្តទៅតាមតម្រូវការរបស់អង្គភាព

(៤). ចូលរួមសហការផ្តល់ព័ត៌មានពាក់ព័ន្ធដល់វិទ្យាស្ថាន និង តួអង្គផ្តល់សេវាបណ្តុះបណ្តាល សម្រាប់ការវាយតម្លៃគុណភាព, ប្រសិទ្ធភាព និងសមិទ្ធកម្មនៃការបណ្តុះបណ្តាលនិងវិក្រឹតការ ដើម្បីជាមូលដ្ឋានសម្រាប់កែលម្អការរៀបចំ និង អនុវត្តកម្មវិធីក្រោយៗទៀត និង

(៥). លើកសំណើតាមរយៈ អគហ និង/ឬ វិទ្យាស្ថានដើម្បីរៀបចំនិងសម្របសម្រួលការបណ្តុះបណ្តាលនិងវិក្រឹតការ ឬទស្សនកិច្ចសិក្សាលើជំនាញពាក់ព័ន្ធសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ។

---

[8] ***មន្ទីរជំនាញ-អង្គភាពក្រោមឱវាទ*** *សំដៅមន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធនៃក្រសួងស្ថាប័ននៅតាមរាជធានី-ខេត្ត ដែលត្រូវចូលរួមអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅដំណាក់កាលទី៣ ។*

### ៦.១.៦. លេខាធិការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ និងលេខាធិការដ្ឋានកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ លេខាធិការដ្ឋាននៃកំណែទម្រង់រដ្ឋបាលសារធាណៈ និងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ នឹងបំពេញមុខងារជាតួអង្គគាំទ្រដំណើរការបណ្តុះបណ្តាល ដែលមានតួនាទី និងភារកិច្ចដូចខាងក្រោម:

(១). ចូលរួមជាមួយ អគហ, វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងស្ថាប័ននិងអង្គភាពពាក់ព័ន្ធក្រោមឱវាទ ក្នុងការកំណត់នូវចំណុចប្រទាក់ក្រឡាគ្នា បំពេញឱ្យគ្នា និង ត្រួតស៊ីគ្នាអំពីតម្រូវការបណ្តុះបណ្តាល សំដៅឆ្លើយតបឱ្យបានទាន់ពេលវា ចំគោលដៅ និងមានប្រសិទ្ធភាព

(២). សហការជាមួយ អគហ ដើម្បីសម្របសម្រួលទំនាក់ទំនងរវាងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាមួយតួអង្គផ្តល់សេវាបណ្តុះបណ្តាលផ្សេងទៀតរបស់ក្រសួងស្ថាប័ន ក្នុងការរៀបចំ និងអនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការ

(៣). សម្របសម្រួល និង សហការជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ក្នុងការគាំទ្រខាងស្មារតី ថវិកា និងបច្ចេកទេស សម្រាប់អនុវត្តកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ ជូនគ្រូបង្គោល និងមន្ត្រីរាជការគោលដៅរបស់ក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោម ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

### ៦.១.៧. ដៃគូអភិវឌ្ឍន៍

ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះ ដៃគូអភិវឌ្ឍន៍ នឹងបំពេញមុខងារជាតួអង្គគាំទ្រដំណើរការបណ្តុះបណ្តាល ដែលមានតួនាទី និងភារកិច្ចដូចខាងក្រោម:

(១). សហការជាមួយ អគហ, លេខាធិការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ និង លេខាធិការដ្ឋានកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, ក្រសួងស្ថាប័ននិងអង្គភាពពាក់ព័ន្ធក្រោមឱវាទ, វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតួអង្គផ្សេងទៀត ក្នុងការកំណត់តម្រូវការបណ្តុះបណ្តាលដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា បំពេញឱ្យគ្នា និង ត្រួតស៊ីគ្នា

(២). សហការជាមួយ អគហ, លេខាធិការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ និងលេខាធិការដ្ឋានកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងការគាំទ្រខាងស្មារតី ថវិកា និង បច្ចេកទេស សម្រាប់អនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល និងមន្ត្រីរាជការគោលដៅរបស់ កសហវ ក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

(៣). ផ្តល់អ្នកជំនាញចូលរួមជាគ្រូឧទ្ទេស, វាគ្មិន និង/ឬ ជាអ្នកជំនាញការកសាងសមត្ថភាព ដើម្បីអនុវត្តការបណ្តុះបណ្តាល, វាយតម្លៃគុណភាព, ប្រសិទ្ធភាព និងសមិទ្ធកម្ម និង ចូលរួមពិនិត្យវាយតម្លៃលទ្ធផលនៃការអនុវត្ត សំដៅកែលម្អ និងធ្វើបច្ចុប្បន្នកម្មឯកសារផែនការយុទ្ធសាស្ត្រនេះ តាមការចាំបាច់ សម្រាប់ដំណាក់កាលទី៤ នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

### ៦.១.៨. ដៃគូសហប្រតិបត្តិការ

ដៃគូសហប្រតិបត្តិការគឺសំដៅវិទ្យាស្ថាន, សាកលវិទ្យាល័យ, អង្គការ និង/ឬស្ថាប័នជាតិ-អន្តរជាតិ ដែលមានបេសកកម្មដូចគ្នាឬប្រហាក់ប្រហែលគ្នា និងបានចូលរួមសហការជាមួយវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង/ឬតួអង្គផ្តល់សេវាបណ្តុះបណ្តាលផ្សេងទៀត ក្នុងការរៀបចំ និងអនុវត្តគម្រោងកម្មវិធីបណ្តុះបណ្តាល ជូនមន្ត្រីរាជការកម្ពុជា ។ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះ ដៃគូសហប្រតិបត្តិការ បំពេញមុខងារជាតួអង្គផ្តល់សេវាបណ្តុះបណ្តាល ដែលមានតួនាទី និងភារកិច្ចដូចខាងក្រោម:

(១). សហការជាមួយវិទ្យាស្ថាន ក្នុងការសិក្សាស្រាវជ្រាវ វិភាគ និងវាយតម្លៃតម្រូវការបណ្តុះបណ្តាល ដើម្បីរៀបចំគម្រោងកម្មវិធី និង អនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាព តាមកិច្ចព្រមព្រៀង និងសេចក្តីត្រូវការជូនមន្ត្រីរាជការកម្ពុជា

(២). សហការគាំទ្រថវិកា សម្ភារ បច្ចេកទេស គ្រូឧទ្ទេស និង អ្នកជំនាញការឯកទេស សម្រាប់អនុវត្តការបណ្តុះបណ្តាល និងវិក្រឹតការ និង ចូលរួមវាយតម្លៃគុណភាព ប្រសិទ្ធភាព និង សមិទ្ធកម្ម ក្រោយការបណ្តុះបណ្តាល និង

(៣). ផ្តល់ការប្រឹក្សាយោបល់ សំដៅធ្វើទំនើបកម្មវិធី និងវិធីសាស្ត្របណ្តុះបណ្តាល និង ផ្តល់ការបណ្តុះបណ្តាលបំប៉នសមត្ថភាពបន្ថែមជូនគ្រូបង្គោល, គ្រូឧទ្ទេស និងសាស្ត្រាចារ្យរបស់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង/ឬតួអង្គផ្តល់សេវាបណ្តុះបណ្តាលផ្សេងទៀត ដើម្បីឱ្យស្របទៅតាមបរិបទអន្តរជាតិ និងសេចក្តីត្រូវការរបស់កម្ពុជា ។

### ៦.១.៩. វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារបណ្តុះបណ្តាលនិងវិក្រឹតការលើជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ។ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ វិទ្យាស្ថាននឹងបំពេញមុខងារជាតួអង្គផ្តល់សេវា និង សម្របសម្រួលការផ្តល់សេវាបណ្តុះបណ្តាលនិងវិក្រឹតការអនុលោមតាមការដឹកនាំនិងណែនាំរបស់ក្រុមការងារកសាងសមត្ថភាព និង សហការជិតស្និទ្ធជាមួយគ្រប់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងស្ថាប័ន និង ដៃគូជាតិ-អន្តរជាតិ ដោយអនុវត្តនូវតួនាទី និងភារកិច្ចដូចខាងក្រោម:

(១). សម្របសម្រួល និងអនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការដែលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ

(២). សិក្សាស្រាវជ្រាវ និង ប្រមូលទិន្នន័យជាធាតុចូល ដើម្បីរៀបចំនិងកែលម្អកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ ព្រមទាំងបោះពុម្ពផ្សព្វផ្សាយលទ្ធផល និងឯកសារស្រាវជ្រាវ ពាក់ព័ន្ធនឹងបញ្ហាសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

(៣). សម្របសម្រួល និង អនុវត្តការវាយតម្លៃតម្រូវការគុណភាព និងប្រសិទ្ធភាព នៃការបណ្តុះបណ្តាលនិងវិក្រឹតការ និងវាយតម្លៃកម្រិតចំណេះដឹងមូលដ្ឋាន និងសមត្ថភាពជំនាញពាក់ព័ន្ធរបស់សិក្ខាកាម

(៤). ផ្តួចផ្តើម សម្របសម្រួល និងជំរុញកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នស្រាវជ្រាវ និងបណ្តុះបណ្តាលជាតិ-អន្តរជាតិ

(៥). រៀបចំ និងសម្របសម្រួលការផ្ទេរនិងចែករំលែកចំណេះដឹង ជំនាញ និងឧត្តមានុវត្តន៍ពីទីប្រឹក្សា និងអ្នកជំនាញការទាំងក្នុងស្រុក និងអន្តរជាតិ ជូនដល់មន្ត្រីរាជការ គ្រូបង្គោល គ្រូឧទ្ទេស និងសាស្ត្រាចារ្យ

(៦). ជ្រើសរើស រៀបចំ និងសម្របសម្រួលការបណ្តុះបណ្តាលបំប៉ន និង ចាត់ចែងគ្រូបង្គោល គ្រូឧទ្ទេស និង សាស្ត្រាចារ្យសម្រាប់អនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការ និងអនុវត្តការវាយតម្លៃសមិទ្ធផល និងស្នាដៃសម្រេចបាន និង

(៧). សហការជាមួយតួអង្គផ្តល់សេវាបណ្តុះបណ្តាល ផ្សេងទៀត តាមរយៈ អគហ និង លេខាធិការដ្ឋាននៃកំណែទម្រង់រដ្ឋបាលសាធារណៈ និង កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ក្នុងការកំណត់ចំណុចប្រទាក់ក្រឡាគ្នា បំពេញឱ្យគ្នា និងត្រួតស៊ីគ្នាលើតម្រូវការបណ្តុះបណ្តាល ដើម្បីឆ្លើយតបឱ្យទាន់ពេលវេលា ចំគោលដៅ និង មានប្រសិទ្ធភាព។

## ៦.២. យន្តការអនុវត្តន៍

ចរន្តលំហូរនៃប្រព័ន្ធតួអង្គ និងយន្តការអនុវត្តន៍ផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ គឺត្រូវប្រព្រឹត្តទៅតាមអភិក្រមដូចតទៅ: រៀងរាល់ឆ្នាំ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងរៀបចំការសិក្សាស្រាវជ្រាវ ពិគ្រោះយោបល់ និង ប្រមូលព័ត៌មាននិងទិន្នន័យចាំបាច់សម្រាប់វិភាគ វាយតម្លៃ និងកំណត់ពីតម្រូវការជាក់ស្តែង សម្រាប់ការរៀបចំផែនការតម្រូវការរួម និង កម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំលើមុខជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ កិច្ចការនេះនឹងត្រូវរៀបចំសម្របសម្រួលនិងអនុវត្តដោយវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាសេនាធិការលើការងារបណ្តុះបណ្តាលនិងវិក្រឹតការ អនុលោមតាម

ការដឹកនាំ និងណែនាំតម្រង់ទិសជាយុទ្ធសាស្ត្រពីក្រុមការងារកសាងសមត្ថភាពនៃ កសហវ និងសហការជិតស្និទ្ធជាមួយគ្រប់អគ្គលេខាធិការដ្ឋាន, អគ្គនាយកដ្ឋាន និង អង្គភាពក្រោមឱវាទ កសហវ, ក្រសួងស្ថាប័ន និងអង្គភាពក្រោមឱវាទ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និង គ្រប់ដៃគូពាក់ព័ន្ធជាតិ-អន្តរជាតិ ។ ផ្អែកលើផែនការតម្រូវការប្រចាំឆ្នាំ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងរៀបចំបូកសរុបជាផែនការ និង កម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការប្រចាំឆ្នាំ និង គ្រោងកញ្ចប់ថវិកាសម្រាប់គាំទ្រការអនុវត្ត ដើម្បីគោរពស្នើសុំការសម្រេច និងការគាំទ្រពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ក្នុងករណីចាំបាច់ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងគោរពស្នើសុំគោលការណ៍ និង ការណែនាំពីថ្នាក់ដឹកនាំក្រសួងដើម្បីបង្កើត ឬបន្តកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នដៃគូជាតិ-អន្តរជាតិ សម្រាប់ការរៀបចំ និង អនុវត្តកម្មវិធីបណ្តុះបណ្តាលទៅតាមការចង្អុលបង្ហាញពីថ្នាក់ដឹកនាំក្រសួង ឬតាមតម្រូវការដែលស្នើឡើងដោយអគ្គលេខាធិការដ្ឋាន, អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ កសហវ ឬក្រសួងស្ថាប័ន និងអង្គភាពក្រោមឱវាទ ។ លើសពីនេះ ករណីមានតម្រូវការបណ្តុះបណ្តាលចាំបាច់និងបន្ទាន់បន្ថែមពីអគ្គនាយកដ្ឋាន ឬអង្គភាពក្រោមឱវាទ កសហវ ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រៅពីគម្រោងផែនការតម្រូវការរួមដែលត្រូវទទួលការអនុម័តគាំទ្រពីថ្នាក់ដឹកនាំក្រសួងរួចហើយ វិទ្យាស្ថាននឹងពិនិត្យលទ្ធភាពដើម្បីរៀបចំគម្រោងកម្មវិធីពិសេសនិងគោរពស្នើការពិនិត្យសម្រេច និង ការណែនាំពីថ្នាក់ដឹកនាំ កសហវ ដែលនឹងត្រូវអនុវត្តតាមនីតិវិធី និង ចរន្តលំហូរនៃប្រព័ន្ធគ្រប់គ្រង និង យន្តការដូចមាននៅក្នុង**ឧបសម្ព័ន្ធទី ៣** ។

## ៦.៣. ប្រភពធនធានហិរញ្ញវត្ថុ

ជារួម ប្រភពធនធានហិរញ្ញវត្ថុសម្រាប់គាំទ្រដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ គឺបានពីថវិការដ្ឋក្នុងក្របខណ្ឌថវិកាកម្មវិធីនិងអង្គភាពថវិកា, ថវិកាដៃគូអភិវឌ្ឍន៍ក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ថវិកាដៃគូសហប្រតិបត្តិការក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការទ្វេភាគី ឬពហុភាគី អនុលោមតាមការសម្រេចនិងការណែនាំជាគោលការណ៍ពីរដ្ឋមន្ត្រី កសហវ និងលក្ខខណ្ឌនៃគម្រោងកម្មវិធីនៃកិច្ចសហប្រតិបត្តិការនីមួយៗ និង ថវិកាបដិភាគពីស្ថាប័នអតិថិជន ។ ចំពោះនីតិវិធីសម្រាប់ការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ គឺត្រូវអនុវត្តតាមគោលការណ៍ច្បាប់ នីតិវិធី និងបទប្បញ្ញត្តិជាធរមានរបស់ កសហវ និងតាមលក្ខខណ្ឌរបស់ដៃគូកិច្ចសហប្រតិបត្តិការ ។

### ៦.៣.១. ប្រភពធនធានហិរញ្ញវត្ថុពីថវិការដ្ឋ

ការកសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ នឹងចូលរួមចំណែកសំខាន់ក្នុងការសម្រេចជោគជ័យ និង ចីរភាព នៃការអនុវត្តថវិកាកម្មវិធី និង អង្គភាពថវិកា ។ ក្នុងន័យនេះ ថវិកាគាំទ្រសម្រាប់ការងារបណ្តុះបណ្តាលនិងវិក្រឹតការ និងកិច្ចការពាក់ព័ន្ធ ត្រូវរៀបចំបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ និង ផែនការវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ដែលត្រូវសម្រេចនិងគាំទ្រដោយថ្នាក់ដឹកនាំ កសហវ ស្របតាមបទដ្ឋានគតិយុត្តិជាធរមាន និង ផ្អែកតាមផែនការសកម្មភាពប្រចាំឆ្នាំស្របតាមស្មារតីនៃផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាព និង គោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាកម្មវិធីនិងអង្គភាពថវិកា និងអនុលោមតាមលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។ ក្នុងនាមជាសេនាធិការរបស់ កសហវ លើការងារបណ្តុះបណ្តាលនិងវិក្រឹតការ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចត្រូវរៀបចំនិងសម្របសម្រួលកិច្ចការទាំងនេះ អនុលោមតាមការដឹកនាំ និង ណែនាំតម្រង់ទិសជាយុទ្ធសាស្ត្រពីក្រុមការងារកសាងសមត្ថភាព និង សហការជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ កសហវ ។

### ៦.៣.២. ប្រភពធនធានហិរញ្ញវត្ថុពីថវិកាដៃគូក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ

ទន្ទឹមនឹងប្រភពថវិការដ្ឋ ការកសាងនិងអភិវឌ្ឍសមត្ថភាព អាចទទួលថវិកាគាំទ្រពីដៃគូអភិវឌ្ឍន៍ តាមរយៈ អគហ សម្រាប់គាំទ្រការអនុវត្តផែនការសកម្មភាពរួម (GDAP3) ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចត្រូវរៀបចំសម្របសម្រួលជាមួយអគ្គលេខាធិការដ្ឋាន, អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ កសហវ ដើម្បីបញ្ចូលសកម្មភាពការងារបណ្តុះបណ្តាលនិងវិក្រឹតការ ទៅក្នុងផែនការសកម្មភាពរួម សំដៅចូលរួមចំណែកគាំទ្រការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ឱ្យសម្រេចជោគជ័យប្រកបដោយប្រសិទ្ធភាព ។

### ៦.៣.៣. ប្រភពធនធានហិរញ្ញវត្ថុពីថវិកាដៃគូសហប្រតិបត្តិការក្នុងក្របខណ្ឌសហប្រតិបត្តិការទ្វេភាគីឬពហុភាគី

ការកសាងនិងអភិវឌ្ឍសមត្ថភាពសម្រាប់អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេស ការអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកា និង ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានវិសាលភាពទូលំទូលាយដូច្នេះ ស្ថាប័នទទួលបន្ទុកការងារបណ្តុះបណ្តាលនិងវិក្រឹតការ ចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការទូលំទូលាយជាមួយស្ថាប័នដៃគូជាតិ-អន្តរជាតិ ដើម្បីពង្រីកវិសាលភាពនៃវិធីសាស្ត្រអភិវឌ្ឍសមត្ថភាពជូនមន្ត្រីរាជការ ។ ស្ថាប័នដៃគូសហប្រតិបត្តិការ អាចផ្តល់ថវិកាគាំទ្រជាបដិភាគសម្រាប់អនុវត្តគម្រោងបណ្តុះបណ្តាល ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការនោះ ។ ក្នុងនាមជាសេនាធិការរបស់ កសហវ លើការងារបណ្តុះបណ្តាលនិងវិក្រឹតការ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងត្រូវបន្តពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការថែមទៀតជាមួយស្ថាប័នដៃគូពាក់ព័ន្ធ ដើម្បីបង្កើនលទ្ធភាពឱ្យមន្ត្រីរាជការកម្ពុជាបានសិក្សា ស្វែងយល់ពីបទពិសោធន៍ និងឧត្តមានុវត្តន៍អន្តរជាតិ សម្រាប់រួមចំណែកអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

សម្រាប់ទិសដៅអនាគត ដើម្បីឱ្យផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពនេះ ត្រូវបានអនុវត្តបានដោយពេញលេញនិងមានប្រសិទ្ធភាព កសហវ នឹងសិក្សាលទ្ធភាពដើម្បីបង្កើនការគាំទ្រថវិកាគាំទ្រដល់ការធ្វើទំនើបកម្ម និងបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និង សម្ភាររូបវន្តសម្រាប់គាំទ្រការស្រាវជ្រាវ ការបណ្តុះបណ្តាលនិងវិក្រឹតការ លើជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ។ ក្រសួងស្ថាប័នទាំងអស់គួររៀបចំផែនការតម្រូវការបណ្តុះបណ្តាលសម្រាប់កសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការរបស់ខ្លួន នៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ និង ត្រូវគ្រោងថវិកាសម្រាប់អនុវត្តការងារនេះ និង អាចស្នើសុំកិច្ចសហការពី កសហវ ក្នុងការអនុវត្តកម្មវិធីបណ្តុះបណ្តាលលើមុខជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ តាមការចាំបាច់ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃ កសហវ អាចជួយផ្តល់សេវាបច្ចេកទេស ក្នុងការសិក្សាវាយតម្លៃអំពីតម្រូវការ និងការរៀបចំផែនការបណ្តុះបណ្តាលនិងវិក្រឹតការប្រចាំឆ្នាំជូនក្រសួងស្ថាប័នថែមទៀត ។

## ៧. ការត្រួតពិនិត្យ និង វាយតម្លៃ

ដើម្បីត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាព គុណភាព សង្គតិភាព និង ប្រសិទ្ធភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃ កសហវ នឹងដើរតួនាទីជាសេនាធិការ ក្នុងការសម្របសម្រួលដំណើរការអនុវត្តការត្រួតពិនិត្យនិងវាយតម្លៃ អនុលោមតាមការណែនាំតម្រង់ទិសជាយុទ្ធសាស្ត្រពីក្រុមការងារកសាងសមត្ថភាពដែលដឹកនាំ និងណែនាំកម្រិតនយោបាយពីរដ្ឋលេខាធិការទទួលបន្ទុក និង ប្រើប្រាស់ប្រព័ន្ធរបាយការណ៍, យន្តការត្រួតពិនិត្យនិងវាយតម្លៃ និង វិធីសាស្ត្រត្រួតពិនិត្យនិងវាយតម្លៃដូចខាងក្រោម:

### ៧.១. ប្រព័ន្ធរបាយការណ៍

វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចសម្របសម្រួលការរៀបចំរបាយការណ៍ប្រចាំត្រីមាស ឆមាស ប្រចាំឆ្នាំ

ពាក់កណ្ដាលអណត្តិ និង ចុងអណត្តិ ស្ដីពីវឌ្ឍនភាព និងបញ្ហាប្រឈម នៅក្នុងការអនុវត្តផែនការកសាងនិងអភិវឌ្ឍសមត្ថភាពនេះ ដោយសហការជាមួយតួអង្គពាក់ព័ន្ធ និង ផ្អែកលើលទ្ធផលសម្រេចបាន ធៀបជាមួយគោលបំណង និង គោលដៅ នៃយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដែលបានដាក់ចេញ សម្រាប់ជូនក្រុមការងារកសាងសមត្ថភាព ពិនិត្យណែនាំ និង គោរពស្នើសុំការពិនិត្យសម្រេច និងការណែនាំពីរដ្ឋមន្ត្រី កសហវ ។

### ៧.២. យន្តការត្រួតពិនិត្យ និង វាយតម្លៃ

ផែនការយុទ្ធសាស្ត្រស្ដីពីការកសាងនិងអភិវឌ្ឍសមត្ថភាពនេះ នឹងត្រូវតាមដានត្រួតពិនិត្យតាមយន្តការដូចតទៅ: ក្នុងកម្រិតយុទ្ធសាស្ត្រ ក្រុមការងារកសាងសមត្ថភាព ដែលដឹកនាំនិងណែនាំកម្រិតនយោបាយពីរដ្ឋលេខាធិការទទួលបន្ទុក និង មានវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ នឹងរៀបចំសិក្ខាសាលា ដែលមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីឱ្យក្រសួងស្ថាប័នទាំងនោះអាចចូលរួមត្រួតពិនិត្យលទ្ធផល និង ឆ្លុះបញ្ចាំងនូវយុទ្ធសាស្ត្ររបស់ខ្លួនលើការងារកសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៃក្រសួងស្ថាប័ននីមួយៗ ។ បន្ទាប់ពីនោះ ក្រុមការងារកសាងសមត្ថភាព តម្រូវឱ្យវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហការជាមួយអគ្គលេខាធិការដ្ឋាន, អគ្គនាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធក្រោមឱវាទ នៃ កសហវ ក្នុងការអនុវត្តការត្រួតពិនិត្យប្រចាំឆ្នាំ ដើម្បីពិនិត្យវាយតម្លៃលទ្ធផលសម្រេចបានក្នុងអនុវត្តយុទ្ធសាស្ត្រ និង សកម្មភាព នៃផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ ។

### ៧.៣. វិធីសាស្ត្រត្រួតពិនិត្យ និង វាយតម្លៃ

វិធីសាស្ត្រដែលត្រូវប្រើសម្រាប់ត្រួតពិនិត្យ និង វាយតម្លៃលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ រួមមានដូចខាងក្រោម:

**(១). ការត្រួតពិនិត្យចំណេះដឹងនិងជំនាញមូលដ្ឋានរបស់សិក្ខាកាមមុនវគ្គបណ្ដុះបណ្ដាលចាប់ផ្ដើម:** គឺជាការធ្វើតេស្តដើម្បីវាស់វែងកម្រិតចំណេះដឹងទូទៅនិងជំនាញមូលដ្ឋានរបស់សិក្ខាកាម ថាតើពួកគាត់មានការយល់ដឹងកម្រិតណាចំពោះប្រធានបទ និងចំណុចសំខាន់ៗ ទាំងឡាយនៃកម្មវិធីបណ្ដុះបណ្ដាលនោះ ក្នុងគោលបំណងដើម្បីកំណត់នូវវិធីសាស្ត្រសមស្របសម្រាប់ការបង្រៀន ។ ម្យ៉ាងទៀតលទ្ធផលនោះ នឹងប្រើជាចំណុចមូលដ្ឋានសម្រាប់ប្រៀបធៀបនូវកម្រិតនៃចំណេះដឹង និងជំនាញរបស់សិក្ខាកាមនៅក្រោយពេលបញ្ចប់វគ្គសិក្សា ។ ការវាស់ស្ទង់នេះ អាចប្រព្រឹត្តទៅតាមរយៈការប្រឡងសំណេរ ឬការរៀបចំកម្រងសំណួរទៅតាមការចាំបាច់នៃវគ្គសិក្សានីមួយៗ ដើម្បីឱ្យសិក្ខាកាមបំពេញ ។ ការធ្វើតេស្តវាស់ស្ទង់សមត្ថភាពចំណេះដឹង និង ជំនាញមូលដ្ឋាននេះ អាចត្រូវអនុវត្ត ឬមិនចាំបាច់អនុវត្ត គឺអាស្រ័យទៅតាមលក្ខណៈសម្បត្តិរបស់សិក្ខាកាមគោលដៅនៃវគ្គសិក្សានីមួយៗ ។

**(២). ការត្រួតពិនិត្យប្រសិទ្ធភាពនៃដំណើរការវគ្គបណ្ដុះបណ្ដាល:** គឺជាការវាយតម្លៃអំពីភាពពេញចិត្តរបស់សិក្ខាកាមចំពោះមាតិកានៃមុខវិជ្ជា, ខ្លឹមសារនៃប្រធានបទ, គ្រូឧទ្ទេស, វិធីសាស្ត្រ, ឯកសារបង្រៀន, កម្មវិធី, ទីតាំង, ថ្នាក់រៀន, សម្ភារឧបទេស និងការសម្របសម្រួលទូទៅដែលធ្វើឱ្យដំណើរការរៀនសូត្រអាចប្រព្រឹត្តទៅបានរលូន និង ជួយធ្វើឱ្យសិក្ខាកាមទទួលបានចំណេះដឹង និងជំនាញតាមការរំពឹងទុក ។ វិធីសាស្ត្រត្រួតពិនិត្យប្រសិទ្ធភាពនៃដំណើរការបណ្ដុះបណ្ដាលនេះ អាចប្រព្រឹត្តទៅដោយប្រើប្រាស់កម្រងសំណួរដែលលក្ខណៈជារចនាសម្ព័ន្ធត្រឹមត្រូវ សម្រាប់ឱ្យសិក្ខាកាមបំពេញ នៅចុងបញ្ចប់វគ្គបណ្ដុះបណ្ដាលនីមួយៗ ។ វិធីនេះនឹងជួយឱ្យយើងអាចវាយតម្លៃពីសេចក្ដីពេញចិត្តរបស់សិក្ខាកាមចំពោះវគ្គសិក្សា និង ចំណុចខ្វះចន្លោះដែលស្ថាប័នផ្ដល់សេវាបណ្ដុះបណ្ដាល ត្រូវកែលម្អដើម្បីឱ្យការរៀបចំលើកក្រោយៗ ទៀតកាន់តែប្រសើរ ។

**(៣). ការត្រួតពិនិត្យកម្រិតចំណេះដឹង និងជំនាញបច្ចេកទេសដែលសិក្ខាកាមទទួលបាន:** គឺជាវាយតម្លៃអំពីកម្រិតនៃការយល់ដឹងរបស់សិក្ខាកាមនៅមុន និង ក្រោយពេលបញ្ចប់វគ្គសិក្សា ។ ការវាស់ស្ទង់នេះនឹងត្រូវធ្វើឡើងតាមរយៈការប្រឡងបញ្ចប់ ឬ ការសម្ភាសផ្ទាល់ជាមួយសិក្ខាកាមដែលបានទទួលការបណ្តុះបណ្តាល ឬ អ្នកទទួលខុសត្រូវនៃអង្គភាពការងាររបស់សិក្ខាកាម ឬបុគ្គលិកដែលជាសហសេវិករបស់សិក្ខាកាម ដើម្បីបញ្ជាក់ថាការងាររបស់សិក្ខាកាមមានការអភិវឌ្ឍឈានឡើង ហើយបុគ្គលិកដែលជាសហសេវិករបស់សិក្ខាកាមនោះ ក៏មានការពេញចិត្តជាមួយសិក្ខាកាមនោះផងដែរ ពិសេស គឺបានជួយសម្រេចគោលដៅរបស់អង្គភាព ក្នុងក្របខណ្ឌនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

**(៤). ការត្រួតពិនិត្យអំពីការប្រើប្រាស់ចំណេះដឹងនិងជំនាញដែលទទួលបានពីការបណ្តុះបណ្តាល:** គឺជាការវាយតម្លៃអំពីប្រសិទ្ធភាពនៃការប្រើប្រាស់ចំណេះដឹង និងជំនាញឯកទេសដែលសិក្ខាកាមទទួលបានពីវគ្គបណ្តុះបណ្តាល ។ ការវាយតម្លៃអំពីការប្រើប្រាស់ចំណេះដឹង និងជំនាញនេះ អាចប្រព្រឹត្តទៅតាមរយៈការសម្ភាសជាមួយថ្នាក់ដឹកនាំអង្គភាពថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័ន ឬ ជាមួយសិក្ខាកាមផ្ទាល់ ឬ ជាមួយសហសេវិករបស់សិក្ខាកាម ។ ការវាយតម្លៃអំពីការប្រើប្រាស់ជំនាញបច្ចេកទេសអាចនឹងត្រូវអនុវត្តតាមរយៈការវាស់វែងលទ្ធផលនៃការអនុវត្តការងារ និង ការសាកល្បងការងាររបស់អតីតសិក្ខាកាម ។ ការវាយតម្លៃអាចផ្តោតទៅលើចំណុចសំខាន់ពីរ គឺ: **ផលប៉ះពាល់ទៅលើលក្ខខណ្ឌ និង បរិយាកាសការងារ សម្រាប់ការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** និង**សមិទ្ធកម្មការងាររបស់សិក្ខាកាមនៅមុន និង ក្រោយការបណ្តុះបណ្តាល** ។

**(៥). ការត្រួតពិនិត្យអំពីវិសាលភាពនៃការអភិវឌ្ឍសមត្ថភាព:** គឺជាការវាយតម្លៃអំពីវិសាលភាពនៃការអភិវឌ្ឍធនធានមនុស្ស ដែលជាវិសាលភាពនៃអត្ថប្រយោជន៍ទទួលបានពីការបណ្តុះបណ្តាល ពោលគឺមិនបញ្ចប់ត្រឹមសិក្ខាកាម និងការងាររបស់គាត់នៅក្នុងអង្គភាពប៉ុណ្ណោះទេ ប៉ុន្តែលើសពីនេះ អត្ថប្រយោជន៍នោះបានបន្តលាតសន្ធឹងកាន់តែទូលាយ តាមរយៈការចែករំលែកចំណេះដឹងរបស់អតីតសិក្ខាកាមទៅកាន់អ្នកទីបី ឬទីបួនថែមទៀត ក្នុងរូបភាពជាសិក្ខាសាលាផ្សព្វផ្សាយជាដើម ។

## ៨. សេចក្តីសន្និដ្ឋាន

ផ្អែកលើលទ្ធផលនៃការវាយតម្លៃតម្រូវការបណ្តុះបណ្តាលនិងវិក្រឹតការ និងបទពិសោធន៍កន្លងមក ផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាពនេះ ចាំបាច់ត្រូវធ្វើបច្ចុប្បន្នកម្មឡើងវិញ ដើម្បីឱ្យសមស្របទៅនឹងតម្រូវការនៃការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅដំណាក់កាលទី ៣ ។ ដើម្បីសម្រេចចក្ខុវិស័យ បេសកកម្ម គោលបំណង និងគោលដៅដែលបានគ្រោងទុក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ចេញនូវយុទ្ធសាស្ត្រសំខាន់ៗ ៣ ដែលប្រទាក់ក្រឡាបំពេញឱ្យគ្នាទៅវិញទៅមក និង គាំទ្រដោយចំណុចដៅជាយុទ្ធសាស្ត្រ ដូចមាននៅក្នុង **ឧបសម្ព័ន្ធ ១** និង ខ្លឹមសារសង្ខេបខាងលើ ។

**យុទ្ធសាស្ត្រទី ១** គ្របដណ្តប់លើការអភិវឌ្ឍសមត្ថភាពស្ថាប័នទទួលបន្ទុកការបណ្តុះបណ្តាលនិងវិក្រឹតការ ដោយផ្តោតទៅលើសកម្មភាពកសាងនិងអភិវឌ្ឍសមត្ថភាព និង ការធ្វើទំនើបកម្ម បង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារបរិក្ខាគាំទ្រការស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការ ។ **យុទ្ធសាស្ត្រទី ២** គ្របដណ្តប់លើការពង្រឹងពង្រីកការស្រាវជ្រាវនិងអភិវឌ្ឍ ដែលប្រព្រឹត្តទៅតាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន ក្រសួងស្ថាប័ន និងដៃគូពាក់ព័ន្ធដើម្បីវិភាគវាយតម្លៃនិងកំណត់តម្រូវការបណ្តុះបណ្តាលនិងវិក្រឹតការ, ប្រមូលធាតុចូលសម្រាប់ធ្វើទំនើបកម្មកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ ។ **យុទ្ធសាស្ត្រទី ៣** គ្របដណ្តប់លើការអនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការ ដែលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ

និងគ្រប់ជ្រុងជ្រោយ រួមនឹងការវាយតម្លៃគុណភាព ប្រសិទ្ធភាព និង សមិទ្ធកម្ម សំដៅធ្វើឱ្យសិក្ខាកាមគោលដៅ មានចំណេះដឹង ជំនាញវិជ្ជាជីវៈ និងសមត្ថភាពគ្រប់គ្រាន់ សម្រាប់អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ ។

ការអនុវត្តផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ នឹងត្រូវប្រព្រឹត្តទៅក្រោមការដឹកនាំផ្ទាល់របស់រដ្ឋមន្ត្រី កសហវ តាមរយៈក្រុមការងារកសាងសមត្ថភាព ដែលដឹកនាំនិងណែនាំកម្រិតនយោបាយពីរដ្ឋលេខាធិការទទួលបន្ទុក និង ចូលរួមអនុវត្តដោយស្ថាប័នតួអង្គពាក់ព័ន្ធ រួមមាន ***ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងស្ថាប័ន, ដៃគូអភិវឌ្ឍន៍ និងដៃគូសហប្រតិបត្តិការ*** ។ ក្នុងទិដ្ឋភាពបច្ចេកទេស ស្ថាប័នតួអង្គអនុវត្តន៍ចំនួនបីប្រភេទគឺ ***ស្ថាប័នផ្តល់សេវាបណ្តុះបណ្តាលនិងវិក្រឹតការ, ស្ថាប័នទទួលសេវាបណ្តុះបណ្តាលនិងវិក្រឹតការ និង ស្ថាប័នគាំទ្រដំណើរការបណ្តុះបណ្តាលនិងវិក្រឹតការ*** នឹងត្រូវចូលរួម សហការ គាំទ្រ និងអនុវត្តផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ តាមយន្តការចលនការប្រព័ន្ធតួអង្គ ដែលរួមមាន ***អគហ, អគ្គលេខាធិការដ្ឋាន, អគ្គនាយកដ្ឋាននិងអង្គភាពក្រោមឱវាទ កសហវ, ក្រសួងស្ថាប័ននិងមន្ទីរជំនាញ-អង្គភាពក្រោមឱវាទ, លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, ស្ថាប័ននីតិបញ្ញត្តិ អាជ្ញាធរសវនកម្មជាតិ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ, ដៃគូអភិវឌ្ឍន៍ និង ដៃគូសហប្រតិបត្តិការជាតិ-អន្តរជាតិ និង មានវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាតួអង្គស្នូលសម្រាប់ផ្តល់សេវានិងសម្របសម្រួលការផ្តល់សេវាបណ្តុះបណ្តាលនិងវិក្រឹតការ*** ។

ទន្ទឹមនេះ ប្រព័ន្ធរបាយការណ៍ប្រចាំត្រីមាស ឆមាស ប្រចាំឆ្នាំ របាយការណ៍ពាក់កណ្តាលអណ្តត្តិ និង របាយការណ៍ចុងអណ្តត្តិ នឹងត្រូវរៀបចំ សម្រាប់ការត្រួតពិនិត្យ និង វាយតម្លៃអំពីវឌ្ឍនភាព គុណភាព ប្រសិទ្ធភាព និងសមិទ្ធផល នៃការអនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការ សម្រាប់គោរពរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យសម្រេច និង ផ្តល់ការណែនាំ ។ ការត្រួតពិនិត្យនិងវាយតម្លៃនេះ នឹងត្រូវធ្វើឡើងក្រោមការដឹកនាំ និងណែនាំតម្រង់ទិសជាយុទ្ធសាស្ត្រកម្រិតនយោបាយពីរដ្ឋលេខាធិការទទួលបន្ទុកការកសាងនិងអភិវឌ្ឍសមត្ថភាព និង ក្រោមការសម្របសម្រួលបច្ចេកទេស និង ដំណើរការអនុវត្តពីវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការចូលរួម សហការ និង គាំទ្រពីគ្រប់តួអង្គពាក់ព័ន្ធ ។

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់គាំទ្រដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ គឺបានពី ***(១). ថវិការដ្ឋក្នុងក្របខណ្ឌថវិកាកម្មវិធីនិងអង្គភាពថវិកា, (២). ថវិការបស់ដៃគូអភិវឌ្ឍន៍ក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង (៣). ថវិការបស់ដៃគូសហប្រតិបត្តិការក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការទ្វេភាគី ឬ ពហុភាគី*** ដោយអនុលោមទៅតាមការសម្រេច និង ការណែនាំជាគោលការណ៍ពីរដ្ឋមន្ត្រី កសហវ និង លក្ខខណ្ឌនៃគម្រោងកម្មវិធីនៃកិច្ចសហប្រតិបត្តិការនីមួយៗ ។ ចំពោះនីតិវិធីសម្រាប់ការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធាន គឺត្រូវអនុវត្តទៅតាមគោលការណ៍ច្បាប់ នីតិវិធី និងបទប្បញ្ញត្តិជាធរមានរបស់ កសហវ និងតាមលក្ខខណ្ឌជាធរមានរបស់ដៃគូនៃកិច្ចសហប្រតិបត្តិការ ។

រួមសេចក្តីមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសង្ឃឹមជឿជាក់ថា ផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ នឹងក្លាយជាត្រីវិស័យតម្រង់ទិសស្នូល សម្រាប់ការកសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នពាក់ព័ន្ធ លើជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីចូលរួមចំណែកក្នុងការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ ឱ្យសម្រេចជោគជ័យប្រកបដោយប្រសិទ្ធភាព និងចីរភាព ៕

## ឧបសម្ព័ន្ធ ១:
## តារាងផែនការសកម្មភាពស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាព (ឆ្នាំ ២០១៧-២០២០)
## សម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងស្ថាប័ន

| វិធានការ | សកម្មភាព | ពេលវេលាអនុវត្ត (២០១៧-២០២០) | | | | ស្ថាប័ននិងតួអង្គអនុវត្តន៍ |
|---|---|---|---|---|---|---|
| | | ១៧ | ១៨ | ១៩ | ២០ | |
| **យុទ្ធសាស្ត្រទី ១: ការអភិវឌ្ឍសមត្ថភាពស្ថាប័ន** | | | | | | |
| *១.១. ការពង្រឹង និងបង្កើនធនធានមនុស្សសម្រាប់អនុវត្តការស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការ (ចំនួន និងសមត្ថភាព: មន្ត្រីបច្ចេកទេស រដ្ឋបាល សម្របសម្រួល គាំទ្រ និង គ្រូបង្គោល និង គ្រូឧទ្ទេស.....)* | ១. ពង្រឹងនិងពង្រីកសមត្ថភាពមន្ត្រីបច្ចេកទេសនិងសម្របសម្រួលជាមួយក្រសួងស្ថាប័នដែលត្រូវទទួលបណ្តុះបណ្តាលនិងវិក្រឹតការ | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និងក្រសួង ស្ថាប័ន |
| | ២. ជ្រើសរើស រៀបចំ ពង្រឹង និងពង្រីកសមត្ថភាពគ្រូឧទ្ទេស គ្រូបង្គោល និងសាស្ត្រាចារ្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់អនុវត្តការងារស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាពមន្ត្រីរាជការ | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និងក្រសួង ស្ថាប័ន |
| | ៣. រៀបចំ និងសម្របសម្រួលការផ្ទេរ និងចែករំលែកចំណេះដឹង ជំនាញ និងឧត្តមានុវត្តន៍ពីទីប្រឹក្សានិងអ្នកជំនាញការជាតិនិងអន្តរជាតិ ជូនដល់មន្ត្រីរាជការ គ្រូបង្គោល គ្រូឧទ្ទេស និង សាស្ត្រាចារ្យ | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និងក្រសួង ស្ថាប័ន |
| | ៤.វាយតម្លៃសមិទ្ធផល និងស្នាដៃដែលមន្ត្រីបច្ចេកទេស សម្របសម្រួលជាមួយគ្រូឧទ្ទេស គ្រូបង្គោល និងសាស្ត្រាចារ្យសម្រេចបានលើការងារស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការ សម្រាប់ផ្តល់ការលើកទឹកចិត្ត ។ | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និងក្រសួង ស្ថាប័ន |
| | ៥.សិក្សាលទ្ធភាពដើម្បីបង្កើនការគាំទ្រថវិកាសម្រាប់អនុវត្តការស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការ ឆ្លើយតបតម្រូវការកសាងនិងអភិវឌ្ឍសមត្ថភាព | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និងក្រសួង ស្ថាប័ន |

| | | | | | | |
|---|---|---|---|---|---|---|
| *១.២. ការធ្វើទំនើបកម្មនិងបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារូបវ័ន្ត គាំទ្រការស្រាវជ្រាវ ការបណ្តុះបណ្តាលនិងវិក្រឹតការ* | **១.** រៀបចំ និង កែលម្អហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងបំពាក់សម្ភារូបវ័ន្តទំនើបចាំបាច់គ្រប់គ្រាន់ និងសមស្រប សម្រាប់គាំទ្រដំណើរការអនុវត្តកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និង ក្រសួងស្ថាប័ន |
| | **២.** រៀបចំកែលម្អ គ្រប់គ្រង និង អភិវឌ្ឍប្រព័ន្ធទិន្នន័យ (Database) ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការ | x | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និង ក្រសួងស្ថាប័ន |
| | **៣.** រៀបចំ គ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងបណ្ណាល័យតាមបែបព័ត៌មានវិទ្យា | x | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ |
| | **៤.** រៀបចំ គ្រប់គ្រង និងអភិវឌ្ឍគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយតាមបណ្តាញសង្គម | x | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ |
| | **៥.** សិក្សាលទ្ធភាពដើម្បីបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងបង្កើនថវិកាគាំទ្រការស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការ | x | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ |
| **យុទ្ធសាស្ត្រទី ២: ការពង្រឹងពង្រីកការស្រាវជ្រាវនិងអភិវឌ្ឍ តាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការ ដើម្បីធ្វើទំនើបកម្មកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការពាក់ព័ន្ធការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ** | | | | | | |
| ***២.១. ការវាយតម្លៃតម្រូវការជាក់លាក់សម្រាប់ការស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាពមន្ត្រីរាជការ*** | **១.** រៀបចំផែនការ ឧបករណ៍ និង កំណត់វិធីសាស្ត្រសម្រាប់ការវាយតម្លៃតម្រូវការ នៃការស្រាវជ្រាវ បណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាពដោយសហការជិតស្និទ្ធជាមួយគ្រប់តួអង្គពាក់ព័ន្ធ | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និង ក្រសួងស្ថាប័ន |
| | **២.** សម្របសម្រួល និង អនុវត្តផែនការវាយតម្លៃតម្រូវការនៃការស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាព | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និង ក្រសួងស្ថាប័ន |
| | **៣.** ប្រមូលសរុប និង វិភាគទិន្នន័យ សម្រាប់កំណត់និងវាយតម្លៃឱ្យបានច្បាស់លាស់អំពីតម្រូវការ នៃការស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាព | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និង ក្រសួងស្ថាប័ន |

| | | | | | | |
|---|---|---|---|---|---|---|
| ***២.២. ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍកម្មវិធី មុខជំនាញ ប្រធានបទ ឯកសារ និងវិធីសាស្ត្របណ្តុះបណ្តាល និងវិក្រឹតការ*** | **១.** សិក្សាស្រាវជ្រាវនិងប្រមូលធាតុចូលអំពីការអនុវត្តគោលនយោបាយ និងកម្មវិធីពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពីគ្រប់អគ្គលេខាធិការដ្ឋាន/ អគ្គនាយកដ្ឋាន និងអង្គភាពនៃ កសហវ និង ក្រសួងស្ថាប័នពាក់ព័ន្ធ | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និង ក្រសួងស្ថាប័ន |
| | **២.** រៀបចំ និង ធ្វើទំនើបកម្មកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ (ប្រធានបទ ឯកសារ វិធីសាស្ត្របណ្តុះបណ្តាល....) | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និង ក្រសួងស្ថាប័ន |
| | **៣.** ចងក្រង បោះពុម្ព និង ផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវ | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និងក្រសួង ស្ថាប័ន |
| ***២.៣. ការពង្រឹងពង្រីកការស្រាវជ្រាវ បណ្តុះបណ្តាលនិងវិក្រឹតការ តាមរយៈកិច្ចសហប្រតិបត្តិការ ជាមួយដៃគូជាតិ-អន្តរជាតិ*** | **១.** ពង្រឹងនិងពង្រីកកិច្ចសហការជាមួយអគ្គលេខាធិការដ្ឋាន/ គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ នៃ កសហវ ក្រសួងស្ថាប័ន និង ដៃគូពាក់ព័ន្ធក្នុងស្រុក | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និង ក្រសួងស្ថាប័ន |
| | **២.** ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយនឹងស្ថាប័ន និង ដៃគូអន្តរជាតិ | x | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និង ក្រសួងស្ថាប័ន |
| **យុទ្ធសាស្ត្រទី ៣: ការបណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាព** | | | | | | |
| ***៣.១. ការវាយតម្លៃកម្រិតចំណេះដឹងមូលដ្ឋាន និង សមត្ថភាពជំនាញពាក់ព័ន្ធរបស់សិក្ខាកាម និង កំណត់វិធីសាស្ត្រនិងបច្ចេកទេសច្បាស់លាស់*** | **១.** កំណត់ឱ្យបានជាក់លាក់អំពីកម្រិតចំណេះដឹងមូលដ្ឋាន និងសមត្ថភាពជំនាញពាក់ព័ន្ធរបស់សិក្ខាកាម | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និងក្រសួងស្ថាប័ន |
| | **២.** កំណត់វិធីសាស្ត្រនិងបច្ចេកទេសសមស្រប សម្រាប់ការបណ្តុះបណ្តាលនិងវិក្រឹតការ | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និងក្រសួងស្ថាប័ន |

| | | | | | | |
|---|---|---|---|---|---|---|
| *មុននឹងអនុវត្តការបណ្តុះបណ្តាល និងវិក្រឹតការ* | ៣. សម្របសម្រួល និង បំពាក់បំប៉នអំពីវិធីសាស្ត្រនិងបច្ចេកទេស នៃការបណ្តុះបណ្តាល និងវិក្រឹតការជូនដល់គ្រូបង្គោល គ្រូឧទ្ទេស និង ក្រុមការងារសម្របសម្រួលវគ្គបណ្តុះបណ្តាល | | | | | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធ នៃ កសហវ និងក្រសួងស្ថាប័ន |
| *៣.២.ការអនុវត្តកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការដែលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ* | ១. រៀបចំ និង សម្របសម្រួលកម្មវិធី (មុខវិជ្ជា ប្រធានបទ) បណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាព ឆ្លើយតបទៅនឹងតម្រូវការរបស់ក្រសួងស្ថាប័ន | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធ នៃ កសហវ និងក្រសួងស្ថាប័ន |
| | ២. លើកកម្ពស់កិច្ចសហការជាមួយអគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងស្ថាប័នក្នុងការអនុវត្តផែនការ និងកម្មវិធីបណ្តុះបណ្តាល | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធ នៃ កសហវ និងក្រសួងស្ថាប័ន |
| | ៣. អនុវត្តដំណើរការបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាពជូនដល់មន្ត្រីរាជការនៃគ្រប់ក្រសួងស្ថាប័ន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និង សហគ្រាសសាធារណៈរបស់រដ្ឋ | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធ នៃ កសហវ និងក្រសួងស្ថាប័ន |
| | ៤. រៀបចំនិងអនុវត្តកម្មវិធីបណ្តុះបណ្តាលជាស៊េរី កម្រិតវិញ្ញាបនបត្រសម្រាប់ក្រុមមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ឬ អ្នកដែលត្រូវតែងតាំង ប្រគល់ភារកិច្ចជាមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ នៃគ្រប់ក្រសួងស្ថាប័ន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈរបស់រដ្ឋ | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធ នៃ កសហវ និងក្រសួងស្ថាប័ន |
| *៣.៣ ការវាយតម្លៃគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មនៃការបណ្តុះបណ្តាល និង វិក្រឹតការ* | ១. រៀបចំយន្តការ ផែនការ ឧបករណ៍ និង កំណត់វិធីសាស្ត្រសម្រាប់ការវាយតម្លៃគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មនៃការបណ្តុះបណ្តាល និងវិក្រឹតការ | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធ នៃ កសហវ និងក្រសួងស្ថាប័ន |
| | ២. សម្របសម្រួល និង អនុវត្តផែនការវាយតម្លៃគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មនៃការបណ្តុះបណ្តាលនិងវិក្រឹតការ | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធ នៃ កសហវ និងក្រសួងស្ថាប័ន |
| | ៣. ប្រមូលសរុប និងវិភាគទិន្នន័យ សម្រាប់កំណត់និងវាយតម្លៃឱ្យបានច្បាស់លាស់អំពីគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មនៃការបណ្តុះបណ្តាល និងវិក្រឹតការ | X | x | x | x | វសហនិងអគ្គនាយកដ្ឋានពាក់ព័ន្ធ នៃ កសហវ និងក្រសួងស្ថាប័ន |

## ឧបសម្ព័ន្ធ ២: តារាងគោលដៅនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង តម្រូវការមុខជំនាញសម្រាប់បណ្តុះបណ្តាលនិងពង្រីកការសមត្ថភាពមន្ត្រីរាជការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័ន

| ដំណាក់កាលទី ១ | ដំណាក់កាលទី ២ | ដំណាក់កាលទី ៣ | ដំណាក់កាលទី ៤ |
|---|---|---|---|
| **១. គោលដៅនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:** | | | |
| **ភាពជឿទុកចិត្តបាននៃថវិកា** តាមរយៈការកសាងទំនុកចិត្តលើថវិកាដោយផ្តល់ធនធានដល់អ្នកគ្រប់គ្រងថវិកាប្រកបដោយភាពជឿជាក់ និងអាចទស្សទាយបានជាមុន ។ | **គណនេយ្យភាពហិរញ្ញវត្ថុ** តាមរយៈការកែលម្អថ្នាក់ដំបូងលើការត្រួតពិនិត្យផ្ទៃក្នុង និង ការដាក់ឱ្យអ្នកគ្រប់គ្រងមានគណនេយ្យភាពជាមួយនឹងការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បង និងអង្គភាពថវិកា និងការអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមព័ត៌មានវិទ្យាជំហានទី ១ ។ | **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** តាមរយៈការពង្រីកការនុវត្តថវិកាកម្មវិធីពេញសាកល្បង និងអង្គភាពថវិកា ការអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមព័ត៌មានវិទ្យាជំហានទី ២ និង កែលម្អទំនាក់ទំនងរវាងគោលនយោបាយអាទិភាព និងការរៀបចំ ផែនការនិងអនុវត្តថវិកា។ | **គណនេយ្យភាពចំពោះសមិទ្ធកម្ម ឬលទ្ធផល** តាមរយៈសមាហរណកម្មលើគណនេយ្យភាពនិងដំណើរ ការពិនិត្យឡើងវិញទាំងហិរញ្ញវត្ថុ និង ការប្រតិបត្តិ ។ |
| **២. តម្រូវការមុខជំនាញក្នុងការអភិវឌ្ឍសមត្ថភាព** | | | |
| -ការធ្វើផែនការសាច់ប្រាក់<br>-ការគ្រប់គ្រងសាច់ប្រាក់<br>-ការគូសគ្រោងតារាងគណនី<br>-យុទ្ធសាស្ត្របំណុល<br>-ការគ្រប់គ្រងបំណុល<br>-ការព្យាករណ៍<br>-ការអភិវឌ្ឍគោលន.ប ចំណូល<br>-ការធ្វើលទ្ធកម្ម IT<br>-ការរៀបចំអភិក្រមការងារ<br>- មូលដ្ឋានគ្រឹះនៃថវិកា និង ការអនុវត្តសម្រាប់វិស័យសាធារណៈ<br>- ទស្សនាទាន និង ការអនុវត្តកិច្ច លទ្ធកម្មសាធារណៈ<br>- គណនេយ្យសាធារណៈ | -ការវិភាគថវិកា<br>- ការរៀបចំថវិកា អនុវត្ត និង ត្រួតពិនិត្យថវិកា<br>-ប្រតិភូកម្មថវិកាដោយមានប្រសិទ្ធភាព<br>- គោលការណ៍ណែនាំ និង នីតិវិធីនៃការអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកា<br>-ការរៀបចំ វិភាគ និង បំណកស្រាយរបាយការណ៍ហិរញ្ញវត្ថុ<br>-ការប្រើប្រាស់តារាងគណនេយ្យ<br>-ការអភិវឌ្ឍផែនការសវនកម្ម<br>- នីតិវិធី-បទប្បញ្ញត្តិលទ្ធកម្មសាធារណៈ<br>-ការស្វែងយល់ពីប្រព័ន្ធ FMIS<br>-ការប្រើប្រាស់ប្រព័ន្ធ FMIS<br>-ការគ្រប់គ្រងការផ្លាស់ប្តូរ និង FMIS | -ការរៀបចំថវិកាពហុឆ្នាំ<br>- ការផ្សារភ្ជាប់ថវិកាជាមួយនឹងគោលនយោបាយ<br>-ការវិភាគគម្រោងកម្មវិធី និងការរៀបចំផែនការថវិកាឆ្លើយតប<br>-អាទិភាវូបនីយកម្មជម្រើសគោលនយោបាយសម្រាប់ថវិកាឆ្លើយតប<br>-ការកំណត់សូចនាករគោលដៅ<br>-គោលការណ៍ណែនាំ និង នីតិវិធីនៃការអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកា<br>-នីតិវិធី និង បទប្បញ្ញត្តិអនុវត្តន៍ស្តីពីលទ្ធកម្មសាធារណៈ<br>-ថវិកា គណនេយ្យ លទ្ធកម្ម និងFMIS<br>- ការវិភាគវាយតម្លៃគម្រោងភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន<br>- ការវិភាគនិងព្យាករណ៍សេដ្ឋកិច្ច .... | - ការកំណត់សូចនាករសមិទ្ធកម្ម<br>- ការធ្វើអាទិភាវូបណីយកម្មកម្មវិធី<br>- ការវិភាគនានាភាព ចំពោះលទ្ធផល ឬសមិទ្ធកម្ម<br>- ការប្រឹក្សាយោបល់ដ៏មានប្រសិទ្ធភាពអំពីថវិកា<br>- ការរាយការណ៍ និង អនុសាសន៍<br>- មេរៀនបទពិសោធន៍អំពីការអនុវត្តថវិកាកម្មវិធីពេញលេញ<br>- គណនេយ្យភាពចំពោះសាធារណជន<br>- ការវាស់វែងគណនេយ្យភាពចំពោះលទ្ធផល ឬសមិទ្ធកម្ម<br>- ....... |

# ឧបសម្ព័ន្ធ ៣: គំនូសបំព្រួញចលនការនៃប្រព័ន្ធតួអង្គ និង យន្តការអនុវត្តន៍ការកសាងនិងអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(ដំណាក់កាលទី ៣)

**រដ្ឋមន្ត្រី កសហវ**

*ផ្តល់មគ្គទេសក៍ដឹកនាំ និងណែនាំ, ផ្តល់គោលការណ៍ និង អនុម័តលើគម្រោងផែនការ និងថវិកាសម្រាប់គាំទ្រការអនុវត្ត*

ក្របខណ្ឌយុទ្ធសាស្ត្រនៃការកសាងនិងអភិវឌ្ឍសមត្ថភាព គឺ ត្រូវបន្តជំរុញ : (ក). ការអភិវឌ្ឍជំនាញ និង (ខ). ការពង្រីកវិសាលភាពនៃវិធីសាស្ត្រអភិវឌ្ឍសមត្ថភាព តាមរយៈអភិក្រមជាយុទ្ធសាស្ត្រ:

១. ការអភិវឌ្ឍសមត្ថភាពស្ថាប័ន

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អគហ)**
- សម្របសម្រួលនិងគាំទ្រផ្នែកថវិកា
- សហការអនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការ
- សហការផ្តល់អ្នកជំនាញជាគ្រូឧទ្ទេស ឬវាគ្មិន
- សម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រការកសាងនិងអភិវឌ្ឍសមត្ថភាព

**ក្រុមការងារកសាងសមត្ថភាព**
- ដឹកនាំ និងណែនាំតម្រង់ទិសជាយុទ្ធសាស្ត្រលើផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាព
- ធានា និងគាំទ្រឱ្យការបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាពមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ
- ដឹកនាំ និងណែនាំតម្រង់ទិសការវាយតម្លៃតម្រូវការ និងប្រសិទ្ធិភាពនៃការបណ្តុះបណ្តាលនិងវិក្រឹតការ
- ដឹកនាំ និងណែនាំទម្រង់ទិសការរៀបចំធ្វើបច្ចុប្បន្នកម្មឯកសារផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាព

**លេខាធិការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ និង លេខាធិការដ្ឋានកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ**
- សហការជាមួយ អគហ, វសហ, និងក្រសួងស្ថាប័នដើម្បីកំណត់ចំណុចត្រួតស៊ីគ្នា ប្រទាក់ក្រឡា និងបំពេញឱ្យគ្នាអំពីតម្រូវការបណ្តុះបណ្តាលនិងវិក្រឹតការ
- សហការជាមួយ អគហ ដើម្បីសម្របសម្រួលជាមួយ វសហ និងតួអង្គផ្តល់ការបណ្តុះបណ្តាលផ្សេងទៀត ក្នុងការរៀបចំ និងអនុវត្តការបណ្តុះ បណ្តាលនិងវិក្រឹតការ
- សម្របសម្រួល និង សហការជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ក្នុងការគាំទ្រខាងស្មារតី ថវិកា និង បច្ចេកទេស

**អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ កសហវ**
- ទទួលសេវាបណ្តុះបណ្តាលនិងវិក្រឹតការ
- សហការអនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការ
- សហការផ្តល់មន្ត្រីជំនាញជាគ្រូឧទ្ទេស-គ្រូបង្គោល-វាគ្មិន
- ស្នើសុំនិងទទួលការបណ្តុះបណ្តាលនិងវិក្រឹតការ

**វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
- រៀបចំផែនការបណ្តុះបណ្តាលនិងវិក្រឹតការ
- សម្របសម្រួល និង អនុវត្តការបណ្តុះបណ្តាល មានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ
- គ្រប់គ្រង និងសម្របសម្រួលការអនុវត្តផែនការបណ្តុះបណ្តាលនិងវិក្រឹតការ
- គ្រប់គ្រង និង សម្របសម្រួលកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ
- ជ្រើសរើស បំពាក់បំប៉ន ចាត់ចែង និងសម្របសម្រួលគ្រូឧទ្ទេស គ្រូបង្គោល សាស្ត្រាចារ្យ វាគ្មិន និង អ្នកសម្របសម្រួល សម្រាប់អនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការ
- អនុវត្តការស្រាវជ្រាវ ប្រមូលទិន្នន័យ និងបោះពុម្ពផ្សាយលទ្ធផល
- សម្របសម្រួល ស្នើ និងគ្រប់គ្រងថវិកាស្របតាមគោលការណ៍
- ស្វែងរកជំនួយបច្ចេកទេស ហិរញ្ញវត្ថុនិងកិច្ចសហការប្រតិបត្តិការ
- វាយតម្លៃតម្រូវការ,គុណភាព,ប្រសិទ្ធភាព និង សមិទ្ធកម្ម នៃការបណ្តុះបណ្តាលនិងវិក្រឹតការ

**ដៃគូអភិវឌ្ឍន៍**
- សហការអនុវត្តការបណ្តុះបណ្តាល
- សហការ គាំទ្រផ្នែកហិរញ្ញវត្ថុ ស្មារតី និងបច្ចេកទេស
- ផ្តល់អ្នកជំនាញជា គ្រូឧទ្ទេស-គ្រូបង្គោល ឬវាគ្មិន
- សហការផ្តល់យោបល់ពីប្រសិទ្ធភាព និងគុណភាពនៃការបណ្តុះបណ្តាល និងវាយតម្លៃតម្រូវការបណ្តុះណ្តាល

**ស្ថាប័ននីតិបញ្ញត្តិ អាជ្ញាធរសវនកម្មជាតិ និងអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ**
- ទទួលសេវាបណ្តុះបណ្តាលនិងវិក្រឹតការ
- សហការអនុវត្តការបណ្តុះបណ្តាលនិងវិក្រឹតការ
- ចាត់បេក្ខភាពដើម្បីសិក្ខាកាមចូលរួមវគ្គបណ្តុះបណ្តាល
- ស្នើសុំនិងទទួលការបណ្តុះបណ្តាលនិងវិក្រឹតការ

**ក្រសួង ស្ថាប័នជំនាញ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល**
- ទទួលនិងសហការបណ្តុះបណ្តាលនិងវិក្រឹតការ
- ស្នើសុំការបណ្តុះបណ្តាលនិងវិក្រឹតការ
- ស្វែងរកប្រភពហិរញ្ញវត្ថុគាំទ្រការបណ្តុះបណ្តាល
- ចូលរួមវាយតម្លៃការបណ្តុះបណ្តាលនិងវិក្រឹតការ

**ស្ថាប័នដៃគូ**
- សហការអនុវត្តការបណ្តុះបណ្តាល
- សហការ គាំទ្រផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេស
- ផ្តល់គ្រូឧទ្ទេស-គ្រូបង្គោល ជំនាញការ និង
- សហការផ្តល់យោបល់ពីប្រសិទ្ធភាព និងគុណភាពនៃការបណ្តុះបណ្តាល និងវាយតម្លៃតម្រូវការបណ្តុះបណ្តាល

២. ការពង្រឹងពង្រីកការស្រាវជ្រាវនិងអភិវឌ្ឍ តាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការ ដើម្បីធ្វើទំនើបកម្មកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ ពាក់ព័ន្ធការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ

៣. ការបណ្តុះបណ្តាលនិងវិក្រឹតការ ដែលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ

## ឧបសម្ព័ន្ធ ៤: តារាងសមិទ្ធផលសំខាន់ៗនៃកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលអនុវត្តក្នុងអំឡុងឆ្នាំ ១៩៩៨ - ២០១៦

| ឆ្នាំ | ចំនួនវគ្គ | ចំនួនសិក្ខាកាម | កម្មវិធី | ក្រសួង/ស្ថាប័ន | មុខវិជ្ជា/ប្រធានបទ |
|---|---|---|---|---|---|
| **ផ្នែកទី១: ឆ្នាំ ១៩៩៨ - ២០០៣** | | | | | |
| **១៩៩៨** | ៥០ វគ្គ | ១៥០០នាក់ | វគ្គរយៈពេលខ្លី | នាយកដ្ឋានពាក់ព័ន្ធនៃកសហវ | -ជំនាញកុំព្យូទ័រ កម្រិតមូលដ្ឋាន និងមធ្យម (Basic and Intermediate Skills of Computer)<br>-ជំនាញកុំព្យូទ័រ កម្មវិធី Access 97<br>-ជំនាញកុំព្យូទ័រ កម្រិតមធ្យម (Intermediate Skills of Computer)<br>-គណនេយ្យហិរញ្ញវត្ថុ (Financial Accounting)<br>-ការគ្រប់គ្រងសេដ្ឋកិច្ច (Economic Management)<br>-ការវិភាគ និង ព្យាករណ៍សេដ្ឋកិច្ច (Economic Analysis and Forecasting)<br>-ទស្សនាទាននៃមីក្រូសេដ្ឋកិច្ច (Microeconomics Concept)<br>-ភាសាអង់គ្លេសទូទៅ (General English)<br>-ច្បាប់ស្តីពីអង្គភាពធុរកិច្ច (Law on Business Organization)<br>-ច្បាប់ស្តីពីប្រតិបត្តិការពាណិជ្ជកម្ម (Commercial Transaction Law) |
| | ១វគ្គ | ៣០នាក់ | វគ្គរយៈពេលវែង | កសហវ | -ភាពជាអ្នកដឹកនាំ និង ការគ្រប់គ្រង (Leadership and Management Skills) |
| | ១៥ វគ្គ | ៦៧៥នាក់ | សិក្ខាសាលា | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -ប្រព័ន្ធពន្ធគយកម្ពុជា (Cambodian Custom System)<br>-ការវិភាគ និង ការគ្រប់គ្រងសេដ្ឋកិច្ច (Economic Analysis and Management)<br>-ការគ្រប់គ្រងបំណុលសាធារណៈ (Public Debt Management)<br>-ការធ្វើសមាហរណកម្មកម្ពុជា ទៅក្នុងប្រព័ន្ធពន្ធអាស៊ាន (The Integration of Cambodia into ASEAN Tax System)<br>-ការអភិវឌ្ឍប្រព័ន្ធធនាគារ (Banking System Development) |

| | | | | | |
|---|---|---|---|---|---|
| | | | | | -ច្បាប់ពាណិជ្ជកម្មនៃកម្ពុជា ថ្មី (New Commercial Law of Cambodia)<br>-គោលនយោបាយពន្ធ (Tax Policy)<br>-ការគ្រប់គ្រងសេដ្ឋកិច្ច (Economic Management)<br>-ការចុះបញ្ជីអាករលើតម្លៃបន្ថែម (Value Added Tax Registration)<br>-វិបត្តិកលិយុគហិរញ្ញវត្ថុអាស៊ី និង ផលប៉ះពាល់មកលើប្រទេសកម្ពុជា (Asian Financial Crisis and its Possible Impacts on Cambodia)<br>-ការកៀរគរហិរញ្ញប្បទានដើម្បីកំណើនសេដ្ឋកិច្ច (Mobilization for Economic Growth)<br>-ការបណ្តុះបណ្តាលគ្រូឧទ្ទេស (Training of Trainers)<br>-ប្រព័ន្ធអាករលើតម្លៃបន្ថែម (Value Added Tax System)<br>-ការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច (Launching of Economic Advisory Team) |
| **១៩៩៩** | ១០៨ វគ្គ | ២១៧០នាក់ | វគ្គរយៈពេលខ្លី | នាយកដ្ឋានពាក់ព័ន្ធនៃកសហវ | -ការគ្រប់គ្រងសេដ្ឋកិច្ច (Economics Management)<br>-ការគ្រប់គ្រងហិរញ្ញវត្ថុ (Financial Management)<br>-គណនេយ្យ (Accounting)<br>-ច្បាប់ (Law)<br>-ជំនាញកុំព្យូទ័រ (Computer Skills)<br>-ភាសាអង់គ្លេស (English language) |
| | ១ វគ្គ | ២០ នាក់ | វគ្គរយៈពេលវែង | នាយកដ្ឋានពាក់ព័ន្ធនៃកសហវ | -ជំនាញភាពជាអ្នកដឹកនាំ និង ការគ្រប់គ្រង សម្រាប់មន្ត្រីគយអាស៊ាន (Leadership and Management Skills for ASEAN Custom Officers) |
| | ៦ វគ្គ | ៧៤៣នាក់ | សិក្ខាសាលា | កសហវ ក្រសួងពាណិជ្ជកម្ម ក្រសួងអភិវឌ្ឍជនបទ | -ស្តង់ដារគណនេយ្យអន្តរជាតិ (International Accounting Standard)<br>-ការគ្រប់គ្រងកំណែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច (Managing Reform of Economic Structure)<br>-ផែនការចំណាយសាធារណៈ (Public Expenditure Plan) |

| | | | | | |
|---|---|---|---|---|---|
| | | | | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ធនាគារជាតិកម្ពុជា<br>ក្រសួងផែនការ<br>ក្រសួងសុខាភិបាល និងគណៈរដ្ឋមន្ត្រី | -ប្រព័ន្ធហិរញ្ញវត្ថុរបស់អង្គការសិលា (Seila Financial System)<br>-ទស្សនាទានស្តីពី របៀងនៃកំណើន (Concept of the Growth Corridors)<br>-ប្រព័ន្ធថវិកាឆ្នាំ ២០០០ (Budgeting System of year 2000) |
| **២០០០** | ១១២ វគ្គ | ៣៣៦០ នាក់ | វគ្គរយៈពេលខ្លី | នាយកដ្ឋានពាក់ព័ន្ធនៃកសហវ | - គណនេយ្យហិរញ្ញវត្ថុ (Financial Accounting)<br>- ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ (Financial Statement Analysis)<br>- ប្រព័ន្ធហិរញ្ញវត្ថុ (Financial System)<br>- គណនេយ្យធនាគារ (Bank Accounting)<br>- ជំនាញសវនកម្ម (Auditing Skills)<br>- ពន្ធលើប្រាក់បៀវត្សន៍ (Salaries Tax)<br>- ជំនាញកុំព្យូទ័រ (Computer Skills)<br>- ការវិភាគ និង ព្យាករណ៍សេដ្ឋកិច្ច (Economics Analysis and Forecasting)<br>- ការសម្របសម្រួលនយោបាយ (Policy Coordination)<br>- តួនាទីរដ្ឋាភិបាល (Role of Government)<br>- ទស្សនាទានមីក្រូសេដ្ឋកិច្ច (Microeconomic Concept)<br>- គោលនយោបាយសារពើពន្ធ (Fiscal Policy)<br>- ការរៀបចំថវិកា (Budgeting)<br>- ប្រតិបត្តិការពាណិជ្ជកម្ម (Commercial Transaction)<br>- ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Control of Public Finance)<br>- គណនេយ្យសាធារណៈ (Public Accounting)<br>- អង្គភាពហិរញ្ញវត្ថុក្នុងស្រុក (Local Entity Finance) |

| | | | | | |
|---|---|---|---|---|---|
| | | | | | - ទំនាក់ទំនងសាធារណៈ (Public Relation)<br>- ជំនាញពន្ធដារ (Taxation Skills)<br>- ភាសាអង់គ្លេសទូទៅ (General English)<br>- ភាសាអង់គ្លេស សម្រាប់ជំនាញពិសេស (English for Specific Skills)<br>- ភាសាអង់គ្លេស កម្រិតដំបូង (English for Beginner)<br>- នីតិរដ្ឋបាល (Administrative Law)<br>- នីតិកិច្ចសន្យា (Contract Law)<br>- ច្បាប់ស្តីពីអង្គភាពធុរកិច្ច (Law on Business Organization)<br>- នីតិវិធីគតិយុត្តិ (Legal Process)<br>- បទដ្ឋានគតិយុត្តិចំពោះពាណិជ្ជកម្មទំនិញអន្តរជាតិ (International Sale of Goods)<br>- កិច្ចសន្យាទូទាត់ និងប្រព័ន្ធទូទាត់ (Negotiable Instruments and Payment System) |
| | ១ វគ្គ | ៣០ នាក់ | វគ្គរយៈពេលវែង | មន្រ្តីមកពីអគ្គាធិការដ្ឋាននៃកសហវ | - ជំនាញសវនកម្ម (Auditing Skills) |
| | ១ វគ្គ | ៧៥ នាក់ | សិក្ខាសាលា | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -កម្មវិធី និង គោលនយោបាយហិរញ្ញវត្ថុ (Financial Programming and Policy) |
| **២០០១** | ៩៧ វគ្គ | ២៩១០ នាក់ | វគ្គរយៈពេលខ្លី | នាយកដ្ឋានពាក់ព័ន្ធនៃកសហវ | -គណនេយ្យហិរញ្ញវត្ថុ (Financial Accounting)<br>-សវនកម្ម (Auditing)<br>-ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ (Financial Statement Analysis)<br>-គណនេយ្យគ្រប់គ្រង (Managerial Accounting)<br>-ជំនាញកុំព្យូទ័រ (Computer Skills)<br>-គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច (Macroeconomic Policy)<br>-អង្គភាពក្នុងស្រុក (Local Entity) |

| | | | | | |
|---|---|---|---|---|---|
| | | | | | -ធុរកិច្ចទូទៅ (General Business)<br>-ជំនាញអង់គ្លេស (English Course)<br>-ច្បាប់ស្ដីពីអង្គភាពធុរកិច្ច (Business Organization Law)<br>-ច្បាប់ស្ដីពីប្រតិបត្តិការពាណិជ្ជកម្ម (Commercial Transaction Law)<br>-សហគ្រាសពាណិជ្ជកម្ម (Commercial Enterprise)<br>-ស្លាកសញ្ញាពាណិជ្ជកម្ម (Trade Mark)<br>-នីតិរដ្ឋបាល (Administrative Law)<br>-នីតិវិធីគតិយុត្ត (Legal Process)<br>-ការគ្រប់គ្រងថវិកា (Budget Management)<br>-គណនេយ្យសាធារណៈ (Public Accounting)<br>-លទ្ធកម្មសាធារណៈ (Public Procurement) |
| | ១ វគ្គ | ៣០ នាក់ | វគ្គរយៈពេលវែង | នាយកដ្ឋានពាក់ព័ន្ធនៃកសហវ | -ជំនាញពន្ធដារ (Taxation Skills) |
| | ៩ វគ្គ | ៧៦៥ នាក់ | សិក្ខាសាលា | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -ការវិភាគភាពក្រីក្រ (Poverty Analysis)<br>-គោលនយោបាយអភិវឌ្ឍន៍ (Development Policies)<br>-ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Finance Management)<br>-ការវិភាគគោលនយោបាយសារពើពន្ធ (Fiscal Policy Analysis)<br>-គោលនយោបាយសារពើពន្ធនៃសេដ្ឋកិច្ចបើកចំហរ (Fiscal Policy in Open Economic)<br>-ការធ្វើហិរញ្ញទានចំពោះឱនភាពថវិកា (Financing the Deficit)<br>-ការវិភាគគោលនយោបាយសារពើពន្ធ (Fiscal Policy Analysis) |
| ២០០២ | ១៦ វគ្គ | ៤៨០នាក់ | វគ្គរយៈពេលខ្លី | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -ប្រភពនិងការប្រើប្រាស់មូលនិធិសេវាសង្គម (Source and Uses of Funds for Social Service)<br>-ការគ្រប់គ្រងចំណាយសាធារណៈ (Public Expenditure Management)<br>-ក្របខណ្ឌចំណាយ រយៈពេលមធ្យម (Medium-term Expenditure Framework) |

| | | | | | |
|---|---|---|---|---|---|
| | | | | | -វិមជ្ឈការសារពើពន្ធ (Fiscal Decentralization)<br>-ការគ្រប់គ្រងចំណាយសាធារណៈ (Public Expenditure Management)<br>-ការវិភាគគោលនយោបាយសារពើពន្ធ (Fiscal Policy Analysis)<br>-ការគ្រប់គ្រងចំណាយសាធារណៈ (Public Expenditure Management)<br>-ការវិភាគគោលនយោបាយសារពើពន្ធ (Fiscal Policy Analysis) |
| | ៧ វគ្គ | ៣១៥នាក់ | សិក្ខាសាលា | រតនាគារជាតិ និងខេត្ត នៃកសហវ | -កម្មវិធី និង គោលនយោបាយហិរញ្ញវត្ថុ (Financial Programming and Policy)<br>-បញ្ហាពន្ធ និង សារពើពន្ធ (Fiscal and Tax Issues)<br>-អង្គការពាណិជ្ជកម្មពិភពលោក (World Trade Organization)<br>- ការត្រៀមខ្លួនរបស់កម្ពុជាសម្រាប់ AFTA (Cambodia Preparation for AFTA)<br>-ការគ្រប់គ្រងចំណាយសាធារណៈ (Public Expenditure Management)<br>-យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចសម្រាប់ប្រទេសក្នុងអាស៊ីខាងកើត (Economic Development Strategy for East Asian Countries) |
| ២០០៣ | ៣២ វគ្គ | ៩៦០នាក់ | វគ្គរយៈពេលខ្លី | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -គណនេយ្យហិរញ្ញវត្ថុ (Financial Accounting)<br>-គណនេយ្យសាធារណៈ (Public Accounting)<br>-គណនេយ្យចំណាយ (Cost Accounting)<br>-ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ (Financial Statement Analysis)<br>-សវនកម្ម (Auditing)<br>- Quick Book<br>-ការគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានវិទ្យា (IT Management)<br>-ជំនាញកុំព្យូទ័រ (Computer Skills)<br>-មីក្រូសេដ្ឋកិច្ច (Microeconomics)<br>-ម៉ាក្រូសេដ្ឋកិច្ច (Macroeconomics)<br>-ជំនាញពន្ធដារ (Taxation Skills)<br>-ជំនាញភាសាអង់គ្លេស (English Courses) |

| | | | | | |
|---|---|---|---|---|---|
| | ១ វគ្គ | ៣០ នាក់ | វគ្គរយៈពេលវែង | នាយកដ្ឋានពាក់ព័ន្ធនៃកសហវ | -ជំនាញពន្ធដារ (Taxation Skills) |
| | ១៨ វគ្គ | ៧២០ នាក់ | សិក្ខាសាលា | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល | -ក្របខណ្ឌសមាហរណកម្មនិងអង្គការពាណិជ្ជកម្មពិភពលោក (Integrated Framework WTO)<br>-ការត្រៀមខ្លួនរបស់កម្ពុជាសម្រាប់ AFTA (Cambodia Preparation for AFTA)<br>-ការតាមដានត្រួតពិនិត្យ និងវាយតម្លៃចំណាយសាធារណៈ (Integrated Fiduciary Assessment and Public Expenditure Review)<br>-ការកែតម្រូវម៉ាក្រូសេដ្ឋកិច្ច ក្នុងសេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់ "ករណីកម្ពុជា" (Macroeconomic Adjustment in Highly Dollarized Economy: The Case of Cambodia)<br>-ការគ្រប់គ្រងហិរញ្ញវត្ថុ (Financial Management)<br>-គោលនយោបាយអភិវឌ្ឍន៍ MOF/JCIF (MOF/JCIF Development Policies)<br>-ការគ្រប់គ្រងចំណាយសាធារណៈ (Public Expenditure Management) |
| **សរុបផ្នែកទី១ (១៩៩៤-២០០៣)** | **៤៧៦ វគ្គ** | **១៤,៨១៣នាក់** | | | |
| **ផ្នែកទី២: ឆ្នាំ ២០០៤ - ២០១៦** | | | | | |
| **២០០៤** | ៨ វគ្គ | ២៤០ នាក់ | វគ្គរយៈពេលខ្លី | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -មូលដ្ឋានគ្រឹះគណនេយ្យ (Basic Accounting)<br>-គណនេយ្យកម្រិតមធ្យម (Intermediate Accounting)<br>-ការវាយតម្លៃខ្លួនឯង (Self-Assessment) |
| | ២ វគ្គ | ២៤០ នាក់ | សិក្ខាសាលា | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -រដ្ឋបាលពន្ធដារការអនុវត្ត (Practical Tax Administration)<br>-ផែនការភ្នំពេញសម្រាប់គ្រប់គ្រងការអភិវឌ្ឍមហាអនុតំបន់មេគង្គ: សម្រាប់ថ្នាក់ដឹកនាំជាន់ខ្ពស់ (GMS-Phnom Penh Plan for Development Management: Advanced Executive Development Program for Senior Officials) |

| | | | | | |
|---|---|---|---|---|---|
| ២០០៥ | ៦ វគ្គ | ១៨០ នាក់ | វគ្គរយៈពេលខ្លី | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -សវនកម្ម (Auditing)<br>-សវនកម្មពន្ធ (Tax Auditing)<br>-ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Finance Management) |
| | ៣ វគ្គ | ៩០ នាក់ | សិក្ខាសាលា | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -ផែនការភ្នំពេញសម្រាប់គ្រប់គ្រងការអភិវឌ្ឍមហាអនុតំបន់មេគង្គៈ សម្រាប់ថ្នាក់ដឹកនាំជាន់ខ្ពស់ (GMS-Phnom Penh Plan for Development Management: Advanced Executive Development Program for Senior Officials)<br>-រចនាសម្ព័ន្ធវិស័យកសិកម្មកម្ពុជាក្នុងបរិបទសមាហរណកម្មពាណិជ្ជកម្ម (Cambodia"s Agrarian Structure in the Context of Trade Integration)<br>-ផែនការភ្នំពេញសម្រាប់គ្រប់គ្រងការអភិវឌ្ឍមហាអនុតំបន់មេគង្គៈ សម្រាប់ថ្នាក់ដឹកនាំជាន់ខ្ពស់ (GMS-Phnom Penh Plan for Development Management: Advanced Executive Development Program for Senior Officials) |
| ២០០៦ | ៧ វគ្គ | ៨៨៦នាក់ | សិក្ខាសាលា | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -សិក្ខាសាលាថ្នាក់ជាតិ ស្តីពី ច្បាប់ថវិកាឆ្នាំ ២០០៧ និង កំណែទម្រង់ថវិកា (National Seminar on Budget Law 2007, Budget Reform)<br>-ការអនុវត្តរដ្ឋបាលពន្ធដារ MOF/JCIF (MOF/JCIF Practical Tax administration)<br>-កំណែទម្រង់សេវាសាធារណៈ (Civil Service Reform)<br>-ការសម្រេចចិត្តលើចំណាយមូលធន សម្រាប់ថ្នាក់ខេត្ត [Capital Expenditure Decision for Provincial Level (Line-Ministries)]<br>-សិក្ខាសាលាអ្នករៀបចំគោលនយោបាយជាន់ខ្ពស់ ស្តីពី ការសម្រេចចិត្តលើចំណាយមូលធន សម្រាប់ថ្នាក់ខេត្ត [Senior Policymaker Seminar: Capital Expenditure Decision for Provincial Level (Line-Ministries)]<br>-ការស្វែងយល់អំពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់មន្ត្រីជាន់ខ្ពស់ (Understanding of Public Financial Management Reform Program for Senior Officials of the Line Ministries) |

| | | | | | |
|---|---|---|---|---|---|
| **២០០៧** | ៣២ វគ្គ | ២៥១៤នាក់ | វគ្គរយៈពេលខ្លី | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -ការគ្រប់គ្រង MBPI (MBPI Management)<br>-កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈនិងបច្ចេកទេស (Professional and Technical Development Program)<br>-វិជ្ជាជីវៈគណនេយ្យ ភាគ ១ និង ភាគ ២ (Professional Accounting Part 1&2)<br>-ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (State Property Management)<br>-កម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ អំពី ការគ្រប់គ្រងការផ្លាស់ប្តូរ និង ភាពជាអ្នកដឹកនាំ (Leadership Development Program: Change Management and Leadership)<br>-កម្មវិធី និង គោលនយោបាយហិរញ្ញវត្ថុ (Financial Programming and Policies)<br>-នយោបាយ និង សេដ្ឋកិច្ចអន្តរជាតិ សម្រាប់វិស័យសាធារណៈ (International Politics and Economics for Public Sector)<br>-ជំនាញចរចាកម្រិតមធ្យម (Intermediate Negotiation Skills)<br>-កម្មវិធីអ្នកដឹកនាំមេគង្គ (Mekong Leader Program)<br>-ពន្ធដារអន្តរជាតិសម្រាប់ប្រទេសតំបន់អាស៊ាន (International Taxation for Asian Countries)<br>-កំណែទម្រង់ហិរញ្ញវត្ថុក្នុងវិស័យសាធារណៈ (Financial Reform in the Public Sector)<br>-ការរចនា និង គ្រប់គ្រងគម្រោងព័ត៌មានវិទ្យា (IT Project Design and Management)<br>-ការអភិវឌ្ឍសមត្ថភាព ធ្វើឱ្យការសម្រេចចិត្តលើចំណាយមូលធនប្រសើរឡើង (Building Capacity for Improving Capital Expenditure Decision)<br>-សិក្ខាសាលាសម្រាប់អ្នករៀបចំគោលនយោបាយជាន់ខ្ពស់ ស្តីពីការធ្វើឱ្យមូលធនប្រសើរឡើង (Senior Policymaker seminar on Improving Capital)<br>-ការសម្រេចចិត្តចំណាយ (Expenditure Decision)<br>-រចនាដំណើរការធុរកិច្ច (Business Process Design)<br>-ការព្យាករណ៍ចំណូល (Revenue Forecasting) |

| | | | | | |
|---|---|---|---|---|---|
| | | | | | -ការគ្រប់គ្រប់វិស័យទេសចរណ៍ក្នុងតំបន់ GMS (Tourism Management in the GMS Countries)<br>-យុទ្ធសាស្ត្ររៀបចំផែនការថវិកា (Budget Plan Strategy)<br>-ការពង្រឹងក្របខណ្ឌច្បាប់នៃប្រព័ន្ធសវនកម្ម (Strengthening Legal Framework of Auditing System)<br>-ការគ្រប់គ្រងការជួញដូរមូលបត្រ (Stock Exchange Management)<br>-វិជ្ជាជីវៈគណនេយ្យ (Professional Accounting)<br>-ការគ្រប់គ្រងហិរញ្ញវត្ថុ និង សវនកម្ម (Financial Management and Auditing)<br>-ICT for FMIS application<br>-ច្បាប់ពាណិជ្ជកម្មអន្តរជាតិៈ កិច្ចចរចា និងយន្តការដោះស្រាយជម្លោះ ក្នុងអង្គការពាណិជ្ជកម្មពិភពលោក (International Trade Law: WTO Negotiations and WTO Dispute Settlement Mechanism)<br>-ការអភិវឌ្ឍសហគ្រាសខ្នាតតូចនិងមធ្យម (Small and Medium Enterprise Development)<br>-ថវិកាកម្មវិធី (Program Budgeting)<br>-មីក្រូធានារ៉ាប់រងសម្រាប់ក្រសួងស្ថាប័ន (Micro Insurance for Line-Ministries) |
| ២០០៨ | ៤៣ វគ្គ | ១២៧៧នាក់ | វគ្គរយៈពេលខ្លី | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -គណនេយ្យហិរញ្ញវត្ថុ វគ្គ១ (Financial Accounting I)<br>-គណនេយ្យហិរញ្ញវត្ថុកម្រិតខ្ពស់ (Advance Financial Accounting)<br>-គណនេយ្យ និង សវនកម្ម (Accounting and Auditing)<br>- ICT and PFM<br>-គណនេយ្យ និង ហិរញ្ញវត្ថុសាធារណៈ (Accounting and Public Finance)<br>-ICT for FMIS<br>-គណនេយ្យកម្រិតមធ្យម និង សវនកម្ម (Intermediate Accounting and Auditing)<br>-ភាសាអង់គ្លេសសម្រាប់គណនេយ្យ និង ហិរញ្ញវត្ថុ (English language for Accounting and Finance) |

| | | | | | |
|---|---|---|---|---|---|
| | | | | | -បច្ចេកទេសសវនកម្មសម្រាប់មន្ត្រីថ្នាក់កណ្ដាល (Audit tecniques for officials at central level)<br>-ការគ្រប់គ្រងថវិកា (Budget management)<br>-កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM Reform Programme)<br>-ប្លង់គណនេយ្យ (Chart of Accounts)<br>-ការគ្រប់គ្រងលទ្ធកម្មសាធារណៈ (Public Procurement Management)<br>-ការវិភាគទិន្នន័យ និង ការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (Economic and Finance Data analysis and Management)<br>-ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច (Macroeconomic management)<br>-ការសម្រេចចិត្តលើចំណាយមូលធន (Capital expenditure decision)<br>-បច្ចេកទេសសវនកម្ម និង ICT សម្រាប់មន្ត្រីថ្នាក់ខេត្ត (Audit techniques & ICT for officials at provincial level) |
| | ៣៣ វគ្គ | ៣១៣៤នាក់ | សិក្ខាសាលា | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -សេវាកម្មសម្រាប់អ្នកបង់ពន្ធ (Tax payer services)<br>-ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (Public finance system)<br>-សវនកម្មពន្ធ (Tax auditing)<br>-ការគ្រប់គ្រងចំណូលមិនមែនពន្ធ (Non-tax revenue management)<br>-ការគ្រប់គ្រងការផ្លាស់ប្ដូរ (Change management)<br>-ការអភិវឌ្ឍមូលបត្រក្នុងប្រទេសកម្ពុជា (Securities development in Cambodia)<br>-ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ [Public Financial Management (PFM)]<br>-សិក្ខាសាលាអន្តរជាតិស្ដីពីការគ្រប់គ្រងវិស័យទេសចរណ៍ (International seminar on tourism management)<br>-ផែនការលទ្ធកម្ម (Procurement Planning) |

| | | | | | |
|---|---|---|---|---|---|
| | | | | | -ការលើកទឹកចិត្ត និង អភិវឌ្ឍន៍ស្ថាប័ន (Institutional development and motivation)<br>-ប្រតិបត្តិការសវនកម្មផ្ទៃក្នុង (Internal audit operation)<br>-ការធ្វើឱ្យគោលនយោបាយមិនមែនពន្ធប្រសើរឡើង (Non-tax policy improving)<br>-គណនេយ្យហិរញ្ញវត្ថុ (Financial accounting)<br>-ការរៀបចំ និង អនុវត្តកម្មវិធីថវិកា (Preparation and implementation of program based budgeting)<br>-សមាហរណកម្មចំណាត់ថ្នាក់ និងមាតិកាថវិកា (Integration of budget classification and contents)<br>-ក្របខណ្ឌចំណាយរយៈពេលមធ្យម (Medium term expenditure framework)<br>-តារាងនៃប្រតិបត្តិការហិរញ្ញវត្ថុ (Table of Financial Execution (TOFE))<br>-តារាងនៃប្រតិបត្តិការហិរញ្ញវត្ថុ និង ម៉ាក្រូសេដ្ឋកិច្ច (Table of Financial Execution and macro economy)<br>-ការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (Strengthening state property management)<br>-ការអភិវឌ្ឍសមត្ថភាព សម្រាប់អនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Capacity building for PFM implementation)<br>-ការកាត់បន្ថយជំហាននៃនីតិវិធីធានាចំណាយ (Reducing procedure for expenditure guaranteeing processes)<br>-នីតិវិធីនៃការគ្រប់គ្រងសាច់ប្រាក់សាធារណៈ (Public cash management procedures)<br>-ការអនុវត្តគម្រោង FMIS (Implementation of FMIS project)<br>- ប្រាក់ឧបត្ថម្ភដល់រដ្ឋបាលរដ្ឋាករ (Excise administration allowance)<br>-របាយការណ៍និងចំណូលរដ្ឋបាលពន្ធគយ (Excise administration revenue and statements)<br>-ការទូទាត់ប្រាក់ឧបត្ថម្ភ (Allowance payment) |

| | | | | | |
|---|---|---|---|---|---|
| | | | | | -ការរក្សាទុកបញ្ជីគណនេយ្យរដ្ឋបាល (Administrative accounting list keeping)<br>-ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (State property inventory preparation)<br>-កំណើននៃការប្រើប្រាស់សេវាធនាគារពាណិជ្ជ (Expanding usage of commercial bank service)<br>-ការផ្ទៀងផ្ទាត់ និង បិទគណនេយ្យនៃស្ថាប័នរដ្ឋនៅធនាគារពាណិជ្ជ (Synchronizing and closing accounts of public institution at commercial banks)<br>-ការរៀបចំថវិកាចំណាយមូលធន (Capital expenditure budgeting preparation) |
| **២០០៩** | ៣២ វគ្គ | ១២៥០នាក់ | វគ្គរយៈពេលខ្លី | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -ការសរសេរសេចក្តីស្នើគម្រោង (Project Proposal Writing)<br>-សមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់អាស៊ាន និងជាមួយប្រទេសដទៃ ក្នុងបរិការណ៍ប្រទេសកម្ពុជា [Regional Economic Integration for ASEAN and With Third Countries (for Cambodia)]<br>-វគ្គវិជ្ជាជីវៈពន្ធដារ ស្តីពី ការគ្រប់គ្រងសេវាសម្រាប់អ្នកបង់ពន្ធ (Professional Taxation Course: Tax Payer Service Management)<br>-ប្រសិទ្ធិភាពនៃការគ្រប់គ្រងគម្រោង ដើម្បីប្រសិទ្ធិភាពសេវាសាធារណៈ (Effective Project Management for an Effective Public Services)<br>-បច្ចេកទេសក្នុងការទំនាក់ទំនង (Communication Technique)<br>-ការគ្រប់គ្រងចំណូល (Revenue Management)<br>-ការគ្រប់គ្រងការផ្លាស់ប្តូរក្នុងបរិការណ៍ FMIS (Change Management with regards to FMIS)<br>-ការអភិវឌ្ឍទីផ្សារសញ្ញាប័ណ្ណ (Bond Market Development)<br>-កំណែទម្រង់ការគ្រប់គ្រងសារពើពន្ធ (Fiscal Management Reform)<br>-ការអនុវត្តប្រព័ន្ធ FMIS (FMIS Implementation)<br>-ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Finance Management)<br>-សវនកម្ម (Auditing) |

| | | | | | |
|---|---|---|---|---|---|
| | ២ វគ្គ | ២៣៨នាក់ | សិក្ខាសាលា | | -ការគ្រប់គ្រងវិស័យទេសចរណ៍ ក្នុងមហាអនុតំបន់ទន្លេមេគង្គ (GMS Tourism Management)<br>-រចនាសម្ព័ន្ធកសិកម្មនៅកម្ពុជា ក្នុងបរិបទសមាហរណកម្មពាណិជ្ជកម្ម (Cambodia's Agrarian Structure in the Context of Trade Integration) |
| ២០១០ | ១៨ វគ្គ | ៦៣១នាក់ | វគ្គរយៈពេលខ្លី | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -ការអនុវត្តប្រព័ន្ធ FMIS (FMIS Implementation)<br>-ការប្រើប្រាស់ចំណាត់ថ្នាក់ថវិកា និង ប្លង់គណនេយ្យ (Use of Budget Classification and Chart of Account)<br>-ការផ្សារភ្ជាប់ថវិកា និងផែនការយុទ្ធសាស្ត្រ (Linking Strategic Plans with Budget)<br>-ប្រសិទ្ធភាពនៃការធ្វើប្រតិភូកម្មថវិកា (Effective Budget Delegation)<br>-ការវិភាគថវិកា (Analyzing Budget)<br>-ការអនុវត្តថវិកា (Budget Execution)<br>-ថវិកាកម្មវិធី (Program Budgeting)<br>-គណនេយ្យ (Accounting)<br>-គណនេយ្យ កម្រិតខ្ពស់ (Advanced Accounting)<br>-ប្រព័ន្ធជូនដំណឹងបឋម ចំពោះភាពផុយស្រួយនៃហិរញ្ញវត្ថុ និងសូចនករ(Financial Vulnerability and Vulnerability Indicators and Early Warning System)<br>-ការគ្រប់គ្រងលទ្ធកម្មសាធារណៈ និងការត្រួតពិនិត្យ/គណនេយ្យភាព (Public Procurement Management and Oversight/ Accountability)<br>-ការគ្រប់គ្រងការផ្លាស់ប្តូរ និង ភាពជាអ្នកដឹកនាំ (Change Management and Leadership)<br>-រៀបចំផែនការ ការចរចា និងធ្វើកិច្ចសន្យាលទ្ធកម្ម (Procurement Planning Contracts and Negotiations)<br>-ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងគោលនយោបាយសាធារណៈ សម្រាប់មន្ត្រីថ្នាក់កណ្តាល (Public Policy Management for Leadership for Mid Level Officials)<br>-ការរាយការណ៍ពីលទ្ធកម្មសាធារណៈ (Public Procurement Reporting) |

| | | | | | |
|---|---|---|---|---|---|
| | ៣ វគ្គ | ៧២នាក់ | សិក្ខាសាលា | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -កម្មវិធីបណ្តុះបណ្តាល ស្តីពី គោលនយោបាយសាធារណៈ សម្រាប់មន្ត្រីថ្នាក់កណ្តាល (Public Policy Training Program (EFI and Nagoya University, under the ADB) for mid-level officials<br>-កម្មវិធីបណ្តុះបណ្តាល ស្តីពី គោលនយោបាយសាធារណៈ សម្រាប់ថ្នាក់ដឹកនាំជាន់ខ្ពស់(Public Policy Training Program (EFI and Nagoya University, under the ADB) for senior-level officials)<br>-កម្មវិធីសិក្សាចក្ខុវិស័យតំបន់ អំពី ការរៀបចំ និងការវាយតម្លៃ គោលនយោបាយសាធារណៈ (Public Policy Design and Evaluation Regional Perspective Learning Program) |
| ២០១១ | ១៦ វគ្គ | ៥៦៦នាក់ | វគ្គរយៈពេលខ្លី | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -ផែនការលំហូសាច់ប្រាក់ (Cash flow planning)<br>-ការគ្រប់គ្រងលំហូសាច់ប្រាក់ (Cash flow managing)<br>-ការរចនាប្លង់គណនេយ្យ (Chart of account design)<br>-យុទ្ធសាស្ត្របំណុល (Debt strategy)<br>-ការគ្រប់គ្រងបំណុល (Debt management)<br>-ការព្យាករណ៍ (Forecasting)<br>-ការអភិវឌ្ឍគោលនយោបាយចំណូល (Revenue policy development)<br>-ការរៀបចំដំណើរការធុរកិច្ច (Business process design)<br>-ការរៀបចំផែនការលំហូរសាច់ប្រាក់ (Cash flow planning)<br>-ការអនុវត្តទម្រង់ FMIS (FMIS Implementation form)<br>-ការប្រើប្រាស់ចំណាត់ថ្នាក់ថវិកា និង ប្លង់គណនេយ្យ (Use of Budget Classification and Chart of Account)<br>-ការផ្សារភ្ជាប់ថវិកា និងផែនការយុទ្ធសាស្ត្រ (Linking Strategic Plans with Budget) |

| | | | | | |
|---|---|---|---|---|---|
| | | | | | -ប្រសិទ្ធភាពនៃការធ្វើប្រតិភូកម្មថវិកា (Effective Budget Delegation)<br>-ការវិភាគថវិកា (Analyzing Budget)<br>-ការអនុវត្តថវិកា (Budget Execution)<br>-ថវិកាកម្មវិធី (Program Budgeting) |
| | ៣ វគ្គ | ៧៥នាក់ | សិក្ខាសាលា | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Strengthening Public Financial Management)<br>- ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងគោលនយោបាយសាធារណៈ នៅសៀងហៃប្រទេសចិន (Shanghai, China, Public Policy Management for Leadership)<br>- កម្មវិធីសិក្សាចក្ខុវិស័យតំបន់ អំពី ការរៀបចំ និងការវាយតម្លៃ គោលនយោបាយសាធារណៈ (Public Policy Design and Evaluation Regional Perspective Learning Program) |
| ២០១២ | ៦ វគ្គ | ៤៦៣នាក់ | វគ្គរយៈពេលខ្លី | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -ការវិភាគម៉ាក្រូសេដ្ឋកិច្ច និង ការរៀបចំថវិកា (Macro-Economic Analysis and Budgeting)<br>-ការរៀបចំថវិការយៈពេលមធ្យម និង អភិក្រមក្នុងការរៀបចំថវិកា (Medium Term budgeting and approaches to budgeting)<br>- ការគ្រប់គ្រងនិងត្រួតពិនិត្យសាច់ប្រាក់ (Cash Management and Control)<br>- ការចំណាយលើកម្មវិធី (Costing of programs)<br>-បទពិសោធន៍គណនេយ្យអន្តរជាតិ IPSAS (IPSAS accounting international experience)<br>-សវនកម្មផ្ទៃក្នុង និង ខាងក្រៅ ព្រមទាំងការគ្រប់គ្រង (External & Internal Audit and Control) |
| ២០១៣ | ១១វគ្គ | ១០២៤នាក់ | វគ្គរយៈពេលខ្លី | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -ភាពជាអ្នកដឹកនាំ ការគ្រប់គ្រង និងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ (Leadership Management and Public Financial Management Reform) |
| ២០១៤ | ៤វគ្គ | ១៣០នាក់ | វគ្គរយៈពេលខ្លី (ក្រៅប្រទេស) | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ “បទពិសោធន៍ប្រទេសចិន” |

| | | | | | |
|---|---|---|---|---|---|
| ២០១៥ | ១០វគ្គ | ៩៩០នាក់ | សិក្ខាសាលាក្នុងស្រុក | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -ការត្រួតពិនិត្យនិងវាយតម្លៃ<br>-ការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ<br>-សវនកម្ម<br>-ថវិកាតាមកម្មវិធី<br>-ថវិកាតាមកម្មវិធីសម្រាប់អង្គភាពថវិកា |
| | ៥វគ្គ | ១៥០ នាក់ | សិក្ខាសាលាក្រៅស្រុក | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -ភាពជាអ្នកដឹកនាំ<br>-កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ "បទពិសោធន៍ប្រទេសចិន" |
| ២០១៦ | ៤៤ វគ្គ | ៣០៥៦នាក់ | សិក្ខាសាលាក្នុងស្រុក | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ និងតាមបណ្ដារាជធានី-ខេត្ត | -នីតិវិធីអនុវត្តរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធី<br>-នីតិវិធីអនុវត្តថវិកាកម្មវិធី: ការអនុវត្ត និង ត្រួតពិនិត្យ<br>-វិធាន និង បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ<br>-នីតិវិធីអនុវត្តថវិកាកម្មវិធីសម្រាប់អង្គភាពថវិកា<br>-ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយប្រែប្រួលអាកាសធាតុ<br>-ការរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>-នីតិវិធីអនុវត្តថវិកាកម្មវិធីសម្រាប់អង្គភាពថវិកា នៃក្រសួងអប់រំ យុវជន និងកីឡា<br>-នីតិវិធីអនុវត្តថវិកាកម្មវិធីសម្រាប់អង្គភាពថវិកា ជូនមន្ត្រីរាជការនៃក្រសួងស្ថាប័នចំនួន ១១ ដែលអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បងឆ្នាំ ២០១៧ |
| | ៤ វគ្គ | ១១៥នាក់ | សិក្ខាសាលាក្រៅស្រុក | កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ | -ភាពជាអ្នកដឹកនាំ<br>-កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ "បទពិសោធន៍ប្រទេសចិន" |
| **សរុបផ្នែកទី២ (ឆ្នាំ២០០៤-២០១៦)** | **២៩២វគ្គ** | **១៧,៣១៧នាក់** | | | |
| **សរុបទាំង២ផ្នែក (ឆ្នាំ១៩៩៨-២០១៦)** | **៧៩៤វគ្គ** | **៣២,១៣០នាក់** | | | |

**ប្រភព:** វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ: តារាងរបាយការណ៍សង្ខេបលទ្ធផលនៃការបណ្តុះបណ្តាលរបស់ កសហវ ឆ្នាំ ១៩៩៨-២០១៦ ។

## ឧបសម្ព័ន្ធ ៥:
## តារាងគ្រឹះស្ថានសាធារណៈរដ្ឋបាល នៅព្រះរាជាណាចក្រកម្ពុជា

| ល.រ | គ្រឹះស្ថានសាធារណៈរដ្ឋបាល | ល.រ | គ្រឹះស្ថានសាធារណៈរដ្ឋបាល |
|---|---|---|---|
| ១ | មន្ទីរពេទ្យកាល់ម៉ែត | ១៦ | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច |
| ២ | សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | ១៧ | អាជ្ញាធរអប្សរា |
| ៣ | វិទ្យាស្ថានជាតិសុខភាពសាធារណៈ | ១៨ | រាជបណ្ឌិត្យសភាកម្ពុជា |
| ៤ | មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | ១៩ | វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា |
| ៥ | មន្ទីរពេទ្យព្រះកុសុមៈ | ២០ | បេឡាជាតិរបបសន្តិសុខសង្គម |
| ៦ | មន្ទីរពេទ្យកុមារជាតិ | ២១ | វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលនៃកងយោធពលខេមរភូមិន្ទ |
| ៧ | មន្ទីរពេទ្យព្រះអង្គឌួង | ២២ | បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល |
| ៨ | មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល | ២៣ | បេឡាជាតិអតីតយុទ្ធជន |
| ៩ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ២៤ | មូលនិធិជនពិការ |
| ១០ | សាកលវិទ្យាល័យភូមិន្ទកសិកម្ម | ២៥ | សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ |
| ១១ | សាលាជាតិកសិកម្មកំពង់ចាម | ២៦ | អាជ្ញាធរជាតិព្រះវិហារដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋាននៃប្រាសាទព្រះវិហារ |
| ១២ | សាលាជាតិកសិកម្មព្រែកលាប | ២៧ | អាជ្ញាធរអគ្គិសនីកម្ពុជា |
| ១៣ | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | ២៨ | គ្រឹះស្ថានអង្គរ |
| ១៤ | បញ្ញត្តិករទូរគមនាគមន៍កម្ពុជា | ២៩ | អាជ្ញាធរជាតិសំបូរព្រៃគុក |
| ១៥ | សាកលវិទ្យាល័យជាតិគ្រប់គ្រង | ៣០ | សាលាភូមិន្ទរដ្ឋបាល |

*ប្រភព: អគ្គនាយកដ្ឋានរតនាគារជាតិ, នាយកដ្ឋានចំណូលចំណាយថវិកា (គិតត្រឹមថ្ងៃទី១៣ មករា ២០១៧)*

## ឧបសម្ព័ន្ធ ៦: តារាងអង្គភាពថវិកានៃក្រសួងស្ថាប័ន និង មន្ទីរជំនាញ ដែលត្រូវអនុវត្តថវិកាកម្មវិធីឆ្នាំ ២០១៥ - ២០១៨

| លរ | ក្រសួងស្ថាប័ន និងមន្ទីរជំនាញ | ចំនួនអង្គភាពថវិកា | អ្នកចូលរួមក្នុង ១ អង្គភាពថវិកា (*) | សរុបអ្នកចូលរួម |
|---|---|---|---|---|
| I. ក្នុងឆ្នាំ ២០១៥ | | ៣៧៩ | | ៣,៧៩០ |
| ១ | ក្រសួងអប់រំ យុវជន និងកីឡា | ៣៩ | ១០ | ៣៩០ |
| ២ | ក្រសួងសុខាភិបាល | ៤៩ | ១០ | ៤៩០ |
| ៣ | ក្រសួងកិច្ចការនារី | ១០ | ១០ | ១០០ |
| ៤ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៦ | ១០ | ៦០ |
| ៥ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | ១៦ | ១០ | ១៦០ |
| ៦ | ក្រសួងអភិវឌ្ឍន៍ជនបទ | ៧ | ១០ | ៧០ |
| ៧ | ក្រសួងសាធារណៈការនិងដឹកជញ្ជូន | ៣ | ១០ | ៣០ |
| ៨ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១៦ | ១០ | ១៦០ |
| ៩ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ៤ | ១០ | ៤០ |
| ១០ | ក្រសួងយុត្តិធម៌ (រួមទាំងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម) | ៤ | ១០ | ៤០ |
| ១១ | មន្ទីររាជធានី ខេត្ត (៩ក្រសួង X ២៥ មន្ទីរ x ១ អង្គភាពថវិកា) | ២២៥ | ១០ | ២,២៥០ |
| II. ក្នុងឆ្នាំ ២០១៦ | | ២៣៧ | | ២,៣៧០ |
| ១ | តុលាការកំពូល | ១ | ១០ | ១០ |
| ២ | សាលាឧទ្ធរណ៍ | ១ | ១០ | ១០ |
| ៣ | អគ្គលេខាធិការដ្ឋានរដ្ឋសភា | ៤ | ១០ | ៤០ |
| ៤ | អគ្គលេខាធិកាដ្ឋានព្រឹទ្ធសភា | ៣ | ១០ | ៣០ |
| ៥ | អាជ្ញាធរសវនកម្មជាតិ | ៥ | ១០ | ៥០ |
| ៦ | អង្គភាពប្រឆាំងអំពើពុករលួយ | ១ | ១០ | ១០ |
| ៧ | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ៥ | ១០ | ៥០ |
| ៨ | ក្រសួងទេសចរណ៍ | ៤ | ១០ | ៤០ |
| ៩ | ក្រសួងពាណិជ្ជកម្ម | ៨ | ១០ | ៨០ |
| ១០ | ក្រសួងធនធានទឹក និងឧតុនិយម | ៧ | ១០ | ៧០ |
| ១១ | ក្រសួងព័ត៌មាន | ៥ | ១០ | ៥០ |
| ១២ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ៤ | ១០ | ៤០ |

| ល.រ | ក្រសួងស្ថាប័ន និងមន្ទីរជំនាញ | ចំនួនអង្គភាពថវិកា | អ្នកចូលរួមក្នុង ១ អង្គភាពថវិកា (*) | សរុបអ្នកចូលរួម |
|---|---|---|---|---|
| ១៣ | ក្រសួងបរិស្ថាន | ៤ | ១០ | ៤០ |
| ១៤ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៦ | ១០ | ៦០ |
| ១៥ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ៤ | ១០ | ៤០ |
| ១៦ | មន្ទីររាជធានី ខេត្ត (៧ក្រសួង X ២៥ មន្ទីរ x ១ អង្គភាពថវិកា) | ១៧៥ | ១០ | ១,៧៥០ |
| | **III. សម្រាប់ឆ្នាំ ២០១៧** | **២២១** | | **២,២១០** |
| ១ | ក្រសួង ព្រះបរមរាជវាំង | ១ | ១០ | ១០ |
| ២ | ក្រុមប្រឹក្សាធម្មនុញ្ញ | ១ | ១០ | ១០ |
| ៣ | ក្រសួងទំនាក់ទំនងសភា ព្រឹទ្ធសភា និងអធិការកិច្ច | ៣ | ១០ | ៣០ |
| ៤ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ៤ | ១០ | ៤០ |
| ៥ | ក្រសួងឧស្សាហកម្មនិងសិប្បកម្ម | ៨ | ១០ | ៨០ |
| ៦ | ក្រសួងរ៉ែនិងថាមពល | ៥ | ១០ | ៥០ |
| ៧ | ក្រសួងធម្មការនិងសាសនា | ១២ | ១០ | ១២០ |
| ៨ | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ៤ | ១០ | ៤០ |
| ៩ | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ១ | ១០ | ១០ |
| ១០ | ក្រសួងផែនការ | ៤ | ១០ | ៤០ |
| ១១ | ក្រសួងមុខងារសាធារណៈ | ៣ | ១០ | ៣០ |
| ១២ | មន្ទីររាជធានី ខេត្ត (៧ក្រសួង X ២៥ មន្ទីរ x ១ អង្គភាពថវិកា) | ១៧៥ | ១០ | ១,៧៥០ |
| | **សរុប** (I + II + III) | **៨៣៧** | | **៨,៣៧០** |
| | **IV. សម្រាប់ឆ្នាំ ២០១៨** | | | |
| ១ | ទីស្ដីការគណៈរដ្ឋមន្ត្រី | ២១ | ១០ | ២១០ |
| ២ | ក្រសួងការពារជាតិ | ១៦ | ១០ | ១៦០ |
| ៣ | ក្រសួងមហាផ្ទៃ | ១០ | ១០ | ១០០ |
| | | ***៤៧*** | | ***៤៧០*** |
| | ***សរុបរួមដល់ឆ្នាំ ២០១៨*** | ***៨៨៤*** | | ***៨,៨៤០*** |

***សម្គាល់:*** *(*) សមាសភាពអ្នកចូលរួមមាន: ថ្នាក់ដឹកនាំអង្គភាពថវិកា ២នាក់, មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ ២នាក់, រដ្ឋបាលបុគ្គលិក/ផ្នែកបុគ្គលិកប្រព័ន្ធ ២នាក់, ភ្នាក់ងាររបើកផ្តល់/រង ២ នាក់ និង ក្រុមលទ្ធកម្ម ២ នាក់ ដែលសរុប ១០ នាក់ ក្នុង ១ អង្គភាពថវិកា។*

***ប្រភព:*** *នាយកដ្ឋានហិរញ្ញកិច្ច នៃអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខែ ធ្នូ ឆ្នាំ ២០១៦ ។*